| ១៧ | ឯកឧត្តម ចាយ បូរិន | ប្រជាជនកម្ពុជា | កំពង់ចាម | ជំនួស ឯ.ឧ. ខៀវ កាញារិទ្ធ ០៩.១០.០៨ |
| ១៨ | ឯកឧត្តម ត្រេស សារ៉ុម | ប្រជាជនកម្ពុជា | កំពង់ចាម | ជំនួស ឯ.ឧ. ជា សុផារ៉ា ០៩.១០.០៨ |
| ១៩ | ឯកឧត្តម ង្វួន ស៊ីមអាន | ប្រជាជនកម្ពុជា | កំពង់ចាម | ជំនួស ឯ.ឧ. អ៊ឹម សិទ្ធី ០៩.១០.០៨ជំនួស ល.ជ អ៊ុក ម៉ាលី ២៧.០៥.០៩ |

| | | | | |
|---|---|---|---|---|
| ២០ | ឯកឧត្តម យស់ សុន | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ២១ | ឯកឧត្តម ជិន គឹមស្រេង | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ២២ | ឯកឧត្តម វ៉ាន់ សេងលី | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ២៣ | ឯកឧត្តម ខែក សំអុន | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ២៤ | លោកជំទាវ ថៃម សាវ៉ៃ | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ២៥ | លោកជំទាវ អ៊ឹម រុន | ប្រជាជនកម្ពុជា | កំពង់ចាម | |
| ២៦ | ឯកឧត្តម សម រង្ស៊ី | សម រង្ស៊ី | កំពង់ចាម | បាត់បង់សមាជិកភាពតំណាងរាស្ត្រ ១៥.០៣.១១ |
| ២៧ | ឯកឧត្តម សុវណ្ណា ពិសាខា | សម រង្ស៊ី | កំពង់ចាម | ជំនួស ឯ.ឧ. ម៉ៅ មុនីវណ្ណ ០៤.០៤.១១ |
| ២៨ | ឯកឧត្តម ជាម ច័ន្ទនី | សម រង្ស៊ី | កំពង់ចាម | |
| ២៩ | លោកជំទាវ ថាក់ ឡានី | សម រង្ស៊ី | កំពង់ចាម | |
| ៣០ | ឯកឧត្តម គឹមសួរ ភិរិទ្ធ | សម រង្ស៊ី | កំពង់ចាម | |
| ៣១ | ឯកឧត្តម កឹម សុខា | សិទ្ធិមនុស្ស | កំពង់ចាម | |
| ៣២ | ឯកឧត្តម យូ ហុកគ្រី | នរោត្តម រណឫទ្ធិ | កំពង់ចាម | |
| ៣៣ | សម្តេចចៅហ្វាវាំង គង់ សំអុល | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង | |
| ៣៤ | ឯកឧត្តម កែវ សូសាក់ | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង | ជំនួសឯ.ឧ អ៊ុក រ៉ាប៊ុន ១០.១០.០៨ |
| ៣៥ | លោកជំទាវ កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង | ជំនួស ឯ.ឧ. ត្រាំ អ៊ីវតឹក ១០.១០.០៨ |
| ៣៦ | ឯកឧត្តម ឃី វណ្ណដេត | សម រង្ស៊ី | កំពង់ឆ្នាំង | |
| ៣៧ | ឯកឧត្តម សាយ ឈុំ | ប្រជាជនកម្ពុជា | កំពង់ស្ពឺ | |
| ៣៨ | ឯកឧត្តម ហែម ខន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ | |
| ៣៩ | ឯកឧត្តម លី សុន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ | |
| ៤០ | ឯកឧត្តម សារិត ប៊ុច | ប្រជាជនកម្ពុជា | កំពង់ស្ពឺ | |

| | | | | |
|---|---|---|---|---|
| ៤១ | លោកជំទាវ អ៊ឹម សារឿន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ | |
| ៤២ | ឯកឧត្តម នុត រុំដួល | សម រង្ស៊ី | កំពង់ស្ពឺ | |
| ៤៣ | ឯកឧត្តម ង៉ួន ញិល | ប្រជាជនកម្ពុជា | កំពង់ធំ | |
| ៤៤ | ឯកឧត្តម អ៊ុន នឹង | ប្រជាជនកម្ពុជា | កំពង់ធំ | |
| ៤៥ | ឯកឧត្តម ញ៉ែម ផ្កាវី | ប្រជាជនកម្ពុជា | កំពង់ធំ | |
| ៤៦ | ឯកឧត្តម ស៊ិក ប៊ុនហុក | ប្រជាជនកម្ពុជា | កំពង់ធំ | |
| ៤៧ | ឯកឧត្តម ម៉ែន សុថាវរិន្ទ្រ | សម រង្ស៊ី | កំពង់ធំ | |
| ៤៨ | ឯកឧត្តម គុជ ម៉ូលី | ហ៊្វុនស៊ិនប៉ិច | កំពង់ធំ | |
| ៤៩ | ឯកឧត្តម នៃ ប៉េណា | ប្រជាជនកម្ពុជា | កំពត | |
| ៥០ | លោកជំទាវ សោម គីមសួគ៌ | ប្រជាជនកម្ពុជា | កំពត | |
| ៥១ | ឯកឧត្តម ទឹម ច័ន្ទតាព | ប្រជាជនកម្ពុជា | កំពត | ជំនួស ឯ.ឧ ចាយ សាំងយុន ០៩.១០.០៨ |
| ៥២ | ឯកឧត្តម សាឡេះ សេន | ប្រជាជនកម្ពុជា | កំពត | ជំនួស ឯ.ឧ. ប៉ែន ស៊ីម៉ន ០៩.១០.០៨ ជំនួស ឯ.ឧ. ឃឹម សាម៉ន ២៧.០៥.០៩ |
| ៥៣ | ឯកឧត្តម សោម ចិន | ប្រជាជនកម្ពុជា | កំពត | |
| ៥៤ | លោកជំទាវ មួរ សុខហួរ | សម រង្ស៊ី | កំពត | |
| ៥៥ | សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន | ប្រជាជនកម្ពុជា | កណ្តាល | |
| ៥៦ | ឯកឧត្តម ហ្សាការីយ៉ា អាដាម | ប្រជាជនកម្ពុជា | កណ្តាល | ជំនួស ឯ.ឧ. ឆាយ ថន ១០.១០.០៨ |
| ៥៧ | ឯកឧត្តម ម៉ុម ជឹមហ៊ុយ | ប្រជាជនកម្ពុជា | កណ្តាល | |
| ៥៨ | លោកជំទាវ ហូ ណួន | ប្រជាជនកម្ពុជា | កណ្តាល | |
| ៥៩ | លោកជំទាវ ឃួន សុដារី | ប្រជាជនកម្ពុជា | កណ្តាល | |
| ៦០ | ឯកឧត្តម អ៊ុក ដាមរី | ប្រជាជនកម្ពុជា | កណ្តាល | ជំនួស ឯ.ឧ. លឹម គានហោ ១០.១០.០៨ |
| ៦១ | ឯកឧត្តម ជា ចំរើន | ប្រជាជនកម្ពុជា | កណ្តាល | ជំនួស ឯ.ឧ. ឌុល គឿន ១០.១០.០៨ |

| | | | | |
|---|---|---|---|---|
| ៦២ | ឯកឧត្តម ចាន់ ចេង | សម រង្ស៊ី | កណ្តាល | |
| ៦៣ | ឯកឧត្តម ឃឹម ឡាគី | សម រង្ស៊ី | កណ្តាល | |
| ៦៤ | លោកជំទាវ ពត ពៅ | សម រង្ស៊ី | កណ្តាល | |
| ៦៥ | ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ | សិទ្ធិមនុស្ស | កណ្តាល | |
| ៦៦ | ឯកឧត្តម អាយ ខន | ប្រជាជនកម្ពុជា | កោះកុង | |
| ៦៧ | លោកជំទាវ ត្រឹង ថារី | ប្រជាជនកម្ពុជា | ក្រចេះ | ជំនួសឯ.ឧ អ៊ឹម ឈុនលឹម ១០.១០.០៨ |
| ៦៨ | ឯកឧត្តម កាទើ តូយ៉េប | ប្រជាជនកម្ពុជា | ក្រចេះ | ជំនួស ឯ.ឧ. ឆាន់ សាផាន ១០.១០.០៨ |
| ៦៩ | ឯកឧត្តម ឡុង រី | សម រង្ស៊ី | ក្រចេះ | |
| ៧០ | លោកជំទាវ បេង រ៉ែន | ប្រជាជនកម្ពុជា | មណ្ឌលគិរី | ជំនួស ឯ.ឧ. វ័ត្ត សារ៉ែម ២៥.១១.១០ |
| ៧១ | ឯកឧត្តម ជា សុទ្ធ | ប្រជាជនកម្ពុជា | ភ្នំពេញ | |
| ៧២ | ឯកឧត្តម គាត ឈន់ | ប្រជាជនកម្ពុជា | ភ្នំពេញ | |
| ៧៣ | ឯកឧត្តម អ៊ុំ ញ៉ាញ់ | ប្រជាជនកម្ពុជា | ភ្នំពេញ | |
| ៧៤ | ឯកឧត្តម ហ៊ូ ស្រ៊ី | ប្រជាជនកម្ពុជា | ភ្នំពេញ | |
| ៧៥ | លោកជំទាវ គ្រួច សំអាន | ប្រជាជនកម្ពុជា | ភ្នំពេញ | |
| ៧៦ | លោកជំទាវ ឡោក ខេង | ប្រជាជនកម្ពុជា | ភ្នំពេញ | ជំនួស ឯ.ឧ អ៊ិត សំហេង ០៩.១០.០៨ |
| ៧៧ | ឯកឧត្តម ជៀប ស៊ីវន | ប្រជាជនកម្ពុជា | ភ្នំពេញ | ជំនួស ឯ.ឧ. ម៉ម ប៊ុនហេង ០៩.១០.០៨ |
| ៧៨ | លោកជំទាវ ជូឡុង សូមូរ៉ា | សម រង្ស៊ី | ភ្នំពេញ | |
| ៧៩ | ឯកឧត្តម យឹម សុវណ្ណ | សម រង្ស៊ី | ភ្នំពេញ | |
| ៨០ | ឯកឧត្តម សុន ឆ័យ | សម រង្ស៊ី | ភ្នំពេញ | |
| ៨១ | ឯកឧត្តម ហូរ វ៉ាន់ | សម រង្ស៊ី | ភ្នំពេញ | |
| ៨២ | លោកជំទាវ លី ស្រីវីណា | សម រង្ស៊ី | ភ្នំពេញ | |
| ៨៣ | ឯកឧត្តម ស៊ុក សំអេង | ប្រជាជនកម្ពុជា | ព្រះវិហារ | |
| ៨៤ | ឯកឧត្តម ជាម យៀប | ប្រជាជនកម្ពុជា | ព្រៃវែង | |

| | | | | |
|---|---|---|---|---|
| ៨៥ | ឯកឧត្តម ប៊ិន ឈិន | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៦ | ឯកឧត្តម ប៉ែន បញ្ញា | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៧ | ឯកឧត្តម ញឹម វណ្ណដា | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៨ | ឯកឧត្តម ពៅ សាមី | ប្រជាជនកម្ពុជា | ព្រៃវែង | ជំនួស ល.ជ ឡុង សាខន ១០.០៥.១១ |
| ៨៩ | ឯកឧត្តម សុខ ឥសាន | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៩០ | ឯកឧត្តម សុខ សាយ | ប្រជាជនកម្ពុជា | ព្រៃវែង | ជំនួស ឯ.ឧ មឹន ស៊ាន ០១.០៧.១០ |
| ៩១ | ឯកឧត្តម ជា ប៉ូច | សម រង្ស៊ី | ព្រៃវែង | |
| ៩២ | ឯកឧត្តម គង់ បូរ៉ា | សម រង្ស៊ី | ព្រៃវែង | |
| ៩៣ | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | សិទ្ធិមនុស្ស | ព្រៃវែង | |
| ៩៤ | ឯកឧត្តម សៅ រ៉ានី | នរោត្តម រណឫទ្ធិ | ព្រៃវែង | |
| ៩៥ | ឯកឧត្តម ឯម ប៉ុណ្ណា | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | ជំនួស ឯ.ឧ ស៊ុយ សែម ០៩.១០.០៨ |
| ៩៦ | ឯកឧត្តម សារី កោសល្យ | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | ជំនួសឯ.ឧ ជិន ប៊ុនស៊ាន ០៩.១០.០៨ |
| ៩៧ | ឯកឧត្តម លី ណារុន | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | |
| ៩៨ | ឯកឧត្តម ស្មាន ទៀត | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | |
| ៩៩ | ឯកឧត្តម ប៊ូ ថង | ប្រជាជនកម្ពុជា | រតនគិរី | |
| ១០០ | ឯកឧត្តម ទៀ បាញ់ | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០១ | ឯកឧត្តម សៀង ណាំ | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០២ | ឯកឧត្តម ឈឹម ម៉ា | ប្រជាជនកម្ពុជា | សៀមរាប | ជំនួស ឯ.ឧ កែវ សាផល ០៩.១០.០៨ |
| ១០៣ | លោកជំទាវ ពៅ សារឿន | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០៤ | ឯកឧត្តម សំ ហ៊ាង | ប្រជាជនកម្ពុជា | សៀមរាប | |

| | | | | |
|---|---|---|---|---|
| ១០៥ | លោកជំទាវ កែ សុវណ្ណរតន៍ | សម រង្ស៊ី | សៀមរាប | |
| ១០៦ | ឯកឧត្តម សួស កាណាន | ប្រជាជនកម្ពុជា | ព្រះសីហនុ | |
| ១០៧ | ឯកឧត្តម សន អ៊ិនថរ | ប្រជាជនកម្ពុជា | ស្ទឹងត្រែង | |
| ១០៨ | លោកជំទាវ ម៉ែន សំអន | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១០៩ | ឯកឧត្តម ហ៊ុល សាវ័ន្ត | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១០ | លោកជំទាវ ដួង វណ្ណា | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១១ | លោកជំទាវ ឈុន សារឹម | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១២ | ឯកឧត្តម សៅ ឡេង | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១៣ | ឯកឧត្តម សុខ អាន | ប្រជាជនកម្ពុជា | តាកែវ | |
| ១១៤ | លោកជំទាវ និន សាផុន | ប្រជាជនកម្ពុជា | តាកែវ | |
| ១១៥ | ឯកឧត្តម ប្រាក់ ធុច | ប្រជាជនកម្ពុជា | តាកែវ | ជំនួស ឯ.ឧ ម៉ុក ម៉ារ៉េត ០៩.១០.០៨ |
| ១១៦ | ឯកឧត្តម ចៅ សុផុន | ប្រជាជនកម្ពុជា | តាកែវ | ជំនួស ឯ.ឧ សួរ យុន ០៩.១០.០៨ |
| ១១៧ | លោកជំទាវ យាន ហុនលី | ប្រជាជនកម្ពុជា | តាកែវ | ជំនួស ឯ.ឧ ច័ន្ទ សារុន ០៩.១០.០៨ |
| ១១៨ | ឯកឧត្តម អ៊ុំ សុខន | ប្រជាជនកម្ពុជា | តាកែវ | ជំនួស ឯ.ឧ អ៊ឹង ប៊ុនហ៊ួវ ០៩.១០.០៨ |
| ១១៩ | ឯកឧត្តម គួយ ប៊ុនរឿន | សម រង្ស៊ី | តាកែវ | |
| ១២០ | ឯកឧត្តម តុ វ៉ាន់ចាន់ | សម រង្ស៊ី | តាកែវ | |
| ១២១ | ឯកឧត្តម អាន ហេ | ប្រជាជនកម្ពុជា | ក្រុងកែប | ជំនួស ឯ.ឧ ចម ប្រសិទ្ធ ១០.១០.០៨ |
| ១២២ | ឯកឧត្តម អ៊ិចសារូ | ប្រជាជនកម្ពុជា | ប៉ៃលិន | ជំនួស ឯ.ឧ អ៊ី ឈាន<br>ជំនួស ឯ.ឧ សំ សាន ០៨.១២.០៨ |
| ១២៣ | ឯកឧត្តម នៅ សំ | ប្រជាជនកម្ពុជា | ឧត្តរមានជ័យ | |

## ច.៧. រដ្ឋសភានីតិកាលទី៥




រដ្ឋសភានីតិកាលទី៥

❖ រដ្ឋសភា នីតិកាលទី៥ កើតចេញពីការបោះឆ្នោតសកល កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣ តាមប្រព័ន្ធសមាមាត្រ មាន ២៤ រាជធានី.ខេត្ត ជាមណ្ឌលបោះឆ្នោត ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន ៨ ។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភាចំនួន២

- គណបក្សប្រជាជនកម្ពុជា : ៦៨ អាសនៈ
- គណបក្សសង្គ្រោះជាតិ : ៥៥ អាសនៈ

**តំណាងរាស្ត្រសរុបចំនួន ១២៣ រូប ក្នុងនោះស្ត្រីចំនួន ២៥ រូប ស្មើនឹង ២០,១៣%** ដែលមានរាយនាមដូចតទៅៈ

| ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ | មណ្ឌល | ផ្សេងៗ |
|---|---|---|---|---|
| ១ | ឯកឧត្តម កែ គឹមយ៉ាន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ២ | ឯកឧត្តម យឹម ឆៃលី | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៣ | ឯកឧត្តម ប៉ាល់ សំអឿន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៤ | លោកជំទាវ នួម សុភ័ណ | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៥ | ឯកឧត្តម ឡុង រី | សង្គ្រោះជាតិ | បន្ទាយមានជ័យ | |
| ៦ | ឯកឧត្តម យន្ត ថារូ | សង្គ្រោះជាតិ | បន្ទាយមានជ័យ | |
| ៧ | សម្តេចក្រឡាហោម ស ខេង | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៨ | ឯកឧត្តម ងិន ឃន | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៩ | លោកជំទាវ លី គឹមលៀង | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១០ | ឯកឧត្តម ឈាង វុន | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១១ | ឯកឧត្តម ឡោក ហ៊ួរ | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១២ | លោកជំទាវ មួរ សុខហួរ | សង្គ្រោះជាតិ | បាត់ដំបង | |
| ១៣ | ឯកឧត្តម ឡុង ប៊ុត្តា | សង្គ្រោះជាតិ | បាត់ដំបង | |
| ១៤ | ឯកឧត្តម ពិន រតនា | សង្គ្រោះជាតិ | បាត់ដំបង | |
| ១៥ | ឯកឧត្តម សម រង្ស៊ី | សង្គ្រោះជាតិ | កំពង់ចាម | |
| ១៦ | ឯកឧត្តម កឹម សុខា | សង្គ្រោះជាតិ | កំពង់ចាម | |
| ១៧ | ឯកឧត្តម ម៉ៅ មុនីវណ្ណ | សង្គ្រោះជាតិ | កំពង់ចាម | |
| ១៨ | ឯកឧត្តម វ៉ាន់ ណារិទ្ធ | សង្គ្រោះជាតិ | កំពង់ចាម | |
| ១៩ | ឯកឧត្តម ទួន យក់ដា | សង្គ្រោះជាតិ | កំពង់ចាម | |
| ២០ | ឯកឧត្តម គីមសួរ ភិរិទ្ធ | សង្គ្រោះជាតិ | កំពង់ចាម | |
| ២១ | ឯកឧត្តម អ៊ុច សេរីយុទ្ធ | សង្គ្រោះជាតិ | កំពង់ចាម | |
| ២២ | ឯកឧត្តម ញ៉ុយ ចំរើន | សង្គ្រោះជាតិ | កំពង់ចាម | |
| ២៣ | ឯកឧត្តម ជីវ កត្តា | សង្គ្រោះជាតិ | កំពង់ចាម | |
| ២៤ | ឯកឧត្តម កង គឹមហាក់ | សង្គ្រោះជាតិ | កំពង់ចាម | |

| | | | |
|---|---|---|---|
| ២៥ | សម្តេចអគ្គមហាពញាចក្រី ហេង សំរិន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៦ | ឯកឧត្តម ហោ ណាំហុង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៧ | ឯកឧត្តម ហ៊ុន ណេង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៨ | ឯកឧត្តម អ៊ឹម សិទ្ធី | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៩ | ឯកឧត្តម ចាយ បូរិន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ៣០ | ឯកឧត្តម កែវ ពិសិដ្ឋ | ប្រជាជនកម្ពុជា | កំពង់ចាម |
| ៣១ | ឯកឧត្តម ង្វៀន ស៊ីមអាន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ៣២ | ឯកឧត្តម ម៉ែន កួន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ៣៣ | សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតី ស្រីង្គារ គង់ សំអុល | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |
| ៣៤ | លោកជំទាវ កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |
| ៣៥ | ឯកឧត្តម គី វណ្ណដារ៉ា | សង្គ្រោះជាតិ | កំពង់ឆ្នាំង |
| ៣៦ | ឯកឧត្តម ង៉ោ គីមជាង | សង្គ្រោះជាតិ | កំពង់ឆ្នាំង |
| ៣៧ | ឯកឧត្តម ប៉ែន សុវណ្ណ | សង្គ្រោះជាតិ | កំពង់ស្ពឺ |
| ៣៨ | ឯកឧត្តម នុត រំដួល | សង្គ្រោះជាតិ | កំពង់ស្ពឺ |
| ៣៩ | ឯកឧត្តម សុខ អ៊ុំស៊ា | សង្គ្រោះជាតិ | កំពង់ស្ពឺ |
| ៤០ | ឯកឧត្តម សត្យា វុធ | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤១ | ឯកឧត្តម ហ៊ុន ម៉ានី | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤២ | ឯកឧត្តម ហែម ខន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤៣ | ឯកឧត្តមបណ្ឌិត ង្វៀន ញ៉ិល | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៤ | ឯកឧត្តម ញ៉ែម ថ្លាវី | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៥ | ឯកឧត្តម ជា អឿង | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៦ | ឯកឧត្តម ម៉ែន សុថាវិទ្រ | សង្គ្រោះជាតិ | កំពង់ធំ |
| ៤៧ | ឯកឧត្តម ជាម ច័ន្ទនី | សង្គ្រោះជាតិ | កំពង់ធំ |
| ៤៨ | ឯកឧត្តម លិម គិមយ៉ា | សង្គ្រោះជាតិ | កំពង់ធំ |
| ៤៩ | ឯកឧត្តម សោម ចិន | ប្រជាជនកម្ពុជា | កំពត |

| | | | |
|---|---|---|---|
| ៥០ | ឯកឧត្តម នឹម ច័ន្ទតារា | ប្រជាជនកម្ពុជា | កំពត |
| ៥១ | លោកជំទាវ អ៊ិន សុគន្ធា | ប្រជាជនកម្ពុជា | កំពត |
| ៥២ | ឯកឧត្តម ជា ប៉ូច | សង្គ្រោះជាតិ | កំពត |
| ៥៣ | ឯកឧត្តម លឹម ប៊ុនស៊ីដារ៉េត | សង្គ្រោះជាតិ | កំពត |
| ៥៤ | ឯកឧត្តម ដាន ចំរើន | សង្គ្រោះជាតិ | កំពត |
| ៥៥ | ឯកឧត្តម អេង ឆៃអ៊ាង | សង្គ្រោះជាតិ | កណ្តាល |
| ៥៦ | ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ | សង្គ្រោះជាតិ | កណ្តាល |
| ៥៧ | ឯកឧត្តម ចាន់ ចេង | សង្គ្រោះជាតិ | កណ្តាល |
| ៥៨ | ឯកឧត្តម តុ វ៉ាន់ចាន់ | សង្គ្រោះជាតិ | កណ្តាល |
| ៥៩ | លោកជំទាវ ពត ពៅ | សង្គ្រោះជាតិ | កណ្តាល |
| ៦០ | លោកជំទាវ តៃ ច័ន្ទមនី | សង្គ្រោះជាតិ | កណ្តាល |
| ៦១ | សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន | ប្រជាជនកម្ពុជា | កណ្តាល |
| ៦២ | លោកជំទាវ ឃួន សុដារី | ប្រជាជនកម្ពុជា | កណ្តាល |
| ៦៣ | ឯកឧត្តម ម៉ុម ជឹមហ៊ុយ | ប្រជាជនកម្ពុជា | កណ្តាល |
| ៦៤ | លោកជំទាវ ហូ ណួន | ប្រជាជនកម្ពុជា | កណ្តាល |
| ៦៥ | ឯកឧត្តមបណ្ឌិត ឈុន ស៊ីរុន | ប្រជាជនកម្ពុជា | កណ្តាល |
| ៦៦ | ឯកឧត្តម អាយ ខន | ប្រជាជនកម្ពុជា | កោះកុង |
| ៦៧ | លោកជំទាវ ត្រឹង ថាវី | ប្រជាជនកម្ពុជា | ក្រចេះ |
| ៦៨ | លោកជំទាវ ស៊ុន សាភឿន | ប្រជាជនកម្ពុជា | ក្រចេះ |
| ៦៩ | ឯកឧត្តម កែវ គីរម្យ | សង្គ្រោះជាតិ | ក្រចេះ |
| ៧០ | ឯកឧត្តម ចាន់ យឿន | ប្រជាជនកម្ពុជា | មណ្ឌលគិរី |
| ៧១ | លោកជំទាវ ដូឡុង សូម្ហ៉ា | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |
| ៧២ | ឯកឧត្តម យឹម សុវណ្ណ | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |
| ៧៣ | ឯកឧត្តម សុន ឆ័យ | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |
| ៧៤ | ឯកឧត្តម ហូរ វ៉ាន់ | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៧៥ | ឯកឧត្តម កែវ សម្បត្តិ | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |
| ៧៦ | លោកជំទាវ លី ស្រីវីណា | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |
| ៧៧ | ឯកឧត្តម ដាំ សិទ្ធិ | សង្គ្រោះជាតិ | រាជធានីភ្នំពេញ |
| ៧៨ | ឯកឧត្តម គាត ឈន់ | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៩ | ឯកឧត្តម កែប ជុតិមា | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៨០ | ឯកឧត្តម ហ៊ូ ស្រ៊ី | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៨១ | លោកជំទាវ គ្រួច សំអាន | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៨២ | លោកជំទាវ ឡោក ខេង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៨៣ | ឯកឧត្តម សួស យ៉ារ៉ា | ប្រជាជនកម្ពុជា | ព្រះវិហារ |
| ៨៤ | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | សង្គ្រោះជាតិ | ព្រៃវែង |
| ៨៥ | ឯកឧត្តម ហេង ដាណារ៉ូ | សង្គ្រោះជាតិ | ព្រៃវែង |
| ៨៦ | ឯកឧត្តម គង់ បូរ៉ា | សង្គ្រោះជាតិ | ព្រៃវែង |
| ៨៧ | ឯកឧត្តម ទួត យឿត | សង្គ្រោះជាតិ | ព្រៃវែង |
| ៨៨ | ឯកឧត្តម ឡាត់ លិតេយ្យ | សង្គ្រោះជាតិ | ព្រៃវែង |
| ៨៩ | ឯកឧត្តម ឡុង ប៊ុន្នី | សង្គ្រោះជាតិ | ព្រៃវែង |
| ៩០ | ឯកឧត្តម ប៊ិន ឈិន | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩១ | ឯកឧត្តមបណ្ឌិតវេជ្ជ ជាម យៀប | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩២ | ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩៣ | ឯកឧត្តម ស សុខា | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩៤ | ឯកឧត្តម សុខ ឥសាន | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩៥ | ឯកឧត្តម តាន់ គឹមវិន | ប្រជាជនកម្ពុជា | ពោធិ៍សាត់ |
| ៩៦ | លោកជំទាវ ឯម ប៉ុណ្ណា | ប្រជាជនកម្ពុជា | ពោធិ៍សាត់ |
| ៩៧ | ឯកឧត្តម សារី កោសល្យ | ប្រជាជនកម្ពុជា | ពោធិ៍សាត់ |
| ៩៨ | ឯកឧត្តម ងឹម ញ៉េង | សង្គ្រោះជាតិ | ពោធិ៍សាត់ |
| ៩៩ | ឯកឧត្តម ប៊ូ ឡាំ | ប្រជាជនកម្ពុជា | រតនគិរី |

| | | | |
|---|---|---|---|
| ១០០ | សម្ដេចពិជ័យសេនា ទៀ បាញ់ | ប្រជាជនកម្ពុជា | សៀមរាប |
| ១០១ | ឯកឧត្ដម សៀង ណាំ | ប្រជាជនកម្ពុជា | សៀមរាប |
| ១០២ | ឯកឧត្ដម ឈឹម ម៉ា | ប្រជាជនកម្ពុជា | សៀមរាប |
| ១០៣ | លោកជំទាវ ពៅ សាវឿន | ប្រជាជនកម្ពុជា | សៀមរាប |
| ១០៤ | លោកជំទាវ កែ សុវណ្ណរតន៍ | សង្គ្រោះជាតិ | សៀមរាប |
| ១០៥ | ឯកឧត្ដម អ៊ុំ សំអាន | សង្គ្រោះជាតិ | សៀមរាប |
| ១០៦ | ឯកឧត្ដម ចេវ គឹមហេង | ប្រជាជនកម្ពុជា | ព្រះសីហនុ |
| ១០៧ | ឯកឧត្ដម ឡូយ សុផាត | ប្រជាជនកម្ពុជា | ស្ទឹងត្រែង |
| ១០៨ | លោកជំទាវ ម៉ែន សំអន | ប្រជាជនកម្ពុជា | ស្វាយរៀង |
| ១០៩ | លោកជំទាវ ឈុន សារឹម | ប្រជាជនកម្ពុជា | ស្វាយរៀង |
| ១១០ | លោកជំទាវ ដួង វណ្ណា | ប្រជាជនកម្ពុជា | ស្វាយរៀង |
| ១១១ | ឯកឧត្ដម វៀល ខេមរិន្ទ្រ | សង្គ្រោះជាតិ | ស្វាយរៀង |
| ១១២ | ឯកឧត្ដម គង់ សភា | សង្គ្រោះជាតិ | ស្វាយរៀង |
| ១១៣ | ឯកឧត្ដម សុខ អាន | ប្រជាជនកម្ពុជា | តាកែវ |
| ១១៤ | លោកជំទាវ និន សាផុន | ប្រជាជនកម្ពុជា | តាកែវ |
| ១១៥ | ឯកឧត្ដមបណ្ឌិត ម៉ុក ម៉ារ៉េត | ប្រជាជនកម្ពុជា | តាកែវ |
| ១១៦ | ឯកឧត្ដម សុខ សូភាន | ប្រជាជនកម្ពុជា | តាកែវ |
| ១១៧ | ឯកឧត្ដម ប៉ុល ហំម | សង្គ្រោះជាតិ | តាកែវ |
| ១១៨ | ឯកឧត្ដម ឃី វណ្ណដេត | សង្គ្រោះជាតិ | តាកែវ |
| ១១៩ | ឯកឧត្ដម អ៊ូ ច័ន្ទរ័ត្ន | សង្គ្រោះជាតិ | តាកែវ |
| ១២០ | លោកជំទាវ ទេព សុទ្ធី | សង្គ្រោះជាតិ | តាកែវ |
| ១២១ | ឯកឧត្ដម ងួន ប៉ឿន | ប្រជាជនកម្ពុជា | កែប |
| ១២២ | លោកជំទាវ បាន ស្រីមុំ | ប្រជាជនកម្ពុជា | ប៉ៃលិន |
| ១២៣ | ឯកឧត្ដម នៅ សំ | ប្រជាជនកម្ពុជា | ឧត្ដរមានជ័យ |

❖ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូល បានសម្រេចរំលាយគណបក្សសង្គ្រោះជាតិ និងហាមឃាត់សិទ្ធិធ្វើនយោបាយរបស់ថ្នាក់ដឹកនាំគណបក្សចំនួន ១១៨រូប តាមបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សយុវជនកម្ពុជា ។

បន្ទាប់មកអាសនៈដែលនៅទំនេរបានបែងចែកជូនទៅគណបក្សនយោបាយដែលបានចូលរួមឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣ ស្របតាមសេចក្តីសម្រេចរបស់ គ.ជ.ប និងស្របតាមច្បាប់ជាធរមាន ។

គណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភា ចំនួន៤

- គណបក្សប្រជាជនកម្ពុជា : ៧៩ អាសនៈ
- គណបក្សហ៊្វុនស៊ិនប៉ិច : ៤១អាសនៈ
- គណបក្សសញ្ជាតិកម្ពុជា : ២អាសនៈ
- គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច : ១អាសនៈ

តំណាងរាស្ត្រសរុបចំនួន :១២៣រូប ដែលមានរាយនាមដូចទៅៈ

| ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ | មណ្ឌល | ផ្សេងៗ |
|---|---|---|---|---|
| ១ | ឯកឧត្តម កែ គឹមយ៉ាន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ២ | ឯកឧត្តម យឹម ឆៃលី | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៣ | ឯកឧត្តម ប៉ាល់ សំអឿន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៤ | លោកជំទាវ នួម សុភ័ណ | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៥ | ឯកឧត្តម ហេង ចាន់ថា | ហ៊្វុនស៊ិនប៉ិច | បន្ទាយមានជ័យ | |
| ៦ | ឯកឧត្តម ផន ចន្ថា | ហ៊្វុនស៊ិនប៉ិច | បន្ទាយមានជ័យ | |
| ៧ | សម្តេចក្រឡាហោម ស ខេង | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៨ | ឯកឧត្តម ងិន ឃន | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៩ | លោកជំទាវ លី គឹមលៀង | ប្រជាជនកម្ពុជា | បាត់ដំបង | |

| | | | |
|---|---|---|---|
| ១០ | ឯកឧត្តម ឈាង វុន | ប្រជាជនកម្ពុជា | បាត់ដំបង |
| ១១ | ឯកឧត្តម ឡោក ហ៊ួរ | ប្រជាជនកម្ពុជា | បាត់ដំបង |
| ១២ | ឯកឧត្តម សៀង ស៊ុតថង | ប្រជាជនកម្ពុជា | បាត់ដំបង |
| ១៣ | ឯកឧត្តម ញ៉ែប ប៊ុនជិន | ហ្វ៊ុនស៊ិនប៉ិច | បាត់ដំបង |
| ១៤ | ឯកឧត្តម អ៊ូ ឡុងឌី | ហ្វ៊ុនស៊ិនប៉ិច | បាត់ដំបង |
| ១៥ | សម្តេចអគ្គមហាពញាចក្រី ហេង សំរិន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៦ | ឯកឧត្តម ហោ ណាំហុង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៧ | ឯកឧត្តម ហ៊ុន ណេង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៨ | ឯកឧត្តម យិន ប៊ុនណាង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៩ | ឯកឧត្តម ចាយ បូរិន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២០ | ឯកឧត្តម កែវ ពិសិដ្ឋ | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២១ | ឯកឧត្តម ង៉ួន ស៊ីមអាន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២២ | ឯកឧត្តម ម៉ែន កួន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៣ | ឯកឧត្តម អ៊ី សំអុល | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៤ | ឯកឧត្តម ម៉ា ឈឿន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៥ | លោកជំទាវ ខុង ស៊ុនអេង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៦ | សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | ហ្វ៊ុនស៊ិនប៉ិច | កំពង់ចាម |
| ២៧ | ឯកឧត្តម យូ ហុកគ្រី | ហ្វ៊ុនស៊ិនប៉ិច | កំពង់ចាម |
| ២៨ | ឯកឧត្តម ខាត់ ទីន | ហ្វ៊ុនស៊ិនប៉ិច | កំពង់ចាម |
| ២៩ | ឯកឧត្តម យ៉ង់ សារីម | ហ្វ៊ុនស៊ិនប៉ិច | កំពង់ចាម |
| ៣០ | ឯកឧត្តម ហុង ប៊ុនហ៊ាង | ហ្វ៊ុនស៊ិនប៉ិច | កំពង់ចាម |
| ៣១ | ឯកឧត្តម យិម រឿនថន | ហ្វ៊ុនស៊ិនប៉ិច | កំពង់ចាម |
| ៣២ | ឯកឧត្តម សេង សុខេង | សញ្ជាតិកម្ពុជា | កំពង់ចាម |
| ៣៣ | សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតី ស្រីង្គារ គង់ សំអុល | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |

| | | | |
|---|---|---|---|
| ៣៤ | លោកជំទាវ កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |
| ៣៥ | ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី | ហ៊្វុនស៊ិនប៉ិច | កំពង់ឆ្នាំង |
| ៣៦ | ឯកឧត្តម អ៊ុក ខុត | ហ៊្វុនស៊ិនប៉ិច | កំពង់ឆ្នាំង |
| ៣៧ | ឯកឧត្តម ហ៊ុន ម៉ានី | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៣៨ | ឯកឧត្តម សត្យា វុធ | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៣៩ | ឯកឧត្តម សុក ប៊ិន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤០ | ឯកឧត្តម ពៅ អៀងត្រី | ហ៊្វុនស៊ិនប៉ិច | កំពង់ស្ពឺ |
| ៤១ | ឯកឧត្តម សោម ណារិទ្ធ | ហ៊្វុនស៊ិនប៉ិច | កំពង់ស្ពឺ |
| ៤២ | ឯកឧត្តម ឡុង ឫទ្ធីយ៉ា | ហ៊្វុនស៊ិនប៉ិច | កំពង់ស្ពឺ |
| ៤៣ | ឯកឧត្តមបណ្ឌិត ង៉ួន ញ៉ិល | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៤ | ឯកឧត្តម ញ៉ែម ថ្ការី | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៥ | ឯកឧត្តម ជា អៀង | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៦ | ឯកឧត្តម នាង ចាន់ណាក់ | ហ៊្វុនស៊ិនប៉ិច | កំពង់ធំ |
| ៤៧ | ឯកឧត្តម ស៊ិន់ សេក | ហ៊្វុនស៊ិនប៉ិច | កំពង់ធំ |
| ៤៨ | ឯកឧត្តម ប៊ុន ណារ៉ែន | ហ៊្វុនស៊ិនប៉ិច | កំពង់ធំ |
| ៤៩ | ឯកឧត្តម សោម ចិន | ប្រជាជនកម្ពុជា | កំពត |
| ៥០ | ឯកឧត្តម នឹម ច័ន្ទតារា | ប្រជាជនកម្ពុជា | កំពត |
| ៥១ | លោកជំទាវ អ៊ុន សុគន្ធា | ប្រជាជនកម្ពុជា | កំពត |
| ៥២ | ឯកឧត្តម សៅ រ៉ានី | ហ៊្វុនស៊ិនប៉ិច | កំពត |
| ៥៣ | ឯកឧត្តម កៅ ល្អប្រពៃ | ហ៊្វុនស៊ិនប៉ិច | កំពត |
| ៥៤ | ឯកឧត្តម ទេព វាសនា | ហ៊្វុនស៊ិនប៉ិច | កំពត |
| ៥៥ | សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ប្រជាជនកម្ពុជា | កណ្តាល |
| ៥៦ | លោកជំទាវ ឃួន សុដារី | ប្រជាជនកម្ពុជា | កណ្តាល |
| ៥៧ | ឯកឧត្តម អ៊ុក ដាមរី | ប្រជាជនកម្ពុជា | កណ្តាល |

| | | | |
|---|---|---|---|
| ៥៨ | លោកជំទាវ ហូ ណូន | ប្រជាជនកម្ពុជា | កណ្ដាល |
| ៥៩ | ឯកឧត្តមបណ្ឌិត ឈុន ស៊ីរុន | ប្រជាជនកម្ពុជា | កណ្ដាល |
| ៦០ | ឯកឧត្តម វ៉ាន សំអឿន | ប្រជាជនកម្ពុជា | កណ្ដាល |
| ៦១ | ឯកឧត្តម គោស៊ុំ សារឿត | ប្រជាជនកម្ពុជា | កណ្ដាល |
| ៦២ | ឯកឧត្តម ច័ន្ទ នរ៉ា | ហ៊្វុនស៊ិនប៉ិច | កណ្ដាល |
| ៦៣ | ឯកឧត្តម យ៉ាន់ សោគុណ | ហ៊្វុនស៊ិនប៉ិច | កណ្ដាល |
| ៦៤ | ឯកឧត្តម អាំង សំបូរ | ហ៊្វុនស៊ិនប៉ិច | កណ្ដាល |
| ៦៥ | ឯកឧត្តម ហួន រាជចំរើន | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | កណ្ដាល |
| ៦៦ | ឯកឧត្តម ជុំ យុហៀន | ប្រជាជនកម្ពុជា | កោះកុង |
| ៦៧ | លោកជំទាវ ត្រឹង ថាវី | ប្រជាជនកម្ពុជា | ក្រចេះ |
| ៦៨ | លោកជំទាវ ស៊ុន សាភឿន | ប្រជាជនកម្ពុជា | ក្រចេះ |
| ៦៩ | ឯកឧត្តម វ៉ោន សាហាក់ | ហ៊្វុនស៊ិនប៉ិច | ក្រចេះ |
| ៧០ | ឯកឧត្តម ចាន់ យឿន | ប្រជាជនកម្ពុជា | មណ្ឌលគិរី |
| ៧១ | ឯកឧត្តម គាត ឈន់ | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧២ | ឯកឧត្តម កែប ជុតិមា | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៣ | ឯកឧត្តម ហ៊ូ ស្រ៊ី | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៤ | លោកជំទាវ គ្រួច សំអាន | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៥ | លោកជំទាវ ឡោក ខេង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៦ | ឯកឧត្តម ជៀប ស៊ីវន | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៧ | ឯកឧត្តម ពេជ្រ គឹមស្រ៊ាង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៨ | ឯកឧត្តម លី ឆេង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ |
| ៧៩ | ឯកឧត្តម ធឹង ចំរើន | ហ៊្វុនស៊ិនប៉ិច | រាជធានីភ្នំពេញ |
| ៨០ | ឯកឧត្តម ផាន់ សិទ្ធី | ហ៊្វុនស៊ិនប៉ិច | រាជធានីភ្នំពេញ |
| ៨១ | លោកជំទាវ កង បូរាណ | ហ៊្វុនស៊ិនប៉ិច | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៨២ | ឯកឧត្តម សុខ ច័ន្ទក្រិស្ណា | ហ្វ៊ុនស៊ិនប៉ិច | រាជធានីភ្នំពេញ |
| ៨៣ | ឯកឧត្តម សួស យ៉ារ៉ា | ប្រជាជនកម្ពុជា | ព្រះវិហារ |
| ៨៤ | ឯកឧត្តម ប៊ិន ឈិន | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៨៥ | ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៨៦ | ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៨៧ | ឯកឧត្តម ស សុខា | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៨៨ | ឯកឧត្តម ពៅ សាមី | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៨៩ | ឯកឧត្តម ឡុង ប៊ុន្នី | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩០ | ឯកឧត្តម ម៉ុម ស៊ីប៊ុន | ប្រជាជនកម្ពុជា | ព្រៃវែង |
| ៩១ | ឯកឧត្តម សាយ ហាក់ | ហ្វ៊ុនស៊ិនប៉ិច | ព្រៃវែង |
| ៩២ | ឯកឧត្តម រស់ សាផន | ហ្វ៊ុនស៊ិនប៉ិច | ព្រៃវែង |
| ៩៣ | ឯកឧត្តម ថាវ គឹមឡុង | ហ្វ៊ុនស៊ិនប៉ិច | ព្រៃវែង |
| ៩៤ | ឯកឧត្តម គង្គ សាវ៉ែន | សញ្ញាតិកម្ពុជា | ព្រៃវែង |
| ៩៥ | ឯកឧត្តម តាន់ គឹមវិន | ប្រជាជនកម្ពុជា | ពោធិ៍សាត់ |
| ៩៦ | លោកជំទាវ ឯម ប៉ុណ្ណា | ប្រជាជនកម្ពុជា | ពោធិ៍សាត់ |
| ៩៧ | ឯកឧត្តម សារី កោសល្យ | ប្រជាជនកម្ពុជា | ពោធិ៍សាត់ |
| ៩៨ | ឯកឧត្តម អ៊ា ឃីម៉េង | ហ្វ៊ុនស៊ិនប៉ិច | ពោធិ៍សាត់ |
| ៩៩ | ឯកឧត្តម ប៊ូ ឡាំ | ប្រជាជនកម្ពុជា | រតនគិរី |
| ១០០ | សម្តេចពិជ័យសេនា ទៀ បាញ់ | ប្រជាជនកម្ពុជា | សៀមរាប |
| ១០១ | ឯកឧត្តម សៀង ណាំ | ប្រជាជនកម្ពុជា | សៀមរាប |
| ១០២ | ឯកឧត្តម ឈឹម ម៉ា | ប្រជាជនកម្ពុជា | សៀមរាប |
| ១០៣ | លោកជំទាវ ពៅ សារឿន | ប្រជាជនកម្ពុជា | សៀមរាប |
| ១០៤ | ឯកឧត្តម យឹម សារី | ហ្វ៊ុនស៊ិនប៉ិច | សៀមរាប |
| ១០៥ | ឯកឧត្តម រ៉ាន់ សុផាន់ណា | ហ្វ៊ុនស៊ិនប៉ិច | សៀមរាប |

| | | | |
|---|---|---|---|
| ១០៦ | ឯកឧត្តម ចេវ គឹមហេង | ប្រជាជនកម្ពុជា | ព្រះសីហនុ |
| ១០៧ | ឯកឧត្តម ឡូយ សុផាត | ប្រជាជនកម្ពុជា | ស្ទឹងត្រែង |
| ១០៨ | លោកជំទាវ ម៉ែន សំអន | ប្រជាជនកម្ពុជា | ស្វាយរៀង |
| ១០៩ | លោកជំទាវ ឈុន សារឹម | ប្រជាជនកម្ពុជា | ស្វាយរៀង |
| ១១០ | លោកជំទាវ ដួង វណ្ណា | ប្រជាជនកម្ពុជា | ស្វាយរៀង |
| ១១១ | ឯកឧត្តម យោគ ស៊ីថុន | ហ៊្វុនស៊ិនប៉ិច | ស្វាយរៀង |
| ១១២ | ឯកឧត្តម ឈឿន តៃមួយ | ហ៊្វុនស៊ិនប៉ិច | ស្វាយរៀង |
| ១១៣ | ឯកឧត្តម ជា វ៉ាន់ដេត | ប្រជាជនកម្ពុជា | តាកែវ |
| ១១៤ | លោកជំទាវ និន សាផុន | ប្រជាជនកម្ពុជា | តាកែវ |
| ១១៥ | ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត | ប្រជាជនកម្ពុជា | តាកែវ |
| ១១៦ | ឯកឧត្តម សុខ សូកាន | ប្រជាជនកម្ពុជា | តាកែវ |
| ១១៧ | ឯកឧត្តម ចាប ញ៉ាលីវុធ | ហ៊្វុនស៊ិនប៉ិច | តាកែវ |
| ១១៨ | ឯកឧត្តម គីង សំណាង | ហ៊្វុនស៊ិនប៉ិច | តាកែវ |
| ១១៩ | ឯកឧត្តម អ៊ី ជឿន | ហ៊្វុនស៊ិនប៉ិច | តាកែវ |
| ១២០ | ឯកឧត្តម សំ វុឌ្ឍី | ហ៊្វុនស៊ិនប៉ិច | តាកែវ |
| ១២១ | ឯកឧត្តម ង៉ួន ប៉ឿន | ប្រជាជនកម្ពុជា | កែប |
| ១២២ | លោកជំទាវ បាន ស្រីមុំ | ប្រជាជនកម្ពុជា | ប៉ៃលិន |
| ១២៣ | ឯកឧត្តម នៅ សំ | ប្រជាជនកម្ពុជា | ឧត្តរមានជ័យ |

## ២. ប្រវត្តិរបស់ព្រឹទ្ធសភា

ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅ នៃការគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារ បណ្តាប្រទេសជាច្រើននៅលើសកលលោកបានជ្រើសយកការអនុវត្តរបបសភាតាមបែបទ្វិសភា ដោយស្ថាប័ននីតិប្បញ្ញត្តិចែកចេញជាពីរ ដែលជាជម្រើសមួយជួយឲ្យដំណើរការគ្រប់គ្រងរដ្ឋប្រព្រឹត្តទៅបានល្អប្រពៃ និងមានតម្លាភាព ព្រោះថា ការមានសភាពីរនឹងជួយជំរុញឱ្យការផលិតច្បាប់បានច្រើន ហើយការពិនិត្យ និងអនុម័តមានភាពរលូនល្អិតល្អន់ និងមានប្រសិទ្ធភាពក្នុងការអនុវត្ត ជាកត្តានាំឲ្យប្រទេសឈានឆ្ពោះទៅកាន់នីតិរដ្ឋ។

ការអនុវត្តប្រព័ន្ធទ្វិសភានៅលើសកលលោក មានការវិវត្តរីកចម្រើនជាលំដាប់។ ប្រព័ន្ធទ្វិសភានេះ ត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជាដំបូងតាំងពីឆ្នាំ១៩៤៧ ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី១ និងត្រូវបានបន្តអនុវត្តក្នុងរបបសាធារណរដ្ឋខ្មែរ។ បន្ទាប់ពីនោះមក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា ប្តូរមកអនុវត្តប្រព័ន្ធសភាទោលដែលបានបន្តអនុវត្តដល់ព្រះរាជាណាចក្រកម្ពុជាទី២ ពីឆ្នាំ១៩៩៣ ដល់ខែមីនា ឆ្នាំ១៩៩៩។

### ២.១. ក្រុមប្រឹក្សាព្រះរាជអាណាចក្រ

រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧ កំណត់ឲ្យមានស្ថាប័ននីតិប្បញ្ញត្តិពីរ គឺរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ។ មាត្រា៧៨ នៃរដ្ឋធម្មនុញ្ញនេះ បញ្ញត្តិឲ្យក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានតួនាទីជាអង្គការនីតិប្បញ្ញត្តិដូចរដ្ឋសភាដែរ គឺមានសិទ្ធិក្នុងការពិនិត្យ ហើយឲ្យយោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋាភិបាលដាក់ឲ្យពិនិត្យ។ ទន្ទឹមនេះ ក្រុមប្រឹក្សាព្រះរាជអាណាចក្រមានភារកិច្ចជួយសម្អាតការងាររាជការ (សកម្មភាពរដ្ឋបាល) ដែលភារកិច្ចនេះ ត្រូវបានលុបដោយព្រះរាជក្រមលេខ: ១៦៦ បរ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦៤ ដោយប្រគល់ភារកិច្ចនេះជូនទៅតុលាការប្រជាជនវិញ។

សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវមានអាយុយ៉ាងតិច ៤០ឆ្នាំ ត្រូវបានចាត់តាំងខ្លះ និងជ្រើសតាំងដោយការបោះឆ្នោតជាសកលខ្លះ។ សមាជិក០២រូប ត្រូវបានព្រះមហាក្សត្រីយ៍ទ្រង់ចាត់តាំងក្នុងបណ្តាព្រះរាជវង្សានុវង្ស ០២រូប ត្រូវជ្រើសតាំងដោយរដ្ឋសភាតាមសំឡេងភាគច្រើនដោយប្រៀប ១០រូបជាអតិបរមាត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល និង

មិនចំពោះជាអ្នកតំណាងភូមិភាគមួយ ឬក្រុងភ្នំពេញ និង១០រូបជាអតិបរមាទៀតជាអ្នកតំណាងវិជ្ជាជីវៈផ្សេងៗត្រូវជ្រើសតាំងដោយការបោះឆ្នោតចំពោះ។

ល័ក្ខខ័ណ្ឌស្តីពីការបោះឆ្នោត ត្រូវសម្រេចទៅតាមអត្ថបទច្បាប់មួយ។ ដោយឡែកបែបផែននៃការចាត់តាំង និងការជ្រើសតាំងសមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រនឹងមានកំណត់ក្នុងច្បាប់ពិសេសមួយ ហើយអាណត្តិនៃក្រុមប្រឹក្សានេះមានរយៈពេល ៤ឆ្នាំ។ មុខងារជាទីប្រឹក្សាព្រះរាជអាណាចក្រ មានវិសមិតភាពជាមួយនឹងមុខងារជាតំណាងរាស្ត្រ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវកោះប្រជុំលើកដំបូង ក្នុងពេលជាមួយគ្នានឹងរដ្ឋសភាដែរ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានសមាជិកចំនួន២៤រូប ដឹកនាំដោយក្រុមអភិបាលមួយដែលមានសមាសភាពចំនួន ០៤រូប។ ក្រុមប្រឹក្សាភិបាលនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រកម្ពុជា ដែលបានចាប់បដិសន្ធិឡើងនៅដើមឆ្នាំ១៩៤៨ មាន**ឯកឧត្តម ឃួន ណៃ** ជាប្រធាន **ឯកឧត្តម ជុំ ទួត** ជាអនុប្រធាន **ឯកឧត្តម យឹម សំ** ជាលេខាធិការ និង**ឯកឧត្តម ម៉ីនសី**។ ការជ្រើសរើសក្រុមប្រឹក្សាភិបាលនេះ បានធ្វើឡើងក្នុងអង្គប្រជុំនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រពេលប្រជុំលើកទី២ នាថ្ងៃចន្ទ ទី៩ ខែកុម្ភៈ ឆ្នាំ១៩៤៨ ដែលមាន **ឯកឧត្តម កែប នួន** ជាប្រធានបណ្តោះអាសន្ន។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មាន៤គណៈកម្មការគឺៈ

១. គណៈកម្មការហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសាធារណការ

២. គណៈកម្មការយុត្តិធម៌ និងរដ្ឋធម្មនុញ្ញ

៣. គណៈកម្មការមហាផ្ទៃ ការបរទេស និងការពារប្រទេស

៤. គណៈកម្មការសិក្សាធិការ វប្បធម៌ សុខាភិបាល និងបញ្ហាសង្គម។

គណៈកម្មការនីមួយៗ មានសមាជិក ៥រូប។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានក្រុមជំនួយការមួយជាសេនាធិការផ្ទាល់ ដែលមានអគ្គលេខាធិការ ០១រូប និងនាយប៉ុយរ៉ូ ០១រូប ដែលជាអ្នកមានកម្រិតចំណេះដឹងខ្ពង់ខ្ពស់ ហើយត្រូវបានជ្រើសរើសពីខាងរាជការ ព្រមទាំងស្មៀនចំនួន ០៧រូប ជ្រើសរើសតាមរយៈការប្រឡង។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវគោរពទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័ននៗ

## ២.២.ព្រឹទ្ធសភានៃសាធារណរដ្ឋខ្មែរ

តាមច្បាប់រដ្ឋធម្មនុញ្ញលេខ: ៤២២/៧០ បរ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៧០ បានប្រកាសដាក់ប្រទេសកម្ពុជាជាសាធារណរដ្ឋខ្មែរ ដោយរក្សាទុកនូវស្ថាប័នកំពូលៗរបស់ព្រះរាជអាណាចក្រកម្ពុជាដដែល លើកលែងតែស្ថាប័នព្រះមហាក្សត្រដែលត្រូវលុបបំបាត់។ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ដែលត្រូវបានប្រកាសឲ្យប្រើតាមបញ្ញត្តិលេខ: ១៩/៧២ ប.ស.ខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ បានកំណត់ឲ្យអនុវត្តរបបសហសភា ដែលមានសភាជាតិ និងព្រឹទ្ធសភា។

បញ្ញត្តិលេខ ៤១/៧២.ប.ស.ខ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧២ ស្តីពីកិច្ចការនៃសាធារណរដ្ឋ ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី១ ០៦ឆ្នាំនៃសាធារណរដ្ឋខ្មែរ ត្រូវប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី១៧ ខែកញ្ញា ឆ្នាំ១៩៧២។ សមាជិកព្រឹទ្ធសភានៃសាធារណរដ្ឋខ្មែរមានចំនួនត្រឹម ៤០រូប ហើយត្រូវប្តូរចំនួនពាក់កណ្តាលនៅចុងឆ្នាំទី៣។ ក្នុងចំណោម ៤០រូបនេះ មាន២៤រូបតំណាងភូមិភាគនានា ០៨រូបតំណាងរដ្ឋបាលស៊ីវិល និង០៨រូបតំណាងទីប្រឹក្សាយោធពល។

ភូមិភាគនានានៃសាធារណរដ្ឋខ្មែរ និងចំនួនសមាជិកព្រឹទ្ធសភា ដែលបានជ្រើសតាំងដោយភូមិភាគនីមួយៗ ត្រូវកំណត់ដូចតទៅ៖

- ភូមិភាគពិសេស : ក្រុងភ្នំពេញ និងខេត្តកណ្តាល មានចំនួន ៥អាសនៈ
- ភូមិភាគទី១ : ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង មានចំនួន ៤អាសនៈ
- ភូមិភាគទី២ : ក្រុងកំពង់សោម ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង មានចំនួន ៤អាសនៈ
- ភូមិភាគទី៣ : ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង មានចំនួន ៤អាសនៈ
- ភូមិភាគទី៤ : ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ មានចំនួន ៤អាសនៈ

- ភូមិភាគទី៥ : ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្ត មណ្ឌលគិរី មានចំនួន ៣អាសនៈ។

ភូមិភាគនីមួយៗ ត្រូវជ្រើសតាំងសមាជិកព្រឹទ្ធសភាតាមចំនួនអាសនៈ ដែលបានកំណត់ខាងលើដោយការបោះឆ្នោតសកល ចំពោះ សម្ងាត់ និងតាមសន្ទឹកបញ្ជី។ បេក្ខជននៃសន្ទឹកបញ្ជី ដែលបានទទួលសំឡេងភាគច្រើន ត្រូវទុកជាជាប់ឆ្នោត។

ក្រុមភូមិភាគនានា និងចំនួនសមាជិកព្រឹទ្ធសភាជាតំណាងរដ្ឋបាលស៊ីវិល ដែលត្រូវជ្រើសរើស ក្នុងក្រុមភូមិភាគនីមួយៗ ត្រូវកំណត់ដូចតទៅ៖

- ក្រុមភូមិភាគពិសេស និងភូមិភាគទី១ : ចំនួន ៣អាសនៈ
- ក្រុមភូមិភាគទី២ និងភូមិភាគទី៣ : ចំនួន ៣អាសនៈ
- ក្រុមភូមិភាគទី៤ និងភូមិភាគទី៥ : ចំនួន ២អាសនៈ។

មន្ត្រី និងភ្នាក់ងាររដ្ឋបាលស៊ីវិលក្នុងសកម្មភាព នៅតាមក្រុមភូមិភាគនីមួយៗ ជ្រើសរើសសមាជិកព្រឹទ្ធសភាទៅតាមចំនួនកំណត់ខាងលើ ដោយការបោះឆ្នោតចំពោះ សម្ងាត់ និងតាមសន្ទឹកបញ្ជី។ បេក្ខជននៃសន្ទឹកបញ្ជីដែលទទួលបានសំឡេងភាគច្រើនត្រូវទុកជាជាប់ឆ្នោត។

សមាជិកព្រឹទ្ធសភា ០៨រូប ដែលត្រូវជ្រើសតាំងដោយទីប្រឹក្សាយោធពល ត្រូវជ្រើសរើសក្នុងចំណោមបេក្ខជនជាទាហាន ដោយយកសំឡេងភាគច្រើន។ ទីប្រឹក្សាយោធពលមានអធិបតីភាពពេញបរិបូណ៌ ក្នុងការសម្រេចទទួលឬមិនទទួលនូវបេក្ខជនសម្រាប់តំណាងខ្លួននៅព្រឹទ្ធសភា។ ក្នុងការសម្រេចនេះ ទីប្រឹក្សាយោធពល ត្រូវគោរពល័ក្ខខ័ណ្ឌដែលបេក្ខជនម្នាក់ៗត្រូវមាន ដើម្បីអាចឈរឈ្មោះឲ្យគេជ្រើសតាំងបាន។

អ្នកដែលមានសិទ្ធិឈរឈ្មោះឲ្យគេជ្រើសតាំងជាសមាជិកព្រឹទ្ធសភាបាន គឺពលរដ្ឋខ្មែរទាំងពីរភេទ មានអាយុយ៉ាងតិច ៤០ឆ្នាំគត់ គិតមកដល់ថ្ងៃបោះឆ្នោត ហើយដែលបានបំពេញនូវល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងបញ្ញត្តិ ស្តីពីការបោះឆ្នោតជ្រើសរើសរដ្ឋសភានីតិកាលទី១ នៃសាធារណរដ្ឋខ្មែរ។

## ២.៣. ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

តាមច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៤ មាត្រា២៦ មាត្រា២៨ មាត្រា៣០ មាត្រា៣៤ មាត្រា៤១ មាត្រា៩០ មាត្រា៩១ មាត្រា៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ បានបញ្ញត្តិបង្កើតឲ្យមានព្រឹទ្ធសភាឡើងវិញ។

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ សមាជិកព្រឹទ្ធសភាមានចំនួនយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ដែលត្រូវបានចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតជាអសកលខ្លះ ហើយអាចត្រូវបានចាត់តាំង និងជ្រើសតាំងសាជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ឆ្នាំ និងមានសញ្ជាតិខ្មែរតាំងពីកំណើត។

ការរៀបចំការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ។

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដ៏ទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

អាណត្តិនៃសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រ និងជាមួយមុខងារជាសមាជិកស្ថាប័នដ៏ទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក ព្រឹទ្ធសភាទាំងមូល។

### ក. ការចាត់តាំង និងការជ្រើសតាំងសមាជិកព្រឹទ្ធសភា

យោងមាត្រា ១៥៩ថ្មី (ពីរ មាត្រា១៥៧ថ្មី) នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ សម្រាប់នីតិកាលទី១ នៃព្រឹទ្ធសភា:

- សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប។
- ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា។
- សមាជិកដ៏ទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមសំណើ របស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែល មានអាសនៈនៅក្នុងរដ្ឋសភា។

សម្រាប់នីតិកាលទី២ និងនីតិកាលបន្តបន្ទាប់នៃព្រឹទ្ធសភា សមាជិកព្រឹទ្ធសភា ត្រូវបាន ចាត់តាំង និងជ្រើសតាំងឡើង ស្របតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យ សប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុង ករណី ដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញ។ កាលបរិច្ឆេទនៃការ បោះឆ្នោត ត្រូវកំណត់ និងប្រកាស ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។ ការគ្រប់គ្រងការបោះឆ្នោតជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និង ការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ ក្នុងមាត្រា១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ មណ្ឌលបោះឆ្នោត ត្រូវរៀបចំ និងបែងចែកជា ៨ (ប្រាំបី) ភូមិភាគ។ អាសនៈក្នុងព្រឹទ្ធសភា ដែលត្រូវបោះឆ្នោត ជ្រើសតាំង ត្រូវកំណត់ត្រឹមចំនួន ៥៨ (ហាសិបប្រាំបី) ដោយបែងចែកតាមភូមិភាគ ដូចខាងក្រោម៖

- ភូមិភាគទី ១ រាជធានីភ្នំពេញ មាន៦ (ប្រាំមួយ) អាសនៈ
- ភូមិភាគទី ២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មាន ៨ (ប្រាំបី) អាសនៈ
- ភូមិភាគទី ៣ ខេត្តកណ្ដាល មាន ៥ (ប្រាំ) អាសនៈ
- ភូមិភាគទី ៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិនមាន ១០ (ដប់) អាសនៈ
- ភូមិភាគទី ៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែបមាន ៧ (ប្រាំពីរ) អាសនៈ
- ភូមិភាគទី ៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀងមាន ៧ (ប្រាំពីរ) អាសនៈ
- ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ មាន ៩ (ប្រាំបួន) អាសនៈ
- ភូមិភាគទី ៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី មាន ៦ (ប្រាំមួយ) អាសនៈ។

អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ។

### ក១. ព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៦)

បន្ទាប់ពីទទួលបានការតែងតាំងពីព្រះមហាក្សត្រ តាមព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៣ និង នស/រកត/០៣៩៩/៤៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៩ និងព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៧០ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ក្រោមអធិបតីភាពសម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ព្រឹទ្ធសភានីតិកាលទី១ បានបើកសម័យប្រជុំលើកទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ដើម្បីជ្រើសតាំងគណៈកម្មការពិសេសទទួលបន្ទុករៀបចំសេចក្ដីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ក្នុងថ្ងៃដដែលនេះ មុនពេលចាប់ផ្ដើមការងារតាមរបៀបវារៈ ប្រធានព្រឹទ្ធសភា អនុប្រធានទាំងពីរ និងសមាជិកព្រឹទ្ធសភា បានចូលក្រាបបង្គំគាល់ព្រះមហាក្សត្រ និងធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងនៅព្រះបរមរាជវាំង។



ព្រឹទ្ធសភានីតិកាលទី១

បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី១ ត្រូវបានព្រឹទ្ធសភាអនុម័តនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ ដោយមានសំឡេងយល់ព្រមចំនួន ៥៧ សំឡេងនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ហើយត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងប្រការ២៨ ដែលមិនស្របនឹងមាត្រា ១១០ថ្មី នៃរដ្ឋធម្មនុញ្ញ។ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី១ មាន ១៦ ជំពូក ចែកជា ៨០មាត្រានេះ ត្រូវបានប្រកាសឲ្យប្រើតាមសេចក្តីសម្រេចលេខ: ០០៥/៥៩៩/ពស/សរ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៩ លើកលែងប្រការ២៨ នៃជំពូកទី១១។

នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ ព្រឹទ្ធសភាបានបន្តសម័យប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានា ហើយគណៈកម្មការនីមួយៗបានបោះឆ្នោតផ្ទៃក្នុងជ្រើសតាំងប្រធាន អនុប្រធាន និងលេខាធិការគណៈកម្មការ ស្របតាមការកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

តាមបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភានីតិកាលទី១ មាន៖

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាយន្តការដឹកនាំ ចាត់ចែង និងពិនិត្យ សម្រេចរាល់ការងារផ្សេងៗ ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុង ។ ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ អនុប្រធានទាំងពីរ និងប្រធានគណៈកម្មការនានារបស់ព្រឹទ្ធសភាជាសមាជិក ។

គណៈកម្មការនានាចំនួន០៩ ជាសេនាធិការក្នុងការអនុវត្តមុខងាររបស់ខ្លួន ដែលត្រូវបានបែងចែកទៅតាមវិស័យជាសមត្ថកិច្ច ដូចខាងក្រោម៖

១. គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង ។
២. គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ ។
៣. គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។
៤. គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសម្អាត ។
៥. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ។
៦. គណៈកម្មការនីតិកម្ម ។
៧. គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍ ។
៨. គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី ។
៩. គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាលចំនួន២ដង (ម្តង១ឆ្នាំ) តាមព្រះរាជក្រឹត្យ៖

លើកទី១៖ ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣០ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៤ (គិតចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥) ។

លើកទី២៖ ព្រះរាជក្រឹត្យ នស/រកត/១២០៥/០៧០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៥ (គិតចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ រហូតដល់ព្រឹទ្ធសភានីតិកាលទី២ ចូលកាន់តំណែង) ។

- ***សម្គាល់៖*** *សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី១ មាន៖*
  - ***សម្តេច ជា ស៊ីម*** *ជាប្រធាន* (CPP)
  - ***ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស*** *ជាអនុប្រធានទី១* (FUN)
  - ***ឯកឧត្តម ញឹក ប៊ុនឆៃ*** *ជាអនុប្រធានទី២* (FUN) *។ មកដល់ខែសីហា ឆ្នាំ២០០៤* ***ឯកឧត្តម ញឹក ប៊ុនឆៃ*** *បានលាលែងទៅបំពេញការងារក្នុងរាជរដ្ឋាភិបាល ហើយគណបក្សហ៊្វុនស៊ិនប៉ិច បានស្នើតែងតាំង* ***ឯកឧត្តម ប៉ោ ប៊ុនស្រ៊ឿ****ជំនួស ។*

## ក.២. ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២)



ព្រឹទ្ធសភានីតិកាលទី២

អនុលោមតាមច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ចាប់ពីនីតិកាលទី២ និងនីតិកាលបន្តបន្ទាប់ព្រឹទ្ធសភាកើតឡើងដោយការបោះឆ្នោតជាអសកលផង ជ្រើសតាំងផង និងចាត់តាំងផង សម្រាប់រយៈពេល៦ឆ្នាំ ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ ។ ព្រឹទ្ធសភានីតិកាលទី២ មានសមាជិកចំនួន៦១រូប ក្នុងនោះ៥៧រូប ត្រូវបានបោះឆ្នោតជាអសកល ០២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង០២រូបទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប ។

ព្រឹទ្ធសភានីតិកាលទី២ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ព្រឹទ្ធសភានីតិកាលទី២ មានគណៈកម្មការចំនួន០៩ ដែលក្នុងនោះ តាមរយៈការបោះឆ្នោតជ្រើសរើស និងជ្រើសតាំង ស្របតាមនីតិវិធីកំណត់ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៥

(គណៈកម្មការទី២, ៣, ៤, ៥, ៦) គណបក្សហ៊្វុនស៊ីនប៉ិច ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៣ (គណៈកម្មការទី១, ៨, ៩) និងគណបក្សសមរង្ស៊ី ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០១ គឺគណៈកម្មការទី៧ ។ ដោយឡែក អនុប្រធានគណៈកម្មការ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន០៤ (គណៈកម្មការទី១, ៦, ៨, ៩ ) និងគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានអាសនៈចំនួន០៥ (គណៈកម្មការទី២, ៣, ៤, ៥, ៧) ។

- **សម្គាល់៖** សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី២ មាន ៖
  - **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ជាប្រធាន (CPP)
  - **សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** ជាអនុប្រធានទី១ (FUN)
  - **ឯកឧត្តម ទេព ង៉ន** ជាអនុប្រធានទី២ (CPP) ។

### ក.៣. ព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)



ព្រឹទ្ធសភានីតិកាលទី៣

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ បានប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ ។ ព្រឹទ្ធសភានីតិកាលទី៣ មានសមាជិកចំនួន៦១រូប ក្នុងនោះ៥៧រូបត្រូវបានបោះឆ្នោតជាអសកល ០២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង០២រូបទៀតត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប ។

ព្រឹទ្ធសភានីតិកាលទី៣ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ចាប់ពីដំណើរការសម័យប្រជុំដំបូង និងបន្តរហូតមកដល់ពាក់កណ្តាលនីតិកាលទី៣ គណៈកម្មការនានានៃព្រឹទ្ធសភាមានចំនួន០៩ ហើយសមាសភាពក្នុងគណៈកម្មការ ដែលបានជាប់ឆ្នោតតាមរយៈការបោះឆ្នោតជ្រើសរើស និងជ្រើសតាំងស្របតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺមកពីគណបក្សប្រជាជនកម្ពុជាទាំងអស់ទាំងប្រធាន អនុប្រធាន លេខាធិការ និងសមាជិក គណៈកម្មការ ។

ដោយអនុលោមតាមកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា និងក្រុមការងាររបស់គណបក្សសមរង្ស៊ី បានឯកភាពចុះកិច្ចព្រមព្រៀង ស្តីពីការរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ ។

តាមរយៈកិច្ចព្រមព្រៀងខាងលើ ព្រឹទ្ធសភាបានធ្វើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ប្រការ១៥ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណៈកម្មការនានារបស់ព្រឹទ្ធសភាមានដូចខាងក្រោម ៖

១. គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត ។

២. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ។

៣. គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។

៤. គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ ។

៥. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ។

៦. គណៈកម្មការនីតិកម្ម និងយុត្តិធម៌ ។

៧. គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ។

៨. គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាល វិជ្ជាជីវៈ និងកិច្ចការនារី ។

៩. គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

១០. គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំង អំពើពុករលួយ ។

ទន្ទឹមនឹងនេះ សមាសភាពក្នុងគណៈកម្មការទាំង១០ ត្រូវបានរៀបចំកែសម្រួលបោះឆ្នោតជ្រើសរើស និងជ្រើសតាំងឡើងវិញ ។ សមាជិកព្រឹទ្ធសភាមកពីគណបក្សសមរង្ស៊ីទាំង១១រូប ត្រូវបានបញ្ចូលទៅក្នុងគណៈកម្មការទាំងអស់ ក្នុងនោះមាន អាសនៈប្រធានគណៈកម្មការចំនួន២គឺគណៈកម្មការទី១ និងទី១០អនុប្រធានគណៈកម្មការចំនួន២គឺគណៈកម្មការទី៣ និងទី៧លេខាធិការគណៈកម្មការចំនួន២គឺគណៈកម្មការទី១និងទី១០ព្រមទាំងសមាជិក៥រូបទៀត បញ្ចូល១រូបៗ ទៅក្នុងគណៈកម្មការទី១,៣,៧,៨ និងទី១០។

- **សម្គាល់៖** សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា មាន ៖
  - **សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ជាប្រធាន (CPP)
  - **ឯកឧត្តម សាយ ឈុំ** ជាអនុប្រធានទី១ (CPP)
  - **ឯកឧត្តម ទេព ង៉ន** ជាអនុប្រធានទី២ (CPP) ។

នៅថ្ងៃទី៨ខែមិថុនាឆ្នាំ២០១៥**សម្ដេចអគ្គមហាធម្មពោធិសាលជា ស៊ីម**ប្រធានព្រឹទ្ធសភាបានទទួលមរណភាព។ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញនាថ្ងៃទី៩ខែមិថុនាឆ្នាំ២០១៥ **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានព្រឹទ្ធសភា និង **ឯកឧត្តម នៃ ប៉េណា** ជាអនុប្រធានទី១ ព្រឹទ្ធសភានីតិកាលទី៣ ។

## ខ. សមាសភាពសមាជិកព្រឹទ្ធសភាតាមនីតិកាល

### ខ.១. សមាសភាពព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៦) ៖

យោង ៖

- ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ត្រាស់បង្គាប់ តែងតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី១
- ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ត្រាស់បង្គាប់ តែងតាំងសមាជិកព្រឹទ្ធសភាពីររូប សម្រាប់នីតិកាលទី១

- ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៩ ត្រាស់បង្គាប់ តែងតាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី១
- ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៧០ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ត្រាស់បង្គាប់ តែងតាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី១

| | | |
|---|---|---|
| ១. | សម្តេច ជា ស៊ីម | ប្រធាន |
| ២ | ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស | អនុប្រធានទី១ |
| ៣. | ឯកឧត្តម ញឹក ប៊ុនឆៃ | អនុប្រធានទី២ |
| ៤. | ឯកឧត្តម អៀវ បណ្ណាការ | តែងតាំងដោយព្រះមហាក្សត្រ |
| ៥. | លោកជំទាវ កែវ ប៊ុនធូក | តែងតាំងដោយព្រះមហាក្សត្រ |
| ៦. | ឯកឧត្តម អ៊ុក ប៊ុនឈឿន | (គ.ប្រ.ជ) |
| ៧. | ឯកឧត្តម ឈា ថាំង | (គ.ប្រ.ជ) |
| ៨. | ឯកឧត្តម ហង់ ជួន | (គ.ប្រ.ជ) |
| ៩. | ឯកឧត្តមចាន់ ភិន | (គ.ប្រ.ជ) |
| ១០. | ឯកឧត្តម ឆាំង សុង | (គ.ប្រ.ជ) |
| ១១. | ឯកឧត្តម អ៊ុង ទី | (គ.ប្រ.ជ) |
| ១២. | ឯកឧត្តម ឈិត គឹមយាត | (គ.ប្រ.ជ) |
| ១៣. | លោកជំទាវ ទី បូរ៉ាស៊ី | (គ.ប្រ.ជ) |
| ១៤. | លោកជំទាវ មាន សំអាន | (គ.ប្រ.ជ) |
| ១៥. | លោកជំទាវ ឈូក ឈឹម | (គ.ប្រ.ជ) |
| ១៦. | ឯកឧត្តម ទេព ង៉ន | (គ.ប្រ.ជ) |
| ១៧. | ឯកឧត្តម ស៊ឹម កា | (គ.ប្រ.ជ) |
| ១៨. | ឯកឧត្តម រស់ ស្រេង | (គ.ប្រ.ជ) |
| ១៩. | ឯកឧត្តម រុង ផ្លាមកេសន | (គ.ប្រ.ជ) |
| ២០. | ឯកឧត្តម ពៅ សាវ៉ាត | (គ.ប្រ.ជ) |
| ២១. | ឯកឧត្តម ប៉ិល ណាល់ | (គ.ប្រ.ជ) |
| ២២. | ឯកឧត្តម សេក សំអៀត | (គ.ប្រ.ជ) |

២៣. ឯកឧត្តម ប៉េង ប៉ាត់ (គ.ប្រ.ជ)
២៤. ឯកឧត្តម បឿយ កើក (គ.ប្រ.ជ)
២៥. ឯកឧត្តម កង ចន្ទ (គ.ប្រ.ជ)
២៦. ឯកឧត្តម ស៊ើយ កែវ (គ.ប្រ.ជ)
២៧. ឯកឧត្តម កែវ សាន (គ.ប្រ.ជ)
២៨. ឯកឧត្តម ស៊ិន សុង (គ.ប្រ.ជ)
២៩. ឯកឧត្តម អ៊ុក ប្រាថ្នា (គ.ប្រ.ជ)
៣០. ឯកឧត្តម ជា ជេដ្ឋ (គ.ប្រ.ជ)
៣១. ឯកឧត្តម វ៉ាន់ ម៉ាត់ (គ.ប្រ.ជ)
៣២. ឯកឧត្តម ផៃ ស៊ីផាន (គ.ប្រ.ជ)
៣៣. លោកជំទាវ ពុំ ស៊ីចាន់ (គ.ប្រ.ជ)
៣៤. ឯកឧត្តម ម៉ែន សារុន (គ.ប្រ.ជ)
៣៥. ឯកឧត្តម ជុង ចន់ (គ.ប្រ.ជ)
៣៦. ឯកឧត្តម ឃួន ហ្វ្រង់ (គ.ហ.ស.ប)
៣៧. ឯកឧត្តម ឃួន ប្វែរ៉េត (គ.ហ.ស.ប)
៣៨. ឯកឧត្តម សឹង អឿម (គ.ហ.ស.ប)
៣៩. ឯកឧត្តម គឹម សុខា (គ.ហ.ស.ប)
៤០. ឯកឧត្តម សាប៊ូ បាថា (គ.ហ.ស.ប)
៤១. ឯកឧត្តម អ៊ុង ស៊ឹម (គ.ហ.ស.ប)
៤២. ឯកឧត្តម ជា ប៉េងឈាង (គ.ហ.ស.ប)
៤៣. ឯកឧត្តម ខៀវ សន (គ.ហ.ស.ប)
៤៤. ឯកឧត្តម ខៀវ សួន (គ.ហ.ស.ប)
៤៥. លោកជំទាវ ម៉ែន ម៉ាលី (គ.ហ.ស.ប)
៤៦. លោកជំទាវ សម កនិដ្ឋា (គ.ហ.ស.ប)
៤៧. លោកជំទាវ មុិច សូម៉ាលី (គ.ហ.ស.ប)
៤៨. ឯកឧត្តម ឆាយ ប៊ិនឡាយ (គ.ហ.ស.ប)

៤៩. ឯកឧត្តម ស៊ិន ប៉ូ (គ.ហ.ស.ប)
៥០. ឯកឧត្តម ប្រាក់ វ៉ាន់នី (គ.ហ.ស.ប)
៥១. ឯកឧត្តម ស៊ឹម សូលី (គ.ហ.ស.ប)
៥២. ឯកឧត្តម ជា គីម (គ.ហ.ស.ប)
៥៣. ឯកឧត្តម យឹង គឹមអួន (គ.ហ.ស.ប)
៥៤. ឯកឧត្តម ហាស សារ៉េន (គ.ហ.ស.ប)
៥៥. ឯកឧត្តម គង់ គាំ (គ.ស.រ)
៥៦. ឯកឧត្តម ម៉េង រីតា (គ.ស.រ)
៥៧. ឯកឧត្តម អ៊ុក មឿន (គ.ស.រ)
៥៨. ឯកឧត្តម ថាច់ សេដ្ឋា (គ.ស.រ)
៥៩. ឯកឧត្តម អ៊ូ ប៊ុនឡុង (គ.ស.រ)
៦០. ឯកឧត្តម ហ៊ុត ទ្រី (គ.ស.រ)
៦១. ឯកឧត្តម ថៅ ផល្លី (គ.ស.រ)

**កំណត់សម្គាល់៖**

សមាសភាពសមាជិកព្រឹទ្ធសភា នីតិកាលទី១ ផ្លាស់ប្តូរ តែងតាំង ជំនួសថ្មី

| ល.រ | សមាជិកចេញ | | | ឈ្មោះសមាជិកថ្មី | ព្រះរាជក្រឹត្យ តែងតាំង | ថ្ងៃប្រកាសសមាជិកថ្មី និងសម័យប្រជុំ |
|---|---|---|---|---|---|---|
| | ឈ្មោះ | មូលហេតុ | គណបក្ស | | | |
| ១ | ឯ.ឧ. យឹង គឹម អួន | លាឈប់ | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ. សេរី កុសល | នស/រកត/០២០០/០៣៨ ចុះថ្ងៃទី០១/២/២០០០ | ២៥/៥/២០០០ សម័យប្រជុំទី៣ |
| ២ | ឯ.ឧ. ស៊ិន សុង | ស្លាប់ | ប្រជាជនកម្ពុជា | ឯ.ឧ. លី គឹមហាន | នស/រកត/០៣០១/០៥៨ ចុះថ្ងៃទី១៥/៣/២០០១ | ០៤/៦/២០០១ សម័យប្រជុំទី៥ |
| ៣ | ឯ.ឧ. ឃួន ប្លៃវ៉ែត | លាឈប់ | ហ៊្វុនស៊ិនប៉ិច | ន. សិរីវុឌ្ឍ | នស/រកត/០៧០១/២១៨ ចុះថ្ងៃទី០៤/៧/២០០១ | ០៩/៨/២០០១ សម័យប្រជុំទី៥ |
| ៤ | ឯ.ឧ. ស៊ិន ប៉ូ | ទៅអគ្គាធរ សវនកម្មជាតិ | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ. ស៊ិន ពិនសេន | នស/រកត/០៧០១/២៥២ ចុះថ្ងៃទី៣១/៧/២០០១ | ០៩/៨/២០០១ សម័យប្រជុំទី៥ |
| ៥ | ឯ. ប៉ិល ណាល់ | ស្លាប់ | ប្រជាជនកម្ពុជា | ឯ.ឧ. តួច សាក់ | នស/រកត/០៨០១/២៦៦ ចុះថ្ងៃទី០៨/៨/២០០១ | ១៣/៨/២០០១ សម័យប្រជុំទី៥ |
| ៦ | ឯ.ឧ . លី គឹមហាន | ស្លាប់ | ប្រជាជនកម្ពុជា | ឯ.ឧ. ទិត រាម | នស/រកត/១១០១/៤២០ ចុះថ្ងៃទី០៩/១១/២០០១ | ០៥/១២/២០០១ សម័យប្រជុំទី៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ឯ.ឧ.<br>ពៅ សាវ៉ាត | គណបក្ស<br>ផ្លាស់ប្តូរ | ប្រជាជនកម្ពុជា | ឯ.ឧ.<br>សោម សុផា | នស/រកត/១២០១/៤៥៥<br>ចុះថ្ងៃទី១២/១២/២០០១ | ២០/១២/២០០១<br>សម័យប្រជុំទី៦ |
| ៨ | ឯ.ឧ.<br>ឆាំង សុង | គណបក្ស<br>ផ្លាស់ប្តូរ | ប្រជាជនកម្ពុជា | ឯ.ឧ.<br>អ៊ុំ សារិទ្ធ | នស/រកត/១២០១/៤៥៥<br>ចុះថ្ងៃទី១២/១២/២០០១ | ២០/១២/២០០១<br>សម័យប្រជុំទី៦ |
| ៩ | ឯ.ឧ.<br>ផៃ ស៊ីផាន | គណបក្ស<br>ផ្លាស់ប្តូរ | ប្រជាជនកម្ពុជា | ជំ.<br>ឡាក់ អូន | នស/រកត/១២០១/៤៥៥<br>ចុះថ្ងៃទី១២/១២/២០០១ | ២០/១២/២០០១<br>សម័យប្រជុំទី៦ |
| ១០ | ឯ.ឧ.<br>កែវ សាន | ផ្លាស់ប្តូរ<br>គណបក្ស | ប្រជាជនកម្ពុជា | ឯ.ឧ.<br>ជ័យ សាផុន | នស/រកត/០១០២/០០២<br>ចុះថ្ងៃទី០៧/០១/២០០២ | ០៨/០១/២០០២<br>សម័យប្រជុំទី៦ |
| ១១ | ឯ.ឧ.<br>គឹម សុខា | លាឈប់ | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ.<br>ឈឹម សៀកឡេង | នស/រកត/១១០២/៣០៥<br>ចុះថ្ងៃទី០៨/១១/២០០២ | ១៦/១២/២០០២<br>សម័យប្រជុំទី៨ |
| ១២ | ឯ.ឧ.<br>ហង់ ជួន | ស្លាប់ | ប្រជាជនកម្ពុជា | ឯ.ឧ.<br>គង់ សាភជ | នស/រកត/១១០២/៣១១<br>ចុះថ្ងៃទី១៦/១១/២០០២ | ១៦/១២/២០០២<br>សម័យប្រជុំទី៨ |
| ១៣ | ព្រះអង្គម្ចាស់<br>ន. សិរីវុឌ្ឍ | លាឈប់ | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ .<br>ឆ្នាំ ប៊ុនស្រុន | នស/រកត/១០០៣/០៣៨<br>ចុះថ្ងៃទី២០/១០/២០០៣ | ១៣/០៤/២០០៤<br>សម័យប្រជុំទី៩ |
| ១៤ | ឯ.ឧ.<br>ឈឹម សៀកឡេង | លាឈប់ | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ.ឡាយ<br>ឈុនសារ៉េត | នស/រកត/១០០៣/៣០៤<br>ចុះថ្ងៃទី២០/១០/២០០៣ | ១៣/០៤/២០០៤<br>សម័យប្រជុំទី៩ |
| ១៥ | ឯ.ឧ.<br>ឃួន ហ្វ្រង់ | ស្លាប់ | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ. ឯក<br>សេរីវឌ្ឍ | នស/រកត/០៣០៤/០៥០<br>ចុះថ្ងៃទី២២/៣/២០០៤ | ១២/០៧/២០០៤<br>សម័យប្រជុំទី៩ |
| ១៦ | ឯ.ឧ.<br>ញឹក ប៊ុនឆៃ | ទៅរដ្ឋាភិបាល | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ.<br>ប៉ោ ប៊ុនស្រ៊ី | នស/រកត/០៧០៤/១៣១<br>ចុះថ្ងៃទី១៨/៧/២០០៤ | ២០/០៨/២០០៤<br>សម័យប្រជុំទី៩ |
| ១៧ | ឯ.ឧ.<br>ជា ប៉េងឈាង | ទៅរដ្ឋាភិបាល | ហ៊្វុនស៊ិនប៉ិច | សម្តេចព្រះរាម<br>នរោត្តម បុប្ផាទេវី | នស/រកត/០៧០៤/១៤៩<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/០៨/២០០៤<br>សម័យប្រជុំទី៩ |
| ១៨ | ឯ.ឧ.<br>សេរី កុសល | ទៅរដ្ឋាភិបាល | ហ៊្វុនស៊ិនប៉ិច | ព្រះអង្គម្ចាស់<br>ស៊ីសុវត្ថិ សិរីរ័ត្ន | នស/រកត/០៧០៤/១៤៩<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/៨/២០០៤<br>សម័យប្រជុំទី៩ |
| ១៩ | ឯ.ឧ.<br>អ៊ុក ប្រាជ្ញា | ទៅរដ្ឋាភិបាល | ប្រជាជនកម្ពុជា | ឯ.ឧ.<br>យ៉ង់ សែម | នស/រកត/០៧០៤/១៥០<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/០៨/២០០៤<br>សម័យប្រជុំទី៩ |
| ២០ | ឯ.ឧ .<br>អ៊ូ ប៊ុនឡុង | ទៅរដ្ឋាភិបាល | សមរង្ស៊ី | ឯ.ឧ.<br>អ៊ឹង ប៊ុនអាង | នស/រកត/០៧០៤/១៥១<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/០៨/២០០៤<br>សម័យប្រជុំទី៩ |
| ២១ | ឯ.ឧ.<br>ខៀវ សន | ទៅរដ្ឋសភា | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ. រស់ ឆេង | នស/រកត/០៧០៤/១៤៩<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/០៨/២០០៤<br>សម័យប្រជុំទី៩ |
| ២២ | ឯ.ឧ.<br>ស៊ិន ពិនសេន | ទៅរដ្ឋសភា | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ.<br>ហួត ប៉ុងលី | នស/រកត/០៧០៤/១៤៩<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/០៨/២០០៤<br>សម័យប្រជុំទី៩ |
| ២៣ | ឯ.ឧ.<br>ស៊ឹម សូលី | ទៅរដ្ឋសភា | ហ៊្វុនស៊ិនប៉ិច | អ្នកម្នាង<br>នរោត្តម ឌីយ៉ាត | នស/រកត/០៧០៤/១៤៩<br>ចុះថ្ងៃទី២៨/៧/២០០៤ | ២០/០៤/២០០៤<br>សម័យប្រជុំទី៩ |
| ២៤ | ឯ.ឧ. ឯក<br>សេរីវឌ្ឍ | ទទួល<br>ភារកិច្ចថ្មី | ហ៊្វុនស៊ិនប៉ិច | ឯ.ឧ.<br>ទា ចំរ៉ាត់ | នស/រកត/១០០៤/៣១៦<br>ចុះថ្ងៃទី១៩/១០/២០០៤ | ២២/១០/២០០៤<br>សម័យប្រជុំទី៩ |
| ២៥ | ឯ.ឧ. វុង<br>ផ្លាមកេសន | លាឈប់ | ប្រជាជនកម្ពុជា | ឯ.ឧ.<br>ជា សុន | នស/រកត/០៣០៥/១៤២<br>ចុះថ្ងៃទី១៨/៣/២០០៥ | ៣០/០៣/២០០៥<br>សម័យប្រជុំទី៩ |
| ២៦ | ជំ.ទ.<br>កែវ ប៊ុនធួក | ស្លាប់ | តំណាង<br>ព្រះមហាក្សត្រ | ឯ.ឧ.<br>អ៊ុំ ម៉ាន្នូរីន | នស/រកត/០៦០៥/២៩៣<br>ចុះថ្ងៃទី២៤/៦/២០០៥ | សម័យប្រជុំ<br>វិសាមញ្ញ |

### ខ.២. សមាសភាពសមាជិកព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២)៖

សមាជិកព្រឹទ្ធសភានីតិកាលទី២ មានចំនួន៦១រូប ដែលក្នុងនោះ ០២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ០២រូប ជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀបនិង៥៧រូបទៀត ជ្រើសតាំងដោយការបោះឆ្នោតជាអសកលកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ ។ ក្នុងចំណោមសមាជិក៥៧រូបនេះ មានសមាសភាពមកពីគណបក្សប្រជាជនកម្ពុជាចំនួន៤៥រូប គណបក្សហ៊្វុនស៊ិនប៉ិចចំនួន១០រូប គណបក្សសមរង្ស៊ី ចំនួន០២រូប ។

សមាសភាពសមាជិក សមាជិកា ដែលបានប្រកាសសុពលភាពនៃអាណត្តិ នាសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី២ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ មានដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម អ៊ុំ ម៉ាន្ទូរីន | អាយុ៨២ឆ្នាំ | (ច.ត ព្រះមហាក្សត្រ) |
| ២. | ឯកឧត្តម សេក សំអៀត | អាយុ៧៦ឆ្នាំ | (គ.ប្រ.ជ) |
| ៣. | ឯកឧត្តម ជ័យ សាផុន | អាយុ៧៦ឆ្នាំ | (គ.ប្រ.ជ) |
| ៤. | ឯកឧត្តម អៀវ បណ្ណាការ | អាយុ៧៥ឆ្នាំ | (ច.ត ព្រះមហាក្សត្រ) |
| ៥. | ឯកឧត្តម កង ចន្ទ | អាយុ៧៤ឆ្នាំ | (គ.ប្រ.ជ) |
| ៦. | សម្ដេច ជា ស៊ីម | អាយុ៧៤ឆ្នាំ | (គ.ប្រ.ជ) |
| ៧. | ឯកឧត្តម ឈា ថាំង | អាយុ៧១ឆ្នាំ | (គ.ប្រ.ជ) |
| ៨. | សម្ដេច ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស | អាយុ៧០ឆ្នាំ | (គ.ហ.ស.ប) |
| ៩. | ឯកឧត្តម ឆាត់ លឿម | អាយុ៧០ឆ្នាំ | (គ.ប្រ.ជ) |
| ១០. | ឯកឧត្តម សោម សុផា | អាយុ៦៩ឆ្នាំ | (គ.ប្រ.ជ) |
| ១១. | ឯកឧត្តម ចាន់ ភិន | អាយុ៦៨ឆ្នាំ | (គ.ប្រ.ជ) |
| ១២. | ឯកឧត្តម ជា សុន | អាយុ៦៧ឆ្នាំ | (គ.ប្រ.ជ) |
| ១៣. | ឯកឧត្តម រស់ ស្រេង | អាយុ៦៧ឆ្នាំ | (គ.ប្រ.ជ) |
| ១៤. | ឯកឧត្តម បឿយ កើក | អាយុ៦៧ឆ្នាំ | (គ.ប្រ.ជ) |
| ១៥. | លោកជំទាវ ទី បូរ៉ាស៊ី | អាយុ៦៧ឆ្នាំ | (គ.ប្រ.ជ) |
| ១៦. | ឯកឧត្តម ហុង ទូហាយ | អាយុ៦៧ឆ្នាំ | (គ.ប្រ.ជ) |

| | | |
|---|---|---|
| ១៧. ឯកឧត្តម គង់ គាំ | អាយុ៦៥ឆ្នាំ | (គ.ស.រ) |
| ១៨. ឯកឧត្តម ផុង ចន់ | អាយុ៦៥ឆ្នាំ | (គ.ប្រ.ជ) |
| ១៩. ឯកឧត្តម ឆ្នាំ ប៊ុនស្រុន | អាយុ៦៤ឆ្នាំ | (គ.ហ.ស.ប) |
| ២០. សម្តេចរាជបុត្រី ព្រះរៀម នរោត្តម បុប្ផាទេវី | អាយុ៦៣ឆ្នាំ | (ជ.ត ដោយរដ្ឋសភា) |
| ២១. ឯកឧត្តម សាប៊ូ បាចា | អាយុ៦៣ឆ្នាំ | (ជ.ត ដោយរដ្ឋសភា) |
| ២២. ឯកឧត្តម ទិត រាម | អាយុ៦៣ឆ្នាំ | (គ.ប្រ.ជ) |
| ២៣. ឯកឧត្តម អ៊ុក ប៊ុនឈឿន | អាយុ៦៣ឆ្នាំ | (គ.ប្រ.ជ) |
| ២៤. ឯកឧត្តម តូច សាក់ | អាយុ៦៣ឆ្នាំ | (គ.ប្រ.ជ) |
| ២៥. ឯកឧត្តម សួន លន់ | អាយុ៦៣ឆ្នាំ | (គ.ប្រ.ជ) |
| ២៦. ឯកឧត្តម ស៊ើយ កែវ | អាយុ៦៣ឆ្នាំ | (គ.ប្រ.ជ) |
| ២៧. ឯកឧត្តម យ៉ង់ សែម | អាយុ៦៣ឆ្នាំ | (គ.ប្រ.ជ) |
| ២៨. ឯកឧត្តម ឡាវ ម៉េងឃីន | អាយុ៦២ឆ្នាំ | (គ.ប្រ.ជ) |
| ២៩. លោកជំទាវ ព្រំ ស៊ិត | អាយុ៦២ឆ្នាំ | (គ.ប្រ.ជ) |
| ៣០. ឯកឧត្តម គឹម ណាំង | អាយុ៦១ឆ្នាំ | (គ.ប្រ.ជ) |
| ៣១. លោកជំទាវ ម៉ែន ម៉ាលី | អាយុ៦១ឆ្នាំ | (គ.ហ.ស.ប) |
| ៣២. លោកជំទាវ ឡាក់ អួន | អាយុ៦១ឆ្នាំ | (គ.ប្រ.ជ) |
| ៣៣. ឯកឧត្តម ម៉ែន សារុន | អាយុ៦០ឆ្នាំ | (គ.ប្រ.ជ) |
| ៣៤. ឯកឧត្តម ទេព ង៉ន | អាយុ៥៩ឆ្នាំ | (គ.ប្រ.ជ) |
| ៣៥. ឯកឧត្តម អ៊ឹង ហួត | អាយុ៥៩ឆ្នាំ | (គ.ហ.ស.ប) |
| ៣៦. ឯកឧត្តម អ៊ុំ សារិទ្ធ | អាយុ៥៩ឆ្នាំ | (គ.ប្រ.ជ) |
| ៣៧. ឯកឧត្តម ឈិត គឹមយាត | អាយុ៥៩ឆ្នាំ | (គ.ប្រ.ជ) |
| ៣៨. ឯកឧត្តម ស៊ី គង់ទ្រីវ | អាយុ៥៩ឆ្នាំ | (គ.ប្រ.ជ) |

| | | |
|---|---|---|
| ៣៩. ឯកឧត្តម គង់ សារាជ | អាយុ៥៩ឆ្នាំ | (គ.ប្រ.ជ) |
| ៤០. លោកជំទាវ ពុំ ស៊ីចាន់ | អាយុ៥៩ឆ្នាំ | (គ.ប្រ.ជ) |
| ៤១. ឯកឧត្តម វ៉ាន់ ម៉ាត់ | អាយុ៥៨ឆ្នាំ | (គ.ប្រ.ជ) |
| ៤២. ឯកឧត្តម ឡាយ អ៊ីពិសិទ្ធិ | អាយុ៥៨ឆ្នាំ | (គ.ប្រ.ជ) |
| ៤៣. ឯកឧត្តម ជា ជេដ្ឋ | អាយុ៥៨ឆ្នាំ | (គ.ប្រ.ជ) |
| ៤៤. ឯកឧត្តម ស៊ឹម កា | អាយុ៥៨ឆ្នាំ | (គ.ប្រ.ជ) |
| ៤៥. ឯកឧត្តម ប៉េង ប៉ាត់ | អាយុ៥៧ឆ្នាំ | (គ.ប្រ.ជ) |
| ៤៦. ឯកឧត្តម ពុត ជួប | អាយុ៥៧ឆ្នាំ | (គ.ប្រ.ជ) |
| ៤៧. ឯកឧត្តម ពុធ ខូវ | អាយុ៥៧ឆ្នាំ | (គ.ប្រ.ជ) |
| ៤៨. ឯកឧត្តម អ៊ុក គង់ | អាយុ៥៧ឆ្នាំ | (គ.ប្រ.ជ) |
| ៤៩. ឯកឧត្តម អ៊ុង ទី | អាយុ៥៧ឆ្នាំ | (គ.ប្រ.ជ) |
| ៥០. ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី | អាយុ៥៧ឆ្នាំ | (គ.ហ.ស.ប) |
| ៥១. ឯកឧត្តម វ៉ាន់ ស៊ីវឿន | អាយុ៥៤ឆ្នាំ | (គ.ស.រ) |
| ៥២. លោកជំទាវ ខូត ទង់ផ្កា | អាយុ៥៤ឆ្នាំ | (គ.ហ.ស.ប) |
| ៥៣. ឯកឧត្តម ប៉ុក កុសល | អាយុ៥៣ឆ្នាំ | (គ.ហ.ស.ប) |
| ៥៤. ឯកឧត្តម កុក អាន | អាយុ៥៣ឆ្នាំ | (គ.ប្រ.ជ) |
| ៥៥. ឯកឧត្តម ម៉ុង ឫទ្ធី | អាយុ៥២ឆ្នាំ | (គ.ប្រ.ជ) |
| ៥៦. លោកជំទាវ ឈូក ឈឹម | អាយុ៥២ឆ្នាំ | (គ.ប្រ.ជ) |
| ៥៧. ឯកឧត្តម ពៅ សិទ្ធិ | អាយុ៥១ឆ្នាំ | (គ.ហ.ស.ប) |
| ៥៨. លោកជំទាវ មាន សំអាន | អាយុ៥០ឆ្នាំ | (គ.ប្រ.ជ) |
| ៥៩. ឯកឧត្តម ជា គីម | អាយុ៤៩ឆ្នាំ | (គ.ហ.ស.ប) |
| ៦០. ឯកឧត្តម លី យ៉ុងផាត់ | អាយុ៤៨ឆ្នាំ | (គ.ប្រ.ជ) |
| ៦១. ឯកឧត្តម ឈឹម សាខន | អាយុ៤៧ឆ្នាំ | (គ.ហ.ស.ប) |

**កំណត់សម្គាល់៖**

សមាសភាពសមាជិកព្រឹទ្ធសភានីតិកាលទី២ ផ្លាស់ប្តូរជំនួសថ្មី

| ល.រ | សមាជិកចេញ | | | ឈ្មោះសមាជិកថ្មី | ថ្ងៃប្រកាសសមាជិកថ្មី និងសម័យប្រជុំ |
|---|---|---|---|---|---|
| | ឈ្មោះ | មូលហេតុ | គណបក្ស | | |
| ១ | សម្តេច នរោត្តម ចក្រពង្ស | បាត់បង់សមាជិកភាពពីគណបក្ស | ហ៊្វុនស៊ិនប៉ិច | ឯកឧត្តម ឈឹម សាខន | ១២/១២/២០០៦ សម័យប្រជុំលើកទី២ |
| ២ | លោកជំទាវ ខ្ងួត ទង់ផ្កា | លាលែងពីគណបក្ស | ហ៊្វុនស៊ិនប៉ិច | ឯកឧត្តម ហេង បូ | ១២/០៧/២០១០ សម័យប្រជុំលើកទី៧ |
| ៣ | ឯកឧត្តម ស៊ី គង់ទ្រីវ | លាលែងពីសមាជិកព្រឹទ្ធសភា | ប្រជាជនកម្ពុជា | ឯកឧត្តម ប្រាក់ ចំរើន | ០៣/០៥/២០១១ សម័យប្រជុំលើកទី៩ |
| ៤ | ឯកឧត្តម ម៉ែន សារុន | ទទួលមរណភាព | ប្រជាជនកម្ពុជា | តិចជាង៦ខែ ចប់នីតិកាល | |

## ៦.៣. សមាសភាពសមាជិកព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨)៖

សមាជិកព្រឹទ្ធសភានីតិកាលទី៣ មានចំនួន៦១រូប ដែលក្នុងនោះ ០២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ០២រូបជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប និង ៥៧រូបទៀត ជ្រើសតាំងដោយការបោះឆ្នោតជាអសកលកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ ។ ក្នុងចំណោមសមាជិក៥៧រូបនេះ មានសមាសភាពមកពីគណបក្សប្រជាជនកម្ពុជា ចំនួន៤៦រូប គណបក្សសមរង្ស៊ី ចំនួន១១រូប ។

សមាសភាពសមាជិក សមាជិកា ដែលបានប្រកាសសុពលភាពនៃអាណត្តិ នាសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៣ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២ មានដូចខាងក្រោម៖

១. ឯកឧត្តម អ៊ុំ ម៉ាន្នូរីន — អាយុ៨៨ឆ្នាំ (ច.ត ព្រះមហាក្សត្រ)
២. ឯកឧត្តមអៀវ បណ្ណាការ — អាយុ៨១ឆ្នាំ (ច.ត ព្រះមហាក្សត្រ)
៣. សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម — អាយុ៨០ឆ្នាំ (គ.ប្រ.ជ)
៤. សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស — អាយុ៧៦ឆ្នាំ (ជ.ត រដ្ឋសភា)
៥. ឯកឧត្តម ឆាត់ លឿម — អាយុ៧៦ឆ្នាំ (គ.ប្រ.ជ)
៦. ឯកឧត្តម ស៊ើយ កែវ — អាយុ៧៥ឆ្នាំ (គ.ប្រ.ជ)
៧. ឯកឧត្តម ចាន់ ភិន — អាយុ៧៤ឆ្នាំ (គ.ប្រ.ជ)

| | |
|---|---|
| ៨. ឯកឧត្តម ប៊ូ ថង | អាយុ៧៤ឆ្នាំ (គ.ប្រ.ជ) |
| ៩. ឯកឧត្តម ជា សុន | អាយុ៧៣ឆ្នាំ (គ.ប្រ.ជ) |
| ១០. លោកជំទាវ ទី បូរ៉ាសុី | អាយុ៧៣ឆ្នាំ (គ.ប្រ.ជ) |
| ១១. ឯកឧត្តម ហុង ទូហាយ | អាយុ៧៣ឆ្នាំ (គ.ប្រ.ជ) |
| ១២. ឯកឧត្តម គង់ គាំ | អាយុ៧១ឆ្នាំ (គ.ស.រ) |
| ១៣.ឯកឧត្តម ប៉ុង ចន់ | អាយុ៨០ឆ្នាំ (គ.ប្រ.ជ) |
| ១៤. សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី | អាយុ៦៩ឆ្នាំ (ជ.ត រង្គសភា) |
| ១៥. ឯកឧត្តម ទិត រាម | អាយុ៦៩ឆ្នាំ (គ.ប្រ.ជ) |
| ១៦. ឯកឧត្តម អ៊ុក ប៊ុនឈឿន | អាយុ៦៩ឆ្នាំ (គ.ប្រ.ជ) |
| ១៧.ឯកឧត្តម សួន លន់ | អាយុ៦៩ឆ្នាំ (គ.ប្រ.ជ) |
| ១៨. ឯកឧត្តម យ៉ង់ សែម | អាយុ៦៩ឆ្នាំ (គ.ប្រ.ជ) |
| ១៩. ឯកឧត្តម ឡាវ ម៉េងឃីន | អាយុ៦៨ឆ្នាំ (គ.ប្រ.ជ) |
| ២០. ឯកឧត្តម សាយ ឈុំ | អាយុ៦៧ឆ្នាំ (គ.ប្រ.ជ) |
| ២១. ឯកឧត្តម គឹម ណាំង | អាយុ៦៧ឆ្នាំ (គ.ប្រ.ជ) |
| ២២. លោកជំទាវ ឡាក់ អួន | អាយុ៦៧ឆ្នាំ (គ.ប្រ.ជ) |
| ២៣.ឯកឧត្តម នុត រំដួល | អាយុ៦៦ឆ្នាំ (គ.ប្រ.ជ) |
| ២៤. ឯកឧត្តម ទេព ង៉ន | អាយុ៦៥ឆ្នាំ (គ.ប្រ.ជ) |
| ២៥. ឯកឧត្តម ចាន់ ណារ៉េត | អាយុ៦៥ឆ្នាំ (គ.ប្រ.ជ) |
| ២៦. ឯកឧត្តម អ៊ុំ សារិទ្ធ | អាយុ៦៥ឆ្នាំ (គ.ប្រ.ជ) |
| ២៧.ឯកឧត្តម ឈិត គឹមយាត | អាយុ៦៥ឆ្នាំ (គ.ប្រ.ជ) |
| ២៨. ឯកឧត្តម គង់ សារាជ | អាយុ៦៥ឆ្នាំ (គ.ប្រ.ជ) |
| ២៩. ឯកឧត្តម ហ៊ូ វ៉ាន់ | អាយុ៦៥ឆ្នាំ (គ.ស.រ) |
| ៣០.លោកជំទាវ ពុំ ស៊ីចាន់ | អាយុ៦៥ឆ្នាំ (គ.ប្រ.ជ) |
| ៣១.ឯកឧត្តម ឡាយ អ៊ីពិសិទ្ធិ | អាយុ៦៤ឆ្នាំ (គ.ប្រ.ជ) |

| | |
|---|---|
| ៣២. ឯកឧត្តម ជា ជេដ្ឋ | អាយុ៦៤ឆ្នាំ (គ.ប្រ.ជ) |
| ៣៣. ឯកឧត្តម ស៊ឹម កា | អាយុ៦៤ឆ្នាំ (គ.ប្រ.ជ) |
| ៣៤.ឯកឧត្តម នៃ ប៉េណា | អាយុ៦៤ឆ្នាំ (គ.ប្រ.ជ) |
| ៣៥.ឯកឧត្តម ប៉េង ប៉ាត់ | អាយុ៦៣ឆ្នាំ (គ.ប្រ.ជ) |
| ៣៦.ឯកឧត្តម ពុធ ខូវ | អាយុ៦៣ឆ្នាំ (គ.ប្រ.ជ) |
| ៣៧. ឯកឧត្តម អ៊ុក គង់ | អាយុ៦៣ឆ្នាំ (គ.ប្រ.ជ) |
| ៣៨. ឯកឧត្តម អ៊ុង ទី | អាយុ៦៣ឆ្នាំ (គ.ប្រ.ជ) |
| ៣៩. ឯកឧត្តម អាំ សំអាត | អាយុ៦២ឆ្នាំ (គ.ប្រ.ជ) |
| ៤០. ឯកឧត្តម អន ស៊ុំ | អាយុ៦២ឆ្នាំ (គ.ប្រ.ជ) |
| ៤១. ឯកឧត្តម យឹម សេត | អាយុ៦១ឆ្នាំ (គ.ប្រ.ជ) |
| ៤២. ឯកឧត្តម ទឹម ផន | អាយុ៦១ឆ្នាំ (គ.ប្រ.ជ) |
| ៤៣.ឯកឧត្តម នួន សាមិន | អាយុ៦១ឆ្នាំ (គ.ប្រ.ជ) |
| ៤៤. ឯកឧត្តម ថាច់ សេដ្ឋា | អាយុ៥៩ឆ្នាំ (គ.ស.រ) |
| ៤៥. ឯកឧត្តម ម៉ែន ស៊ីផាន់ | អាយុ៥៨ឆ្នាំ (គ.ប្រ.ជ) |
| ៤៦. ឯកឧត្តម កុក អាន | អាយុ៥៨ឆ្នាំ (គ.ប្រ.ជ) |
| ៤៧.ឯកឧត្តម ម៉ុង ឫទ្ធី | អាយុ៥៨ឆ្នាំ (គ.ប្រ.ជ) |
| ៤៨. ឯកឧត្តម វ៉ាន់ វុធ | អាយុ៥៨ឆ្នាំ (គ.ប្រ.ជ) |
| ៤៩. លោកជំទាវ ឈូក ឈឹម | អាយុ៥៨ឆ្នាំ (គ.ប្រ.ជ) |
| ៥០. លោកជំទាវ កែវ ម៉ាលី | អាយុ៥៧ឆ្នាំ (គ.ប្រ.ជ) |
| ៥១. លោកជំទាវ ថាក់ ឡានី | អាយុ៥៧ឆ្នាំ (គ.ស.រ) |
| ៥២. ឯកឧត្តម ទាវ វណ្ណុល | អាយុ៥៧ឆ្នាំ (គ.ស.រ) |
| ៥៣.ឯកឧត្តម ហុង សុខហួរ | អាយុ៥៦ឆ្នាំ (គ.ស.រ) |
| ៥៤. លោកជំទាវ មាន សំអាន | អាយុ៥៦ឆ្នាំ (គ.ប្រ.ជ) |
| ៥៥. ឯកឧត្តម ម៉ម ប៊ុននាង | អាយុ៥៦ឆ្នាំ (គ.ប្រ.ជ) |
| ៥៦. ឯកឧត្តម លី យ៉ុងផាត់ | អាយុ៥៤ឆ្នាំ (គ.ប្រ.ជ) |

៥៧. ឯកឧត្តម ម៉ែន សុផាវរិទ្ធ អាយុ៥៣ឆ្នាំ (គ.ស.រ)
៥៨. លោកជំទាវ កែ សុវណ្ណរតន៍ អាយុ៥០ឆ្នាំ (គ.ស.រ)
៥៩. ឯកឧត្តម អេង ឆៃអ៊ាង អាយុ៤៧ឆ្នាំ (គ.ស.រ)
៦០. ឯកឧត្តម អ៊ុច សេរីយុទ្ធ អាយុ៤២ឆ្នាំ (គ.ស.រ)
៦១. ឯកឧត្តម ហេង បូរ៉ា អាយុ៤២ឆ្នាំ (គ.ប្រ.ជ)

**កំណត់សម្គាល់៖**

**សមាសភាពសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ផ្លាស់ប្តូរជំនួសថ្មី**

| ល.រ | សមាជិកចេញ | | | ឈ្មោះសមាជិកថ្មី | ព្រះរាជក្រឹត្យ សេចក្តីសម្រេច |
|---|---|---|---|---|---|
| | ឈ្មោះ | មូលហេតុ | គណបក្ស | | |
| ១ | សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស | លាលែង សុំចូលនិវត្តន៍ | រដ្ឋសភា | ឯកឧត្តម ប្រាក់ ចំរើន | ព្រះរាជក្រឹត្យនស/រកត/០៤១២/៣៧២ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ |
| ២ | ឯកឧត្តម ចាន់ ភិន | ទទួលមរណភាព | ប្រជាជនកម្ពុជា | ឯកឧត្តម ឈួន ឡេង | សេចក្តីសម្រេចលេខ: ០៣៩/១០១២/ពស/ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ |
| ៣ | ឯកឧត្តម អ៊ុំ សារិទ្ធ | សុំលាលែងពី សមាជិក ព្រឹទ្ធសភា | ប្រជាជនកម្ពុជា | ឯកឧត្តម ជុំ វង់ | សេចក្តីសម្រេចលេខ: ០១៧/០២១៣/ពស/ស.រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ |
| ៤ | ឯកឧត្តម នុត រំដួល | ប្រាសចាក សមាជិកភាព ពីគណបក្ស | សមរង្ស៊ី | ឯកឧត្តម យូ ស៊ាងហេង | សេចក្តីសម្រេចលេខ: ០៦០/១៥១៣/ពស/ស.រ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ |
| ៥ | ឯកឧត្តម ហ៊ូ វ៉ាន់ | ប្រាសចាក សមាជិកភាព ពីគណបក្ស | សមរង្ស៊ី | ឯកឧត្តម ចេប គឹមអ៊ាង | សេចក្តីសម្រេចលេខ: ០៦០/១៥១៣/ពស/ស.រ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ |
| ៦ | ឯកឧត្តម ថាច់ សេដ្ឋា | ប្រាសចាក សមាជិកភាព ពីគណបក្ស | សមរង្ស៊ី | ឯកឧត្តម សោម ចាន់ដេត | សេចក្តីសម្រេចលេខ: ០៦០/១៥១៣/ពស/ស.រ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ |

| | | | | | |
|---|---|---|---|---|---|
| ៧ | ឯកឧត្តម<br>ម៉ែន សុជាវិរិទ្ធ | ប្រាសចាក<br>សមាជិកភាព<br>ពីគណបក្ស | សមរង្ស៊ី | ឯកឧត្តម<br>សេង ម៉ារឌី | សេចក្តីសម្រេចលេខ:<br>០៦០/១៥១៣/ពស/ស.រ<br>ចុះថ្ងៃទី២២ ខែឧសភា<br>ឆ្នាំ២០១៣ |
| ៨ | លោកជំទាវ<br>កែ សុវណ្ណរតន៍ | ប្រាសចាក<br>សមាជិកភាព<br>ពីគណបក្ស | សមរង្ស៊ី | លោកជំទាវ<br>លី នារី | សេចក្តីសម្រេចលេខ:<br>០៦០/១៥១៣/ពស/ស.រ<br>ចុះថ្ងៃទី២២ ខែឧសភា<br>ឆ្នាំ២០១៣ |
| ៩ | ឯកឧត្តម<br>អេង ឆៃអ៊ាង | ប្រាសចាក<br>សមាជិកភាព<br>ពីគណបក្ស | សមរង្ស៊ី | លោកជំទាវ<br>ឡាយ បូនី | សេចក្តីសម្រេចលេខ:<br>០៦០/១៥១៣/ពស/ស.រ<br>ចុះថ្ងៃទី២២ ខែឧសភា<br>ឆ្នាំ២០១៣ |
| ១០ | ឯកឧត្តម<br>អ៊ុច សេរីយុទ្ធ | ប្រាសចាក<br>សមាជិកភាព<br>ពីគណបក្ស | សមរង្ស៊ី | ឯកឧត្តម<br>សួន រ៉ាន់ឡេង | សេចក្តីសម្រេចលេខ:<br>០៦០/១៥១៣/ពស/ស.រ<br>ចុះថ្ងៃទី២២ ខែឧសភា<br>ឆ្នាំ២០១៣ |
| ១១ | ឯកឧត្តម<br>គឹម ណាំង | ទទួលមរណភាព | ប្រជាជនកម្ពុជា | ឯកឧត្តម<br>ឈួន សឿន | សេចក្តីសម្រេចលេខ:<br>១២១/១១១៣/ពស/ស.រ<br>ចុះថ្ងៃទី២៥ ខែវិច្ឆិកា<br>ឆ្នាំ២០១៣ |
| ១២ | សម្តេច<br>អគ្គមហាធម្ម<br>ពោធិសាល<br>ជា ស៊ីម | ទទួលមរណភាព | ប្រជាជនកម្ពុជា | ឯកឧត្តម<br>ម៉ាន់ ឈឿន | សេចក្តីសម្រេចលេខ:<br>០៤៣/០៦១៥/ពស/ស.រ<br>ចុះថ្ងៃទី៣០ ខែមិថុនា<br>ឆ្នាំ២០១៥ |
| ១៣ | ឯកឧត្តម<br>ទិត ពម | ទទួលមរណភាព | ប្រជាជនកម្ពុជា | ឯកឧត្តម<br>វ៉ាន់ ម៉ាត់ | សេចក្តីសម្រេចលេខ:<br>០៦១/០៧១៥/ពស/ស.រ<br>ចុះថ្ងៃទី២៤ ខែកក្កដា<br>ឆ្នាំ២០១៥ |
| ១៤ | ឯកឧត្តម<br>គង់ គាំ | លាលែង<br>សុំចូលនិវត្តន៍ | សមរង្ស៊ី | ឯកឧត្តម<br>យឹម ឃុនឃឿន | សេចក្តីសម្រេចលេខ:<br>០២៦/០៤១៦/ពស/រ.ស<br>ចុះថ្ងៃទី២២ ខែមេសា<br>ឆ្នាំ២០១៦ |

| | | | | | |
|---|---|---|---|---|---|
| ១៥ | ឯកឧត្តម<br>ប៉េង ប៉ាត់ | ទទួលមរណភាព | ប្រជាជនកម្ពុជា | លោកជំទាវ<br>ជិន សុជីម | សេចក្ដីសម្រេចលេខ:<br>០២៦/០៤១៦/ពស/រ.ស<br>ចុះថ្ងៃទី២២ ខែមេសា<br>ឆ្នាំ២០១៦ |
| ១៦ | សម្ដេចរាជបុត្រី<br>ព្រះរៀម<br>នរោត្តម បុប្ផាទេវី | សុំលាលែងពី<br>សមាជិកព្រឹទ្ធសភា | រដ្ឋសភា | ឯកឧត្ដម<br>ខៀវ មុត | សេចក្ដីសម្រេចលេខ:<br>០៥៤/០៦១៦/ពស/ស.រ<br>ចុះថ្ងៃទី២៩ ខែមិថុនា<br>ឆ្នាំ២០១៦ |
| ១៧ | លោកជំទាវ<br>ថាក់ ឡានី | លើកអភ័យឯកសិទ្ធិ | សមរង្ស៊ី | | លើកអភ័យឯកសិទ្ធិ<br>ថ្ងៃទី០១ ខែកក្កដា<br>ឆ្នាំ២០១៦ |
| ១៨ | ឯកឧត្តម<br>ហុង សុខហួរ | -**លើកអភ័យឯកសិទ្ធិ**<br>-លាលែងពីគណបក្ស | សមរង្ស៊ី | លោកជំទាវ<br>គន់ លំអង | សេចក្ដីសម្រេចលេខ:<br>០៤៣/០៦១៧/ពស/<br>ស.រ.នវ<br>ចុះថ្ងៃទី២៩ ខែមិថុនា<br>ឆ្នាំ២០១៧ |

## គ. គណបក្សនយោបាយទទួលបានអាសនៈតាមនីតិកាល

### គ.១. នីតិកាលទី១

គណបក្សនយោបាយ និងស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភានីតិកាលទី១ មានដូចខាងក្រោម៖

១- ស្ថាប័នព្រះមហាក្សត្រ ចំនួន ០២រូប ។

២- គណបក្សប្រជាជនកម្ពុជា (CPP) ចំនួន៣១រូប ។

៣-គណបក្សហ្វ៊ុនស៊ិនប៉ិច (FUN) ចំនួន២១រូប ។

៤- គណបក្សសមរង្ស៊ី (SRP) ចំនួន០៧រូប ។

### គ.២. នីតិកាលទី២

គណបក្សនយោបាយ និងស្ថាប័នដែលមានអាសនៈក្នុងព្រឹទ្ធសភានីតិកាលទី២ មានដូចខាងក្រោម៖

| | |
|---|---|
| ១. ស្ថាប័នព្រះមហាក្សត្រ | ចំនួន០២រូប ។ |
| ២. រដ្ឋសភា | ចំនួន០២រូប ។ |
| ៣. គណបក្សប្រជាជនកម្ពុជា ( CPP ) | ចំនួន៤៥រូប ។ |
| ៤. គណបក្សហ្វ៊ុនស៊ិនប៉ិច ( FUN ) | ចំនួន ១០រូប ។ |
| ៥. គណបក្សសមរង្ស៊ី ( SRP ) | ចំនួន ០២រូប ។ |

### គ.៣. នីតិកាលទី៣

គណបក្សនយោបាយ និងស្ថាប័នដែលមានអាសនៈក្នុងព្រឹទ្ធសភានីតិកាលទី៣ មានដូចខាងក្រោម៖

| | |
|---|---|
| ១. ស្ថាប័នព្រះមហាក្សត្រ | ចំនួន០២រូប ។ |
| ២. រដ្ឋសភា | ចំនួន០២រូប ។ |
| ៣. គណបក្សប្រជាជនកម្ពុជា ( CPP ) | ចំនួន៤៦រូប ។ |
| ៤. គណបក្សសមរង្ស៊ី ( SRP ) | ចំនួន ១១រូប ។ |

# ផ្នែកទី២
# សភាក្នុងនីតិកាលបច្ចុប្បន្ន


I. រូបសញ្ញា និងទីតាំង ....................................១២៦

១. រដ្ឋសភា ....................................១២៦

*ក. រូបសញ្ញា* ....................................១២៦

*ខ. ទីតាំងបច្ចុប្បន្ន* ....................................១២៦

២. ព្រឹទ្ធសភា ....................................១២៧

*ក. រូបសញ្ញា* ....................................១២៧

*ខ. ទីតាំងបច្ចុប្បន្ន* ....................................១២៧

II. រដ្ឋសភានីតិកាលបច្ចុប្បន្ន ....................................១២៨

១. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ....................................១២៩

២. សមាសភាពតាមមណ្ឌល....................................១៣០

៣. រចនាសម្ព័ន្ធរដ្ឋសភា....................................១៣៧

៤. តួនាទី ភារកិច្ច និងអភ័យឯកសិទ្ធិសភា ....................................១៣៨

III. ព្រឹទ្ធសភានីតិកាលបច្ចុប្បន្ន ....................................១៤៥

១. ការចាត់តាំង និងជ្រើសតាំងសមាជិកព្រឹទ្ធសភា....................................១៤៦

២. សមាសភាពតាមមណ្ឌលភូមិភាគ ............................................. ១៤៧
៣. រចនាសម្ព័ន្ធព្រឹទ្ធសភា.......................................................... ១៥១
៤. តួនាទី ភារកិច្ច និងអភ័យឯកសិទ្ធិសភា .................................. ១៥២
IV. គណៈកម្មការសភា ............................................ ១៥៩
១. គណៈកម្មការរដ្ឋសភា ........................................................ ១៥៩
១.១. ការបង្កើត ............................................................... ១៥៩
១.២. រចនាសម្ព័ន្ធ............................................................... ១៦០
១.៣. តួនាទី ភារកិច្ច........................................................... ១៦០
២.គណៈកម្មការព្រឹទ្ធសភា........................................................ ១៦៥
២.១. ការបង្កើត ............................................................... ១៦៥
២.២. រចនាសម្ព័ន្ធ .............................................................. ១៦៧
២.៣. តួនាទី ភារកិច្ច និងសមត្ថកិច្ច.......................................... ១៦៧
V. ការងារការទូតសភា ........................................... ១៧២
VI. ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា .............. ១៧៨



# I. រូបសញ្ញា និងទីតាំង

## ១. រដ្ឋសភា

*ក. រូបសញ្ញា*

*ខ. ទីតាំងបច្ចុប្បន្ន*

*វិមានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នត្រូវបានសម្ពោធក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ* **នរោត្តម សីហមុនី** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ៧ ខែកក្កដា ឆ្នាំ២០០៧ មានទីតាំងស្ថិតនៅវិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។*



# ២. ព្រឹទ្ធសភា

## ក. រូបសញ្ញា

## ខ. ទីតាំងបច្ចុប្បន្ន

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាមានទីតាំងស្ថិតក្នុងវិមានរដ្ឋចំការមន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ លាតសន្ធឹងលើផ្ទៃដីទំហំ ៦៧.២៧១.៥៣ ម៉ែត្រការ៉េ ខាងជើងទល់នឹងក្រសួងកសិកម្ម ខាងត្បូងទល់នឹងផ្លូវលេខៈ ៤៦២ ខាងលិចទល់នឹងផ្លូវត្រសក់ផ្អែម ខាងកើតទល់នឹងមហាវិថីព្រះនរោត្តម ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានប្រគល់អតីតវិមានរដ្ឋចំការមនឱ្យព្រឹទ្ធសភាគ្រប់គ្រងតាមអនុក្រឹត្យលេខៈ ៧៥ អ.ន.ក្រ.អ.ក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ និងសេចក្តីជូនដំណឹងលេខៈ ៣១០ ស.ជ.ណ.អ.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។



ក្លោងទ្វារខាងមុខព្រឹទ្ធសភា

# II. រដ្ឋសភានីតិកាលបច្ចុប្បន្ន




*ក្រោមព្រះរាជអធិបតីភាព នៃព្រះមហាក្សត្រ* ***នរោត្តម សីហមុនី*** *ក្នុងពិធីបើកសម័យប្រជុំដំបូងនៃរដ្ឋសភានីតិកាលទី៦*




*រដ្ឋសភា នីតិកាលទី៦*



រដ្ឋសភា នីតិកាលទី៦ ក្នុងពិធីសច្ចាប្រណិធាន

## ១. ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រ យ៉ាងតិច ១២០រូប ដែលត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមាន៖

- សិទ្ធិបោះឆ្នោត
- មានអាយុយ៉ាងតិច ២៥ ឆ្នាំ
- មានសញ្ជាតិខ្មែរតាំងពីកំណើត
- លក្ខខណ្ឌមួយចំនួនទៀត មានកំណត់ក្នុងច្បាប់បោះឆ្នោត ។

រដ្ឋសភានីតិកាលទី៦ កើតចេញពីការបោះឆ្នោតសកល កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ តាមប្រព័ន្ធសមាមាត្រ មាន ២៥ រាជធានី.ខេត្ត ជាមណ្ឌលបោះឆ្នោត (មានខេត្តមួយទើបបង្កើតថ្មី គឺខេត្តត្បូងឃ្មុំ) ដោយមានគណបក្សនយោបាយចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតចំនួន២០។

ប្រជាពលរដ្ឋ បានចុះឈ្មោះបោះឆ្នោតចំនួន ៨.៣៨០.២១៧នាក់ និងប្រជាពលរដ្ឋបានទៅបោះឆ្នោតចំនួន ៦.៩៥៦.៩០០នាក់ ស្មើនឹង ៨៣.០២% ។

គណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាចំនួន ១ គឺគណបក្សប្រជាជនកម្ពុជា មាន១២៥អាសនៈ ស្មើនឹង១០០%។

តំណាងរាស្ត្រសរុប**ចំនួន ១២៥រូប ក្នុងនោះតំណាងរាស្ត្រស្ត្រី ២៦រូប ស្មើនឹង ២០,៩%** តំណាងរាស្ត្រជនជាតិភាគតិចចំនួន ៧រូប។

## ២. សមាសភាពតាមមណ្ឌល

| ល.រ. | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ | មណ្ឌល | ផ្សេងៗ |
|---|---|---|---|---|
| ១ | ឯកឧត្តម កែ គឹមយ៉ាន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ២ | ឯកឧត្តម គោ ស៊ុំ សារឿត | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៣ | ឯកឧត្តម ប៉ាល់ សំអឿន | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៤ | លោកជំទាវ នួម សុភ័ណ | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៥ | ឯកឧត្តម សេរី កុសល | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៦ | ឯកឧត្តម អ៊ី ឡុង | ប្រជាជនកម្ពុជា | បន្ទាយមានជ័យ | |
| ៧ | សម្តេចក្រឡាហោម ស ខេង | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៨ | ឯកឧត្តម ងិន ឃន | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ៩ | លោកជំទាវ លី គឹមលៀង | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១០ | ឯកឧត្តម ឈាង វុន | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១១ | ឯកឧត្តម ឡោក ហ៊ួរ | ប្រជាជនកម្ពុជា | បាត់ដំបង | |
| ១២ | ឯកឧត្តម ភួ ពុយ | ប្រជាជនកម្ពុជា | បាត់ដំបង | |

| | | | |
|---|---|---|---|
| ១៣ | ឯកឧត្តម សៀង ស៊ុតថង | ប្រជាជនកម្ពុជា | បាត់ដំបង |
| ១៤ | ឯកឧត្តម ច័ន្ទ សុផល | ប្រជាជនកម្ពុជា | បាត់ដំបង |
| ១៥ | ឯកឧត្តម យឹម ឆៃលី | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៦ | ឯកឧត្តម ហ៊ុន ណេង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៧ | ឯកឧត្តម ម៉ា ឈឿន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៨ | ឯកឧត្តម អ៊ី សំអុល | ប្រជាជនកម្ពុជា | កំពង់ចាម |
| ១៩ | លោកជំទាវ ស្រី គឹមឆយ | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២០ | លោកជំទាវ ខុង ស៊ុនអេង | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២១ | ឯកឧត្តម លន់ លឹមថៃ | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២២ | លោកជំទាវ កុល ធារិន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៣ | ឯកឧត្តម ង៉ួន សុជាតិ | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៤ | ឯកឧត្តម ង៉ួន ស៊ីមអាន | ប្រជាជនកម្ពុជា | កំពង់ចាម |
| ២៥ | សម្តេចអគ្គមហាពញាចក្រី ហេង សំរិន | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ២៦ | ឯកឧត្តម ជា សុផារ៉ា | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ២៧ | ឯកឧត្តម យិន ប៊ុនណាង | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ២៨ | ឯកឧត្តម សន សារ៉ាណា | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ២៩ | ឯកឧត្តមបណ្ឌិត ចាយ បូរិន | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ៣០ | ឯកឧត្តម កែវ ពិសិដ្ឋ | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ៣១ | ឯកឧត្តម ប្រាជ្ញ ចន្ទ | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ៣២ | ឯកឧត្តម ម៉ូត យូសុះ | ប្រជាជនកម្ពុជា | ត្បូងឃ្មុំ |
| ៣៣ | សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីវង្ការ គង់ សំអុល | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |
| ៣៤ | លោកជំទាវ កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |
| ៣៥ | ឯកឧត្តម ឌួង ស៊ុវ៉ាង | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |
| ៣៦ | លោកជំទាវ កុប ម៉ារីយ៉ាស | ប្រជាជនកម្ពុជា | កំពង់ឆ្នាំង |

| | | | |
|---|---|---|---|
| ៣៧ | ឯកឧត្តម អ៊ូ សំអួន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៣៨ | ឯកឧត្តម ហ៊ុន ម៉ានី | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៣៩ | ឯកឧត្តម សត្យា វុធ | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤០ | ឯកឧត្តម សុខ ប៊ិន | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤១ | ឯកឧត្តម សំ រិទ្ធី | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤២ | ឯកឧត្តម តុង សេង | ប្រជាជនកម្ពុជា | កំពង់ស្ពឺ |
| ៤៣ | ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ង្លួន ញ៉ិល | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៤ | លោកជំទាវ លឹម ផល្លា | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៥ | ឯកឧត្តម ជា អឿង | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៦ | ឯកឧត្តម ឃឹម លាត | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៧ | ឯកឧត្តម ឃឹង នុភាព | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៨ | ឯកឧត្តម នង វាសនា | ប្រជាជនកម្ពុជា | កំពង់ធំ |
| ៤៩ | ឯកឧត្តម ប៉ែន ស៊ីម៉ន | ប្រជាជនកម្ពុជា | កំពត |
| ៥០ | លោកជំទាវ អ៊ុន សុគន្ធា | ប្រជាជនកម្ពុជា | កំពត |
| ៥១ | ឯកឧត្តម សោម ចិន | ប្រជាជនកម្ពុជា | កំពត |
| ៥២ | ឯកឧត្តម នឹម ច័ន្ទតារា | ប្រជាជនកម្ពុជា | កំពត |
| ៥៣ | ឯកឧត្តម កៀង វ៉ាង | ប្រជាជនកម្ពុជា | កំពត |
| ៥៤ | ឯកឧត្តម ម៉ាត់ សេត | ប្រជាជនកម្ពុជា | កំពត |
| ៥៥ | សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ប្រជាជនកម្ពុជា | កណ្ដាល |
| ៥៦ | លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី | ប្រជាជនកម្ពុជា | កណ្ដាល |
| ៥៧ | ឯកឧត្តម ប្រាក់ សុខុន | ប្រជាជនកម្ពុជា | កណ្ដាល |
| ៥៨ | ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | ប្រជាជនកម្ពុជា | កណ្ដាល |
| ៥៩ | ឯកឧត្តម ង៉ោ សុវណ្ណ | ប្រជាជនកម្ពុជា | កណ្ដាល |

| | | | | |
|---|---|---|---|---|
| ៦០ | ឯកឧត្តម អ៊ុក ដាមរី | ប្រជាជនកម្ពុជា | កណ្ដាល | |
| ៦១ | ឯកឧត្តម ឱុល គឿន | ប្រជាជនកម្ពុជា | កណ្ដាល | |
| ៦២ | ឯកឧត្តម សុះ មុះសិន | ប្រជាជនកម្ពុជា | កណ្ដាល | |
| ៦៣ | ឯកឧត្តមបណ្ឌិត ឈុន ស៊ីរុន | ប្រជាជនកម្ពុជា | កណ្ដាល | |
| ៦៤ | ឯកឧត្តម ជឹម សុខខុន | ប្រជាជនកម្ពុជា | កណ្ដាល | |
| ៦៥ | ឯកឧត្តម ទី សុគន្ធ | ប្រជាជនកម្ពុជា | កណ្ដាល | |
| ៦៦ | ឯកឧត្តម ជុំ យុហៀន | ប្រជាជនកម្ពុជា | កោះកុង | |
| ៦៧ | លោកជំទាវ ស៊ុន សាគឿន | ប្រជាជនកម្ពុជា | ក្រចេះ | |
| ៦៨ | ឯកឧត្តម សរ ចំរុង | ប្រជាជនកម្ពុជា | ក្រចេះ | |
| ៦៩ | លោកជំទាវ ត្រឹង ថារី | ប្រជាជនកម្ពុជា | ក្រចេះ | |
| ៧០ | ឯកឧត្តម ចាន់ យឿន | ប្រជាជនកម្ពុជា | មណ្ឌលគិរី | |
| ៧១ | លោកជំទាវ គឹម សុវណ្ណា | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | ជំនួស ឯកឧត្តម ប៉ា សុជាតិវង្ស |
| ៧២ | ឯកឧត្តម សួន រិនឌី | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៣ | ឯកឧត្តម ឃុត ចាន់ដារ៉ា | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៤ | លោកជំទាវ ម៉ក់ វណ្ណសុីថា | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៥ | ឯកឧត្តម កែប ជុតិមា | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៦ | ឯកឧត្តម ហ៊ូ ស្រ៊ី | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៧ | លោកជំទាវ គ្រួច សំអាន | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៨ | លោកជំទាវ ឡោក ខេង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៧៩ | លោកជំទាវ ម៉ាណ ណាវី | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៨០ | ឯកឧត្តម ជៀប ស៊ីវន | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៨១ | ឯកឧត្តម ពេជ្រ គឹមស្រ៊ាង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៨២ | ឯកឧត្តមបណ្ឌិត លី ឆេង | ប្រជាជនកម្ពុជា | រាជធានីភ្នំពេញ | |
| ៨៣ | ឯកឧត្តម សួស យ៉ារ៉ា | ប្រជាជនកម្ពុជា | ព្រះវិហារ | |
| ៨៤ | ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប | ប្រជាជនកម្ពុជា | ព្រៃវែង | |

| | | | | |
|---|---|---|---|---|
| ៨៥ | ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៦ | ឯកឧត្តម ជាម ប៉េអា | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៧ | ឯកឧត្តម ទេព សាម៉ន | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៨ | ឯកឧត្តម មុំម សុីបុន | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៨៩ | ឯកឧត្តម ឡុង ប៊ុន្នី | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៩០ | ឯកឧត្តម ពេជ្រ ជីវ៉ន | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៩១ | ឯកឧត្តម ហោង វរលក្ខណ៍ | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៩២ | ឯកឧត្តម ខៀវ ភារិទ្ធ | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៩៣ | លោកជំទាវ គង់ សាឡុន | ប្រជាជនកម្ពុជា | ព្រៃវែង | |
| ៩៤ | ឯកឧត្តម សុខ ផេង | ប្រជាជនកម្ពុជា | ព្រៃវែង | ជំនួស ឯកឧត្តម ពៅ សាមី |
| ៩៥ | ឯកឧត្តម សារី កោសល្យ | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | |
| ៩៦ | ឯកឧត្តម រ៉ូហ្វី អូស្មាន | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | |
| ៩៧ | ឯកឧត្តម ខូយ សុខា | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | |
| ៩៨ | លោកជំទាវ ឯម ប៉ុណ្ណា | ប្រជាជនកម្ពុជា | ពោធិ៍សាត់ | |
| ៩៩ | ឯកឧត្តម ប៊ូ ឡាំ | ប្រជាជនកម្ពុជា | រតនគិរី | |
| ១០០ | សម្តេចពិជ័យសេនា ទៀ បាញ់ | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០១ | ឯកឧត្តម សៀង ណាំ | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០២ | ឯកឧត្តម ឈឹម ម៉ា | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០៣ | លោកជំទាវ ពៅ សាវឿន | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០៤ | ឯកឧត្តម ទូ ផល្លា | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០៥ | ឯកឧត្តម យិន គឹមស៊ាន | ប្រជាជនកម្ពុជា | សៀមរាប | |
| ១០៦ | ឯកឧត្តម នេន ម៉ាល័យ | ប្រជាជនកម្ពុជា | ព្រះសីហនុ | |
| ១០៧ | ឯកឧត្តម តាក វណ្ណថា | ប្រជាជនកម្ពុជា | ព្រះសីហនុ | |

| | | | | |
|---|---|---|---|---|
| ១០៨ | ឯកឧត្តម ចេវ គឹមហេង | ប្រជាជនកម្ពុជា | ព្រះសីហនុ | |
| ១០៩ | ឯកឧត្តម ឡូយ សុផាត | ប្រជាជនកម្ពុជា | ស្ទឹងត្រែង | |
| ១១០ | លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១១ | លោកជំទាវ ដួង វណ្ណា | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១២ | ឯកឧត្តម ជ័យ សុន | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១៣ | លោកជំទាវ ឈុន សារឹម | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១៤ | លោកជំទាវ ពៅ សុភាព | ប្រជាជនកម្ពុជា | ស្វាយរៀង | |
| ១១៥ | ឯកឧត្តម ប៊ិន ឈិន | ប្រជាជនកម្ពុជា | តាកែវ | |
| ១១៦ | លោកជំទាវ និន សាផុន | ប្រជាជនកម្ពុជា | តាកែវ | |
| ១១៧ | ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត | ប្រជាជនកម្ពុជា | តាកែវ | |
| ១១៨ | ឯកឧត្តម លី ស៊ុគ្រី | ប្រជាជនកម្ពុជា | តាកែវ | ជំនួស ឯ.ឧ សុខ សុកាន ២៩.១២.២០ |
| ១១៩ | លោកជំទាវ នូ សុវណ្ណទី | ប្រជាជនកម្ពុជា | តាកែវ | ជំនួស ឯ.ឧ ជា វ៉ាន់ដេត ១០.០៤.២០ |
| ១២០ | ឯកឧត្តម ស៊ូ ភិរិន្ទ | ប្រជាជនកម្ពុជា | តាកែវ | |
| ១២១ | ឯកឧត្តម ច័ន្ទ សារុន | ប្រជាជនកម្ពុជា | តាកែវ | |
| ១២២ | ឯកឧត្តម អ៊ិត សុខ | ប្រជាជនកម្ពុជា | តាកែវ | |
| ១២៣ | ឯកឧត្តម ង្វន ប៊ឿន | ប្រជាជនកម្ពុជា | កែប | |
| ១២៤ | ឯកឧត្តម សៅ សារ៉ាត់ | ប្រជាជនកម្ពុជា | ប៉ៃលិន | ជំនួស ល.ជ បាន ស្រីមុំ ២៩.១២.២០ |
| ១២៥ | ឯកឧត្តម នៅ សំ | ប្រជាជនកម្ពុជា | ឧត្តរមានជ័យ | |

# នីតិកាលទី ៦ នៃរដ្ឋសភា (២០១៨-២០២៣)



## ៣. រចនាសម្ព័ន្ធរដ្ឋសភា

**អង្គការលេខរបស់រដ្ឋសភា**




### ក. ថ្នាក់ដឹកនាំរដ្ឋសភា

ថ្នាក់ដឹកនាំរដ្ឋសភាមាន ប្រធានរដ្ឋសភា អនុប្រធានទី១ រដ្ឋសភា និងអនុប្រធានទី២ រដ្ឋសភា។

### ខ. គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មាន

- ប្រធានរដ្ឋសភា
- អនុប្រធានទាំងពីរ នៃរដ្ឋសភា
- ប្រធានគណៈកម្មការនានានៃរដ្ឋសភា ។



ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នីតិកាលទី៦

### គ. គណៈកម្មការនានានៃរដ្ឋសភា

គណៈកម្មការជំនាញនៃរដ្ឋសភា មានចំនួន ១០ ។

១. គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា
២. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៣. គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
៤. គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ
៥. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦. គណៈកម្មការនីតិកម្ម និងយុត្តិធម៌
៧. គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍
៨. គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាល វិជ្ជាជីវៈ និងកិច្ចការនារី
៩. គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១០.គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ

**នៅក្នុងគណៈកម្មការនីមួយៗមានសមាជិកចំនួន ៩រូប ដែលរួមមាន៖**

| | |
|---|---|
| ប្រធានគណៈកម្មការ | ចំនួន ១រូប |
| អនុប្រធានគណៈកម្មការ | ចំនួន ១រូប |
| លេខាធិការគណៈកម្មការ | ចំនួន ១រូប |
| សមាជិកគណៈកម្មការ | ចំនួន ៦រូប |

## ៤. តួនាទី ភារកិច្ច និងអភ័យឯកសិទ្ធិសភា

### ក. តួនាទី ភារកិច្ច

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបាន កំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

តំណាងរាស្ត្រ ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ដែលមានតួនាទី និងភារកិច្ចដូចតទៅ :

### ក.១. តួនាទីការធ្វើច្បាប់ ( នីតិកម្ម)



ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា



ប្រជុំពិនិត្យសេចក្តីព្រាងច្បាប់រវាងគណៈកម្មការនិងក្រសួងជំនាញ



ប្រជុំពេញអង្គរដ្ឋសភា

- សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។
- រដ្ឋសភា អនុម័តច្បាប់ធម្មនុញ្ញតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។
- រដ្ឋសភា អនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ។
- រដ្ឋសភាអនុម័តច្បាប់ស្តីពី ការលើកលែងទោសជាទូទៅ អនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

ការអនុម័តច្បាប់ទាំងឡាយខាងលើនេះ តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

### ក.២. តួនាទីការបោះឆ្នោតទុកចិត្ត និងការបោះឆ្នោតជ្រើសតាំង

- រដ្ឋសភា បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល ឬអនុម័តញត្តិបន្ទោសរាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

- រដ្ឋសភា បោះឆ្នោតជ្រើសតាំងសមាជិកនៃស្ថាប័នមួយចំនួនដូចជា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ៣រូប សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អគ្គសវនករ និងអគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយចំនួន ១រូប សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន ១រូប និងសមាជិកព្រឹទ្ធសភាចំនួន ២រូប ។



ប្រជុំពេញអង្គបោះឆ្នោតទុកចិត្តរដ្ឋាភិបាល នីតិកាលទី៦

## ក.៣. តួនាទីតាមដានការអនុវត្តច្បាប់

- តំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។ រដ្ឋសភា កំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ការឆ្លើយសំណួរ។ទោះបីយ៉ាងណាក៏ដោយសម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ យោងតាម (**រដ្ឋធម្មនុញ្ញ មាត្រា៩៦**)។

- រដ្ឋសភា អាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល ពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកយកមកពិភាក្សាបាន ។



បេសកកម្មតាមដានការអនុវត្តច្បាប់ របស់គណៈកម្មការទី៨ រដ្ឋសភា



បេសកកម្មតាមដានការអនុវត្តច្បាប់ របស់គណៈកម្មការទី៦ រដ្ឋសភា




ការឆ្លើយសំណួរដោយតំណាងរដ្ឋាភិបាលនៅក្នុងពេលប្រជុំពេញអង្គរបស់រដ្ឋសភា

### ក.៤. តួនាទីភាពជាតំណាងប្រជាជាតិ

តំណាងរាស្ត្រ ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ដែលមានតួនាទីដូចតទៅ:

- ស្វែងយល់អំពីសំណូមពរ សំណើ និងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។

(**មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ ចែងថា** សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ) ។

(**មាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា**: ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី )។







ការជួបឈ្វេងយល់ពីស្ថានភាព និងការលំបាករបស់ប្រជាពលរដ្ឋ ដោយសមាជិក សមាជិការដ្ឋសភា

## ខ. អភ័យឯកសិទ្ធិសភា

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែក :

- ការធានាក្នុងការបញ្ចេញយោបល់ ឬការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់តំណាងរាស្ត្រនៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាតំណាងរាស្ត្រគឺជាអភ័យឯកសិទ្ធិដាច់ខាតរបស់តំណាងរាស្ត្រ។
- ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតំណាងរាស្ត្រណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀបរបស់តំណាងរាស្ត្រ។

តំណាងរាស្ត្រមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិក ណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍ របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។



## III. ព្រឹទ្ធសភានីតិកាលបច្ចុប្បន្ន



ព្រឹទ្ធសភានីតិកាលទី២



ព្រឹទ្ធសភានីតិកាលទី៤ ក្នុងពិធីសច្ចាប្រណិធាន

## ១. ការចាត់តាំង និងជ្រើសតាំងសមាជិកព្រឹទ្ធសភា

សម្រាប់នីតិកាលទី៤ សមាជិកព្រឹទ្ធសភាសរុបមានចំនួន៦២រូប (បង្កើន០១អាសនៈ នៅមណ្ឌលភូមិភាគទី៧) ក្នុងនោះ ០២រូប ចាត់តាំងដោយព្រះមហាក្សត្រ ០២រូប ជ្រើសតាំងដោយរដ្ឋសភា និង៥៨រូប ជ្រើសតាំងដោយការបោះឆ្នោតជាអសកល ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ព្រឹទ្ធសភានីតិកាលទី៤ បានបើកសម័យប្រជុំដំបូង នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ព្រឹទ្ធសភានីតិកាលទី៤មាន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ជាប្រធាន **ឯកឧត្តម ស៊ឹម កា** ជាអនុប្រធានទី១ និង**ឯកឧត្តម ទេព ង៉ន** ជាអនុប្រធានទី២ ។

**កំណត់សម្គាល់៖**

ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តម ស៊ឹម កា ត្រូវបានព្រឹទ្ធសភា បោះឆ្នោតជ្រើសរើសជាអនុប្រធានទី១ព្រឹទ្ធសភា ជំនួសឯកឧត្តម នៃ ប៉េណា ដែលបានទទួលមរណភាព ។

## ២. សមាសភាពតាមមណ្ឌលភូមិភាគ

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ នីតិកាលទី៤ មានដូចខាងក្រោម៖

**ភូមិភាគទី១ ( រាជធានីភ្នំពេញ )**

| | |
|---|---|
| ១- ឯកឧត្តម ជា ដេជ្ជ | ប្រធាន |
| ២- ឯកឧត្តម ម៉ុម ជឹមហ៊ុយ | អនុប្រធាន |
| ៣- ឯកឧត្តម ម៉ាន់ ឈឿន | លេខាធិការ |
| ៤- សម្តេចវិបុលសេនាភក្តី សាយ ឈុំ | សមាជិក |
| ៥- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា | សមាជិក |
| ៦- លោកជំទាវ ម៉ុំ សណ្តាប់ | សមាជិកា ។ |

**ភូមិភាគទី២ ( ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ )**

| | |
|---|---|
| ១- ឯកឧត្តម អ៊ុក ប៊ុនឈឿន | ប្រធាន |
| ២- ឯកឧត្តម ឈិត គឹមយាត | អនុប្រធាន |
| ៣- ឯកឧត្តម ឆាយ វណ្ណា | លេខាធិការ |
| ៤- ឯកឧត្តម ហេង បូរ៉ា | សមាជិក |
| ៥- ឯកឧត្តម ច្រឹង គឹមស្រ៊ាន | សមាជិក |
| ៦- ឯកឧត្តម ឡាន់ ឆន | សមាជិក |
| ៧- ឯកឧត្តម ជឹម លាវ | សមាជិក |
| ៨- លោកជំទាវ ស៊ី វណ្ណថា | សមាជិកា ។ |

**ភូមិភាគទី៣ ( ខេត្តកណ្តាល )**

| | |
|---|---|
| ១- ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន | ប្រធាន |
| ២- ឯកឧត្តម ប្រាក់ ចំរើន | អនុប្រធាន |
| ៣- ឯកឧត្តម ម៉ម ប៊ុននាង | លេខាធិការ |
| ៤- លោកជំទាវ ទី បូរ៉ាស៊ី | សមាជិកា |
| ៥- ឯកឧត្តម ឡាវ ម៉េងឃីន | សមាជិក ។ |

**ភូមិភាគទី៤ (ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និង ខេត្តប៉ៃលិន)**

| | |
|---|---|
| ១- ឯកឧត្តម ប៉ុល លឹម | ប្រធាន |
| ២- ឯកឧត្តម សួន លន់ | អនុប្រធាន |
| ៣- ឯកឧត្តម ចាន់ ណារ៉េត | លេខាធិការ |
| ៤- ឯកឧត្តម អន ស៊ុំ | សមាជិក |
| ៥- ឯកឧត្តម ណាំ ទុំ | សមាជិក |
| ៦- ឯកឧត្តម អ៊ុក គង់ | សមាជិក |
| ៧- លោកជំទាវ ឯម ផលាមុនី | សមាជិក |
| ៨- ឯកឧត្តម ឈើយ ចាន់ណា | សមាជិក |
| ៩- ឯកឧត្តម សត ណាឌី | សមាជិក |
| ១០- ឯកឧត្តម ឡៅ ធន | សមាជិក ។ |

**ភូមិភាគទី៥ (ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប)**

| | |
|---|---|
| ១- ឯកឧត្តម ខៀវ មុត | ប្រធាន |
| ២- ឯកឧត្តម គិន ណៃត | អនុប្រធាន |
| ៣- ឯកឧត្តម ទេព យុទ្ធី | លេខាធិការ |
| ៤- ឯកឧត្តម កុក អាន | សមាជិក |
| ៥- ឯកឧត្តម ស្រី បេន | សមាជិក |
| ៦- ឯកឧត្តម លី សារី | សមាជិក |
| ៧- លោកជំទាវ កង់ សៅវ៉ធន | សមាជិកា ។ |

**ភូមិភាគទី៦ (ខេត្តព្រៃវែង និងខេត្តស្វាយរៀង)**

| | |
|---|---|
| ១- លោកជំទាវ មាន សំអាន | ប្រធាន |
| ២- ឯកឧត្តម សុខ ឥសាន | អនុប្រធាន |

៣- ឯកឧត្តម ឈួន ឡេង — លេខាធិការ

៤- ឯកឧត្តម គឹម ជា — សមាជិក

៥- ឯកឧត្តម ម៉ែន ស៊ីផាន់ — សមាជិក

៦- ឯកឧត្តម ទឹម ផន — សមាជិក

៧- ឯកឧត្តម សុខ យាត — សមាជិក ។

**ភូមិភាគទី៧ ( ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ )**

១- ឯកឧត្តម គង់ សារាជ — ប្រធាន

២- ឯកឧត្តម ហែម ខន — អនុប្រធាន

៣- ឯកឧត្តម ថុង ចន់ — លេខាធិកា

៤- ឯកឧត្តម អាយ ខន — សមាជិក

៥- ឯកឧត្តម លី យ៉ុងផាត់ — សមាជិក

៦- ឯកឧត្តម ម៉ុង ឫទ្ធី — សមាជិក

៧- ឯកឧត្តម សាយ បូរិន — សមាជិក

៨- ឯកឧត្តម អ៊ឹង លាងហ៊ួ — សមាជិក

៩- ឯកឧត្តម ញ៉ូវ សុង — សមាជិក ។

**ភូមិភាគទី៨ ( ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី )**

១- ឯកឧត្តម យ៉ង់ សែម — ប្រធាន

២- ឯកឧត្តម មួង ប៉យ — អនុប្រធាន

៣- ឯកឧត្តម ញ៉ែម សាម៉ន — លេខាធិការ

៤- លោកជំទាវ ឃួន ឃុនឌី — សមាជិកា

៥- លោកជំទាវ ឱ សុខុម — សមាជិកា

៦- ឯកឧត្តម ណាយ ស្រួន — សមាជិក ។

# នីតិកាលទី ៤ ព្រឹទ្ធសភា (២០១៨-២០២៤)

ការបោះឆ្នោតចុងក្រោយ៖
**២៣ មេសា ២០១៨**

អាណត្តិ៖ **៦ឆ្នាំ**



## ៣. រចនាសម្ព័ន្ធព្រឹទ្ធសភា

ព្រឹទ្ធសភាមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ មានភារកិច្ច ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់សកម្មភាពផ្សេងៗរបស់ព្រឹទ្ធសភា ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុង ព្រមទាំងមានគណៈកម្មការនានា ដែលទទួលបន្ទុកការងារតាមវិស័យជាសមត្ថកិច្ច ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មានប្រធានព្រឹទ្ធសភាជាប្រធាន និងមានអនុប្រធានទាំងពីរនៃព្រឹទ្ធសភា និងប្រធានគណៈកម្មការនានាជាសមាជិក ។

គណៈកម្មការនានារបស់ព្រឹទ្ធសភា ប្រតិបត្តិការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។




តាមបញ្ញត្តិ ចំណុច (ខ) នៃប្រការ១១ ប្រការ៣៨ និងប្រការ៧៧ស្ទួន នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ព្រឹទ្ធសភាមានយន្តការផ្សេងៗជាអាទិ៍ៈ ក្រុមសមាជិកព្រឹទ្ធសភា គណៈកម្មការក្រុមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រឹទ្ធសភា អ្នកនាំពាក្យព្រឹទ្ធសភា ក្រុមមិត្តភាពព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាជាមួយសភាបណ្ដាប្រទេស និងក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយបណ្ដាស្ថាប័នអន្តរសភា ។

ការរៀបចំ ការប្រព្រឹត្តទៅ និងដំណើរការរៀបចំរបស់ក្រុមទាំងនេះ អនុវត្តទៅតាមតួនាទីភារកិច្ច និងសមត្ថកិច្ចដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

## ៤. តួនាទី ភារកិច្ច និងអភ័យឯកសិទ្ធិសភា

### ក. តួនាទី ភារកិច្ច

#### ក.១. តួនាទី

*យោងមាត្រា១១២ថ្មី នៃរដ្ឋធម្មនុញ្ញ ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ។*

#### ក.២. ភារកិច្ច

*ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញកិច្ចការរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន (វាក្យខ័ណ្ឌទី១ មាត្រា៩៩ថ្មី នៃរដ្ឋធម្មនុញ្ញ) ។*

*ក្នុងនាមជាចំណែកមួយនៃអង្គនីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានមុខងារសំខាន់ៗបី ដូចខាងក្រោម៖*

### ខ. មុខងារ

#### ខ.១. មុខងារនីតិកម្ម

*យោងតាមមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលរដ្ឋសភាបញ្ជូនមក ។*



*ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*



ប្រជុំពិនិត្យសេចក្តីព្រាងច្បាប់រវាងគណៈកម្មការនិងក្រសួងជំនាញ




ប្រជុំពេញអង្គព្រឹទ្ធសភា

### ខ.២. មុខងារតាមដានការអនុវត្តច្បាប់

ដើម្បីបំពេញមុខងារតាមដានការអនុវត្តច្បាប់ ព្រឹទ្ធសភាមានគណៈកម្មការចំនួន១០ ទទួលខុសត្រូវតាមវិស័យជាសមត្ថកិច្ចរបស់ខ្លួន ។ គណៈកម្មការនីមួយៗ បំពេញការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ច ដែលកំណត់ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ។ គណៈកម្មការនីមួយៗ មានផែនការសកម្មភាពរបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ។ ជាពិសេសនៅចន្លោះសម័យប្រជុំនីមួយៗ គណៈកម្មការតែងចុះទៅបំពេញមុខងារនេះ តាមក្រសួង មន្ទីរ រាជធានី ខេត្ត ដើម្បីពិនិត្យមើលការអនុវត្តច្បាប់ និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច ។



បេសកកម្មតាមដានការអនុវត្តច្បាប់របស់គណៈកម្មការទី៦ ព្រឹទ្ធសភា



បេសកកម្មតាមដានការអនុវត្តច្បាប់របស់គណៈកម្មការទី១ ព្រឹទ្ធសភា




*បេសកកម្មតាមដានការអនុវត្តច្បាប់របស់គណៈកម្មការទី៧ ព្រឹទ្ធសភា*

### ខ.៣. មុខងារតំណាង

*យោងតាមមាត្រា២ នៃច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភាចែងថា សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ ។*

*មាត្រា១០ នៃច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាចែងថា អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។*

*ភាពជាតំណាង ក្រុមប្រឹក្សាឃុំសង្កាត់ នាំឱ្យព្រឹទ្ធសភាមានបេសកកម្មផ្ទាល់របស់ខ្លួនក្នុងលក្ខណៈជាពិសេសមួយ ដោយត្រូវផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងកិច្ចការពារ និងលើកតម្កើងផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស រួមទាំងភូមិភាគទាំង៨ទៀតផង ។ ដូច្នេះ ព្រឹទ្ធសភាមានកាតព្វកិច្ចចូលរួមចំណែកយ៉ាងខ្ជាប់ខ្ជួន ក្នុងការតាមដានមើលការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ពោលគឺជួយជំរុញធ្វើឲ្យមានការអភិវឌ្ឍបានត្រឹមត្រូវ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។*





ការជួបឈ្វេងយល់ពីស្ថានភាព និងការលំបាករបស់ប្រជាពលរដ្ឋ ដោយសមាជិក សមាជិកាព្រឹទ្ធសភា

ក្រៅពីមុខងារស្នូលទាំងបីខាងលើ ព្រឹទ្ធសភាមានមុខងារពីរបន្ថែមទៀត គឺ៖

### ២.៤. មុខងារសហប្រតិបត្តិការអន្តរជាតិ

ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រឹទ្ធសភាបានបំពេញការងារយ៉ាងសកម្ម ក្នុងការចូលរួមអនុវត្តកាតព្វកិច្ចអន្តរជាតិ និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសភា និងអង្គការសភានានាក្នុងតំបន់ និងពិភពលោក ។ ក្នុងគ្រប់នីតិកាល ព្រឹទ្ធសភាបានចាត់ទុកកិច្ចសហ ប្រតិបត្តិការអន្តរជាតិ ជាកម្លាំងស្នូលនៃការអភិវឌ្ឍស្ថាប័ន ។







*ការចូលរួមប្រជុំនៅលើឆាកអន្តរជាតិ ដើម្បីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍស្ថាប័ន*

## ១.៩. មុខងារអភិវឌ្ឍន៍ស្ថាប័ន

ព្រឹទ្ធសភា មានមោទនភាពលើសមិទ្ធផលជាស្នាដៃ នៃការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អគ្គលេខាធិការដ្ឋាន គួបផ្សំនឹងកិច្ចសហប្រតិបត្តិការដ៏មានតម្លៃ ទាំងពហុរូបភាព និងពហុវិស័យ ដែលមិនអាចខ្វះបានពីដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញ និងពង្រឹងសមត្ថភាពព្រឹទ្ធសភាទាំងផ្នែកធនធានមនុស្ស និងការអភិវឌ្ឍស្ថាប័ន ។







*អគារនានាជាជំនួយរបស់ប្រទេសជាមិត្ត*

## គ. អភ័យឯកសិទ្ធិសភា

យោងមាត្រា៤ នៃច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភាចែងថា សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែក គឺ ៖

### គ.១. អភ័យឯកសិទ្ធិដាច់ខាត

ជាការធានាក្នុងការបញ្ចេញយោបល់ ឬការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់សមាជិកព្រឹទ្ធសភា នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា ។

### គ.២. អភ័យឯកសិទ្ធិដោយប្រៀប

ជាការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ ។

សមាជិកព្រឹទ្ធសភា មិនអាចធ្វៀតប្រើអភ័យឯកសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ (មាត្រា៩ នៃច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភា)។

ប្រសិនបើបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន (មាត្រា៧ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា) ។

ការស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានព្រឹទ្ធសភា (មាត្រា៨ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា) ។

# IV. គណៈកម្មការសភា

## ១. គណៈកម្មការរដ្ឋសភា

### ១.១. ការបង្កើត

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋសភា នឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

រដ្ឋសភាអាចតាំងគណៈកម្មការពិសេសដែលមានសមាជិកច្រើន ឬតិចតាមតម្រូវការៗ យោងប្រការ៦ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា គណៈកម្មការនានា នៃរដ្ឋសភាមានចំនួន ១០ គឺ :

សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

### ១.២. របនាសម្ព័ន្ធ

គណៈកម្មការនីមួយៗមានសមាជិកយ៉ាងតិច ៧រូប ។ តំណាងរាស្ត្រមួយរូប អាចជាសមាជិកពីរគណៈកម្មការបាន ។

គណៈកម្មការនីមួយៗត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និង លេខាធិការមួយរូប ដោយវិធីបោះឆ្នោត ។

### ១.៣. តួនាទី ភារកិច្ច

គណៈកម្មការនានានៃរដ្ឋសភាជាសេនាធិការរបស់រដ្ឋសភាក្នុងការប្រតិបត្តិអំណាចនីតិប្បញ្ញត្តិស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន មានភារកិច្ចរួមដូចតទៅ:

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូនតាមមុខជំនាញ ។ គណៈកម្មការជម្រាបជូនសម័យប្រជុំរដ្ឋសភាអំពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់។

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ។ល ។

- ធ្វើការទំនាក់ទំនង ផ្នែកការទូតសភាដោយពង្រឹង សហប្រតិបត្តិការជាមួយគណៈកម្មការសភា នៃបណ្តាប្រទេសនានា ដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែក នីតិប្បញ្ញត្តិ ។ រួមចំណែកក្នុងការពង្រឹង និងពង្រីកសហប្រតិបត្តិការមានផលប្រយោជន៍ទៅវិញទៅមកជាមួយដៃគូអភិវឌ្ឍន៍ ។

- អញ្ជើញរដ្ឋមន្ត្រី ឬវរជនមកបំភ្លឺអំពីបញ្ហាអ្វីមួយ ពាក់ព័ន្ធនឹងវិស័យដែលខ្លួនទទួលខុសត្រូវ ។

- ចុះបំពេញបេសកកម្មតាមរាជធានី និងបណ្តាខេត្ត ព្រមទាំងស្ថាប័នពាក់ព័ន្ធ ។

- ជំរុញស្ថាប័នពាក់ព័ន្ធឱ្យកសាងផែនការច្បាស់លាស់ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់។

- ពិនិត្យនិងលើកសំណើវិសោធនកម្មច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត ដែលមិនសមស្របនឹងស្ថានភាពជាក់ស្តែង សំដៅធ្វើឱ្យមានសុខដុមនីយកម្មជាមួយច្បាប់ជាតិ និងអន្តរជាតិ ។
- ពិនិត្យដោះស្រាយសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋ ។ រួមចំណែកពង្រឹងការគោរព ប្រតិបត្តិច្បាប់ ទន្ទឹមនឹងពង្រីកការផ្សព្វផ្សាយព័ត៌មាន ច្បាប់ និងលើកកម្ពស់ការយល់ដឹងលើវិស័យច្បាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ ។ លើកទឹកចិត្តឱ្យមានការចូលរួមដោយសកម្មពីសំណាក់សាធារណជន ក្នុងវេទិកានានាសំដៅឆ្លើយតបទៅនឹងសំណូមពរព្រមទាំងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ។
- ទទួល និងពិនិត្យ ពាក្យបណ្តឹង និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ តាមវិស័យទទួលខុសត្រូវរបស់គណៈកម្មការ និងលើកសំណើតាមរយៈប្រធានរដ្ឋសភាជូនក្រសួងពាក់ព័ន្ធពិចារណា និងដោះស្រាយ។

## សមាសភាពនៅក្នុងគណៈកម្មការជំនាញនីមួយៗ

| គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា (គណៈកម្មការទី១) | |
|---|---|
| ឯកឧត្តម ប្រាជ្ញ ចន្ទ | ប្រធាន |
| លោកជំទាវ ឯម ប៉ុណ្ណា | អនុប្រធាន |
| ឯកឧត្តម សរ ចំរុង | លេខាធិការ |
| ឯកឧត្តម ម៉ុម ស៊ីប៊ុន | សមាជិក |
| លោកជំទាវ ឈុន សារឹម | សមាជិកា |
| ឯកឧត្តម អ៊ី ឡុង | សមាជិក |
| លោកជំទាវ ស្រី គឹមឆយ | សមាជិកា |
| ឯកឧត្តម សួន រិនឌី | សមាជិក |
| ឯកឧត្តម ម៉ូត យូសុះ | សមាជិក |

| គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២) | |
|---|---|
| ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប | ប្រធាន |
| ឯកឧត្តម ចាយ បូរិន | អនុប្រធាន |
| លោកជំទាវ លី គឹមលៀង | លេខាធិការ |
| ឯកឧត្តម ឈឹម ម៉ា | សមាជិក |
| ឯកឧត្តម ស៊ូ ភិរិន្ទ | សមាជិក |
| ឯកឧត្តម ងិន ឃន | សមាជិក |
| ឯកឧត្តម អ៊ុំ សំអួន | សមាជិក |
| លោកជំទាវ កុល ធារិន | សមាជិកា |
| ឯកឧត្តម យឹម លាត | សមាជិក |
| **គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក (គណៈកម្មការទី៣)** | |
| ឯកឧត្តម ឡូយ សុផាត | ប្រធាន |
| ឯកឧត្តម ហ៊ូ ស្រ៊ី | អនុប្រធាន |
| ឯកឧត្តម លន់ លឹមថៃ | លេខាធិការ |
| ឯកឧត្តម ជា អឿង | សមាជិក |
| ឯកឧត្តម ឃុត ចាន់ដារ៉ា | សមាជិក |
| ឯកឧត្តម សៀង ស៊ិតថង | សមាជិក |
| ឯកឧត្តម ខួយ សុខា | សមាជិក |
| ឯកឧត្តម ជឹម សុខខុន | សមាជិក |
| ឯកឧត្តម សន សារ៉ាណា | សមាជិក |
| **គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ (គណៈកម្មការទី៤)** | |
| ឯកឧត្តម ហ៊ុន ណេង | ប្រធាន |
| ឯកឧត្តម ច័ន្ទ សុផល | អនុប្រធាន |
| លោកជំទាវ អ៊ុន សុគន្ធា | លេខាធិការ |
| ឯកឧត្តម សត្យា វុធ | សមាជិក |

| | |
|---|---|
| ឯកឧត្តម ប៊ូ ឡាំ | សមាជិក |
| ឯកឧត្តម នៅ សំ | សមាជិក |
| លោកជំទាវ ខុង ស៊ុនអេង | សមាជិកា |
| ឯកឧត្តម ឡុង ប៊ុន្នី | សមាជិក |
| ឯកឧត្តម នូ ផល្លា | សមាជិក |
| **គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន (គណៈកម្មការទី៥)** | |
| ឯកឧត្តម ឈាង វុន | ប្រធាន |
| ឯកឧត្តម សួស យ៉ារ៉ា | អនុប្រធាន |
| ឯកឧត្តម ទឹម ច័ន្ទតារា | លេខាធិការ |
| ឯកឧត្តម ទី សុគន្ធ | សមាជិក |
| ឯកឧត្តម ងួន សុជាតិ | សមាជិក |
| ឯកឧត្តម យិន គឹមស៊ាន | សមាជិក |
| លោកជំទាវ កុប ម៉ារីយ៉ាស | សមាជិកា |
| ឯកឧត្តម ជាម ប៉េអា | សមាជិក |
| ឯកឧត្តម ជុំ យុហៀន | សមាជិក |
| **គណៈកម្មការនីតិកម្ម និងយុត្តិធម៌ (គណៈកម្មការទី៦)** | |
| ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា | ប្រធាន |
| លោកជំទាវ គ្រួច សំអាន | អនុប្រធាន |
| ឯកឧត្តម កែវ ពិសិដ្ឋ | លេខាធិការ |
| ឯកឧត្តម ឡោក ហ៊ួរ | សមាជិក |
| ឯកឧត្តមបណ្ឌិត លី ឆេង | សមាជិក |
| ឯកឧត្តម ង៉ោ សុវណ្ណ | សមាជិក |
| ឯកឧត្តមបណ្ឌិត ម៉ា ឈឿន | សមាជិក |
| ឯកឧត្តម អ៊ិត សុខ | សមាជិក |
| ឯកឧត្តម ថោង វរលក្ខណ៍ | សមាជិក |

| | |
|---|---|
| **គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ (គណៈកម្មការទី៧)** | |
| ឯកឧត្តម ហ៊ុន ម៉ានី | ប្រធាន |
| ឯកឧត្តម សំ រិទ្ធី | អនុប្រធាន |
| ឯកឧត្តម ខៀវ ភារិទ្ធ | លេខាធិការ |
| ឯកឧត្តម សុខ ប៊ិន | សមាជិក |
| លោកជំទាវ នួម សុភ័ណ | សមាជិកា |
| ឯកឧត្តម គោស៊ុំ សារឿត | សមាជិក |
| ឯកឧត្តម ម៉ាត់ សេត | សមាជិក |
| ឯកឧត្តម នេន ម៉ាល័យ | សមាជិក |
| ឯកឧត្តម សារី កោសល្យ | សមាជិក |
| **គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី (គណៈកម្មការទី៨)** | |
| លោកជំទាវ ឡោក ខេង | ប្រធាន |
| ឯកឧត្តម ប៉ាល់ សំអឿន | អនុប្រធាន |
| ឯកឧត្តមបណ្ឌិត ឈុន ស៊ីរុន | លេខាធិការ |
| ឯកឧត្តម ង៉ូន ស៊ីមអាន | សមាជិក |
| ឯកឧត្តម ង៉ូន ប៉ឿន | សមាជិក |
| ឯកឧត្តម សុះ មុះសិន | សមាជិក |
| ឯកឧត្តម ពេជ្រ ជីវ៉ន | សមាជិក |
| លោកជំទាវ ម៉ក់ វណ្ណស៊ីថា | សមាជិកា |
| ឯកឧត្តម ឃឹង នុភាព | សមាជិក |
| **គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (គណៈកម្មការទី៩)** | |
| លោកជំទាវ និន សាផុន | ប្រធាន |
| ឯកឧត្តម កែប ជុតិមា | អនុប្រធាន |

| | |
|---|---|
| លោកជំទាវ កែ ច័ន្ទមុនី | លេខាធិការ |
| លោកជំទាវ ទូ សុវណ្ណនី | សមាជិកា |
| ឯកឧត្តម ពេជ្រ គឹមស្រ៊ាង | សមាជិក |
| ឯកឧត្តម តុង សេង | សមាជិក |
| ឯកឧត្តម តាក វណ្ណថា | សមាជិក |
| ឯកឧត្តម ភូ ពុយ | សមាជិក |
| ឯកឧត្តម នង វាសនា | សមាជិក |
| **គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ (គណៈកម្មការទី១០)** | |
| ឯកឧត្តម បណ្ឌិត ប៉ែន ស៊ីម៉ន | ប្រធាន |
| លោកជំទាវ ត្រឹង ថារី | អនុប្រធាន |
| ឯកឧត្តម ចេវ គឹមហេង | លេខាធិការ |
| លោកជំទាវ ពៅ សារឿន | សមាជិកា |
| ឯកឧត្តម អ៊ុក ដាមរី | សមាជិក |
| ឯកឧត្តម សោម ចិន | សមាជិក |
| ឯកឧត្តម ទេព សាម៉ន | សមាជិក |
| លោកជំទាវ គង់ សាឡុន | សមាជិកា |
| ឯកឧត្តមបណ្ឌិត ជ័យ សុន | សមាជិក |

# ២. គណៈកម្មការព្រឹទ្ធសភា

## ២.១. ការបង្កើត

ព្រឹទ្ធសភាមានគណៈកម្មការនានាចំនួន១០ ត្រូវបានបង្កើតឡើងស្របតាមមាត្រា១១៤ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ និងប្រការ១០ ប្រការ១៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ គណៈកម្មការនីមួយៗ មានសមាជិកចំនួន០៩រូប ។ គណៈកម្មការនីមួយៗ មានប្រធាន១រូប អនុប្រធាន១រូប និងលេខាធិការ១រូប ។

គណៈកម្មការនីមួយៗ ប្រតិបត្តិការការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងមានរបបថវិកាប្រចាំខែ សម្រាប់បំពេញការងារ ដែលកំណត់ដោយគណៈកម្មាធិការ អចិន្ត្រៃយ៍ព្រឹទ្ធសភា ។








## ២.២. រចនាសម្ព័ន្ធ




## ២.៣. តួនាទី ភារកិច្ច និងសមត្ថកិច្ច

### ក. តួនាទី

គណៈកម្មការនានារបស់ព្រឹទ្ធសភា មានតួនាទីជាសេនាធិការក្នុងការជួយទ្រទ្រង់មុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារតំណាង ព្រមទាំងជាទីប្រមូលព័ត៌មាន ដែលពាក់ព័ន្ធនឹងសមត្ថកិច្ច តាមវិស័យរបស់គណៈកម្មការនីមួយៗ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ។

### ខ. ភារកិច្ច

គណៈកម្មការនានារបស់ព្រឹទ្ធសភា មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ពិនិត្យសិក្សា ផ្ដល់យោបល់ និងធ្វើរបាយការណ៍លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ឬបញ្ហាទាំងពួងតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនីមួយៗ រួចរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា

- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីឈ្វេងយល់ជាមុននូវរាល់គំនិតផ្ដួចផ្ដើម និងការសម្រេច លើសេចក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់ឬបញ្ហាទាំងពួង ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ

- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងមកបំភ្លឺចំពោះមុខគណៈកម្មការ

- អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងអង្គការសង្គមស៊ីវិល ចូលរួមផ្តល់យោបល់លើបញ្ហាផ្សេងៗ

- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ឬបញ្ហាទាំងពួង ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំពេញរដ្ឋសភា ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ សំណូមពរឬចំណាប់អារម្មណ៍ផ្សេងៗ បើមាន

- សិក្សាស្រាវជ្រាវ និងប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ គណៈកម្មការ ដើម្បីរាយការណ៍ឬលើយោបល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ឬផ្តល់ជាអនុសាសន៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ

- ធ្វើរបាយការណ៍អំពីព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយធ្វើការវិភាគ និងវាយតម្លៃ បន្ទាប់មករាយការណ៍អំពីលទ្ធផលទាំងនោះជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំពេញរដ្ឋសភា

- ផ្តួចផ្តើមគំនិតរៀបចំពិគ្រោះយោបល់ សិក្ខាសាលា វេទិកាសាធារណៈ បេសកម្ម ក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំពេញរដ្ឋសភា

- ចុះបំពេញបេសកម្មស្វែងរកព័ត៌មានតាមក្រសួង ស្ថាប័ន និងតាមដានការអនុវត្តច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅថ្នាក់ក្រោមជាតិ និងភូមិភាគទាំង៨ បន្ទាប់មកធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំពេញរដ្ឋសភានិង/ឬលើកអនុសាសន៍ ឬធ្វើអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសម្របសម្រួល និង/ឬដោះស្រាយ

- ទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងស្ថានទូតអន្តរជាតិនានា ដើម្បីសិក្សាឈ្វេងយល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ គណៈកម្មការ
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍ សភាប្រទេសនានាក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍និងសិក្សាស្វែងយល់អំពីការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ
- បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន
- គណៈកម្មការ មានសមត្ថកិច្ចប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទដ្ឋានគតិយុត្តនានាជាធរមាន ។

**គណៈកម្មការនានារបស់ព្រឹទ្ធសភារួមមាន៖**

| | | |
|---|---|---|
| **គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា (គណៈកម្មការទី១)** | | |
| ឯកឧត្តម យ៉ង់ សែម | ប្រធាន | 012 707 407 |
| ឯកឧត្តម ខៀវ មុត | អនុប្រធាន | 012 902 963 |
| ឯកឧត្តម ណាំ ទុំ | លេខាធិការ | 012 887 111 |
| ឯកឧត្តម ជុង ចន់ | សមាជិក | 012 527 679 |
| ឯកឧត្តម ជឹម លាវ | សមាជិក | 012 872 733 |
| ឯកឧត្តមបណ្ឌិត ជ័យ សុន | | សមាជិក |
| **គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគា និងសវនកម្ម (គណៈកម្មការទី២)** | | |
| ឯកឧត្តម ជា ដេដ្ឋ | ប្រធាន | 012 946 846 |
| ឯកឧត្តម ឈួន ឡេង | អនុប្រធាន | 011 941 028 |
| ឯកឧត្តម គិន ណែត | លេខាធិការ | 012 954 897 |
| ឯកឧត្តម ហេង បូរ៉ា | សមាជិក | 012 775 252 |
| លោកជំទាវ ឱ សុខុម | សមាជិកា | 012 954 145 |

| | | |
|---|---|---|
| **គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក (គណៈកម្មការទី៣)** | | |
| ឯកឧត្តម ម៉ុង ឫទ្ធី | ប្រធាន | 012 300 099 |
| ឯកឧត្តម ចាន់ ណារ៉េត | អនុប្រធាន | 012 888 626 |
| លោកជំទាវ កង សៅវែន | លេខាធិការ | 097 7777 123 |
| ឯកឧត្តម ប្រឹង គឹមស្រ៊ាន | សមាជិក | 012 339 503 |
| ឯកឧត្តម លី សារី | សមាជិក | 012 246 642 |
| **គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ (គណៈកម្មការទី៤)** | | |
| ឯកឧត្តម សុខ ឥសាន | ប្រធាន | 012 949 414 |
| ឯកឧត្តម ប៉ុល លឹម | អនុប្រធាន | 012 495 992 |
| ឯកឧត្តម អន ស៊ុំ | លេខាធិការ | 012 839 090 |
| ឯកឧត្តម សត ណាឌី | សមាជិក | 012 856 385 |
| ឯកឧត្តម មួង ប៉យ | សមាជិក | 097 2477 777 |
| **គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន (គណៈកម្មការទ៥)** | | |
| លោកជំទាវ ទី បូរ៉ាស៊ី | ប្រធាន | 097 6557 777 |
| ឯកឧត្តម ឈិត គឹមយាត | អនុប្រធាន | 011 822 877 |
| ឯកឧត្តម ឆាយ វណ្ណា | លេខាធិការ | 092 879 797 |
| លោកជំទាវ ឃួន ឃុនឌី | សមាជិកា | 012 782 069 |
| លោកជំទាវ ដា ច័ន្ទទេវី | សមាជិកា | 012 367 712 |
| **គណៈកម្មការនីតិកម្ម និងយុត្តិធម៌ (គណៈកម្មការទី៦)** | | |
| ឯកឧត្តម អ៊ុក ប៊ុនឈឿន | ប្រធាន | 077 888 990 |
| ឯកឧត្តម អាយ ខន | អនុប្រធាន | 098 991 145 |
| ឯកឧត្តម គឹម ជា | លេខាធិការ | 092 999 506 |
| ឯកឧត្តម អ៊ុក គង់ | សមាជិក | 012 770 212 |
| ឯកឧត្តម ស្រី បេន | សមាជិក | 012 402 838 |

| គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ (គណៈកម្មការទី៧) | | |
|---|---|---|
| ឯកឧត្តម ម៉ុម ជីមហ៊ុយ | ប្រធាន | 012 587 106 |
| ឯកឧត្តម ម៉ាន់ ឈឿន | អនុប្រធាន | 012 820 311 |
| ឯកឧត្តម ឈើយ ចាន់ណា | លេខាធិការ | 012 839 009 |
| ឯកឧត្តម សុខ យាត | សមាជិក | 012 962 369 |
| ឯកឧត្តម ឡៅ ធន | សមាជិក | 011 649 950 |
| **គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី (គណៈកម្មការទី៨)** | | |
| លោកជំទាវ មាន សំអាន | ប្រធាន | 012 852 211 |
| ឯកឧត្តម ប្រាក់ ចំរើន | អនុប្រធាន | 012 831 180 |
| លោកជំទាវ មុំ សណ្តាប់ | លេខាធិការ | 012 834 842 |
| ឯកឧត្តម ទេព យុទ្ធី | សមាជិក | 012 330 081 |
| ឯកឧត្តម សាយ បូរិន | សមាជិក | 012 388 127 |
| **គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (គណៈកម្មការទី៩)** | | |
| ឯកឧត្តម គង់ សាភជ | ប្រធាន | 012 555 659 |
| ឯកឧត្តម ម៉ែន ស៊ីផាន់ | អនុប្រធាន | 012 918 836 |
| ឯកឧត្តម ទឹម ផន | លេខាធិការ | 015 300 203 |
| ឯកឧត្តម ញ៉ែម សាម៉ន | សមាជិក | 077 339 966 |
| លោកជំទាវ ស៊ី វណ្ណថា | សមាជិកា | 011 994 199 |
| **គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ (គណៈកម្មការទី១០)** | | |
| ឯកឧត្តម ម៉ម ប៊ុននាង | ប្រធាន | 011 924 727 |
| ឯកឧត្តម ហែម ខន | អនុប្រធាន | 012 830 735 |
| ឯកឧត្តម ឡាន់ ឆន | លេខាធិការ | 097 7775 666 |
| ឯកឧត្តម សួន លន់ | សមាជិក | 012 598 984 |
| លោកជំទាវ ឯម ផលាមុនី | សមាជិកា | 012 895 077 |

# V. ការងារការទូតសភា

ការទូតសភា គឺសំដៅទៅលើសកម្មភាពការងារអន្តរជាតិទាំងឡាយណារបស់សភា ឬសមាជិក សមាជិកាសភា ដែលធ្វើឡើង ដើម្បីបង្កើនការយោគយល់គ្នាទៅវិញទៅមករវាងប្រទេសមួយនឹងប្រទេសមួយ សំដៅជួយពង្រឹងការងារទាំងផ្នែកមុខងារនីតិកម្ម មុខងារត្រួតពិនិត្យការអនុវត្តរបស់រដ្ឋាភិបាល និងមុខងារជាតំណាងរបស់ប្រជាពលរដ្ឋ ក៏ដូចជាជួយបង្កើនធម្មានុភាពប្រជាធិបតេយ្យនៃស្ថាប័នអន្តរសភា។

ជាទូទៅកិច្ចការការទូត ត្រូវបានគេយល់ឃើញថា ជាការងាររបស់ស្ថាប័ននីតិប្រតិបត្តិ ដែលអនុវត្តតាមរយៈក្រសួងការបរទេស និងប្រមុខការទូតប្រចាំប្រទេសនីមួយៗ ។

ប៉ុន្តែនៅទស្សវត្សរ៍ចុងក្រោយនេះ ស្ថាប័ននីតិប្បញ្ញត្តិដែលមានតួនាទីស្នូលជាតំណាងប្រជាជាតិ និងប្រជាពលរដ្ឋទាំងមូល បានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ។

ក្នុងក្របខ័ណ្ឌពហុភាគី សភានៃបណ្ដាប្រទេសក្នុងតំបន់ និងសកលលោក បានធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាដោយបង្កើតជាអង្គការ និងសមាគមសភានានា ។ ជាគោលការណ៍ អង្គការ និងសមាគមសភា បានរៀបចំនូវលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង ដោយកំណត់ អំពីសិទ្ធិ កាតព្វកិច្ច បែបបទ និងនីតិវិធីនៃកិច្ចដំណើរការរបស់អង្គការអន្តរសភាទាំងនោះ ។ ដូច្នេះអង្គការអន្តរសភាតែងតែរៀបចំមហាសន្និបាត និងកិច្ចប្រជុំផ្សេងៗប្រចាំឆ្នាំ ដើម្បីចូលរួមចំណែកជាមួយស្ថាប័ននីតិប្រតិបត្តិ ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងវិស័យនយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តាមរយៈការអនុម័តនូវសេចក្ដីសម្រេច ឬសេចក្ដីថ្លែងការណ៍ នានានៅក្នុងអង្គមហាសន្និបាតរបស់ខ្លួនរៀងៗខ្លួន ។ អង្គការសភាទាំងនោះរួមមាន សហភាពអន្តរសភា (IPU) អន្តរសភាអាស៊ាន (AIPA) សភាក្នុងតំបន់អាស៊ី (APA) សភានិយាយភាសាបារាំង (APF) វេទិកានៃសភាអាស៊ីប៉ាស៊ីហ្វិក (APPF) ជាដើម។



មហាសន្និបាតអន្តរសភាអាស៊ាន




មហាសន្និបាត IPU លើកទី១៤១



*កិច្ចប្រជុំសមាជិកសភាវ័យក្មេង*

ក្នុងក្របខ័ណ្ឌទ្វេភាគី សភាបានខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយសភានៃប្រទេសនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ទាក់ទងនឹងការអនុវត្តមុខងារសភា និងបានចូលរួមចំណែកជាមួយស្ថាប័ននីតិប្រតិបត្តិ ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងវិស័យនយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងបានកៀរគររកការគាំទ្រសម្រាប់ការអភិវឌ្ឍស្ថាប័នសភា និងធនធានមនុស្ស។

អនុលោមតាមមាត្រា ៩០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទីអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ តាមរយៈការផ្តល់សច្ចាប័នឲ្យចូលជារដ្ឋភាគី ឬបញ្ចប់ជារដ្ឋភាគី។

## យន្តការសម្រាប់អនុវត្តការទូតសភារបស់សភាកម្ពុជា

ប្រធានសភាមានតួនាទីចាត់ចែងការងារទំនាក់ទំនងអន្តរជាតិរបស់សភា ដោយមានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន (គណៈកម្មការទី៩) ជាសេនាធិការក្នុងការជួយពិនិត្យ និងផ្តល់យោបល់ ។

សភានៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តការងារការទូតសភាតាមក្របខ័ណ្ឌពហុភាគី និងទ្វេភាគី។

ក្របខ័ណ្ឌពហុភាគី រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតក្រុមរដ្ឋសភាជាតិកម្ពុជាទទួលបន្ទុកកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរសភាតំបន់ និងសកលលោក ចំនួន ១០ និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរសភាតំបន់ និងសកលលោក ចំនួន ៦។

ក្នុងក្របខ័ណ្ឌទ្វេភាគី រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតក្រុមមិត្តភាពរដ្ឋសភាកម្ពុជា ជាមួយប្រទេសចំនួន១៣៦ (នៅតំបន់អាស៊ីមានប្រទេសចំនួន ៤៧ អឺរ៉ុបមានប្រទេសចំនួន ៣៦ អាហ្វ្រិកមានប្រទេសចំនួន ៣០ អាម៉េរិកមានប្រទេសចំនួន ១៥ អាម៉េរិកខាងត្បូងមានប្រទេសចំនួន ៦ និងនៅអូសេអានីមានប្រទេសចំនួន ២) និងព្រឹទ្ធសភាបានបង្កើតក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា ជាមួយប្រទេសចំនួន ១៥ ។

**អង្គការសភាពហុភាគី ដែលរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក**

| ល.រ | អង្គការសភាពហុភាគី | រដ្ឋសភា | ព្រឹទ្ធសភា |
|---|---|---|---|
| ១ | វេទិកាសមាជិកសភាអាស៊ី ដើម្បីប្រជាជន និងការអភិវឌ្ឍ (The Asian Forum of Parliamentarians on Population and Development, AFPPD) | ✓ | |
| ២ | អន្តរសភាអាស៊ាន (ASEAN Inter-Parliamentary Assembly, AIPA) | ✓ | ✓ |
| ៣ | សភាក្នុងតំបន់អាស៊ី (Asia Parliamentary Assembly, APA) | ✓ | ✓ |
| ៤ | សភានិយាយភាសាបារាំង ( Assemblée Parlementaire de la Francophonie, APF) | ✓ | ✓ |
| ៥ | វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (Asia Pacific Parliamentary Forum, APPF) | ✓ | ✓ |
| ៦ | ភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (Asia-Europe Parliamentary Partnership, ASEP) | ✓ | |

| | | | |
|---|---|---|---|
| ៧ | អន្តរសភាកម្ពុជា ឡាវ វៀតណាម ( Cambodia -Lao-Vietnam Inter-Parliamentary, CLV ) | | ✓ |
| ៨ | អង្គការសមាជិកសភាពិភពលោកប្រឆាំងអំពើពុករលួយ ( Global Organization of Parliamentarians Against Corruption, GOPAC ) | ✓ | |
| ៩ | សហភាពអន្តរសភា ( Inter-Parliamentary Union, IPU ) | ✓ | ✓ |

## ការចូលរួមចំណែកពង្រឹងការងារការទូតសភា

ជារៀងរាល់ឆ្នាំគណៈប្រតិភូសភាកម្ពុជា តែងតែអញ្ជើញទៅចូលរួមមហាសន្និបាត វេទិកា ឬកិច្ចប្រជុំប្រចាំឆ្នាំរបស់អង្គការអន្តរសភាតំបន់ និងសកលលោក។ នៅក្នុងមហាសន្និបាត វេទិកា ឬកិច្ចប្រជុំប្រចាំឆ្នាំ គណៈប្រតិភូតែងធ្វើការជជែក និងពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេច ឬសេចក្តីថ្លែងការណ៍នានា ដើម្បីដាក់ចេញនូវយន្តការ ឬអនុសាសន៍ផ្សេងៗ សំដៅជួយជម្រុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងវិស័យនយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ក្នុងតំបន់ និងសកលលោក ។ មន្ត្រីសភាមានការកិច្ចជួយរៀបចំឯកសារជំនួយស្មារតីដល់គណៈប្រតិភូសភាកម្ពុជាសម្រាប់ធ្វើការពិភាក្សា និងផ្តល់យោបល់ឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ។

អគ្គលេខាធិការដ្ឋានសភាកម្ពុជា ដែលជាសេនាធិការរបស់សភាក្នុងការផ្តល់សេវាជូនសមាជិក សមាជិកា ក៏ដូចជាគណៈកម្មការសភា បានរិះរកមធ្យោបាយជាបន្តបន្ទាប់ដើម្បីពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីរួមមានដូចជា ជំនាញស្រាវជ្រាវ ការទូតសភាជាដើម។

ដោយមានកិច្ចសហប្រតិបត្តិការល្អជាមួយវិទ្យាស្ថានសភាកម្ពុជា កន្លងមក វគ្គបណ្តុះបណ្តាលជំនាញស្តីពី “ការទូតសភា” ដែលមានរយៈពេលមួយឆ្នាំ (ពីខែវិច្ឆិកា ២០១៧ ដល់ខែវិច្ឆិកា ឆ្នាំ២០១៨) ត្រូវបានរៀបចំដោយជោគជ័យដែលមានមន្ត្រីចូលរួមសរុបចំនួន ១២រូប (ស្ត្រី៤រូប)។

ក្នុងវគ្គនេះសិក្ខាកាមត្រូវបានហ្វឹកហ្វឺនលើការស្រាវជ្រាវ និងសរសេរឯកសារផ្សេងៗ ចាំបាច់សម្រាប់គាំទ្រដល់ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សភាដូចជា ឯកសារជំនួយស្មារតី សុន្ទរកថា សេចក្តីព្រាងសេចក្តីសម្រេចសម្រាប់មហាសន្និបាត វេទិកា ឬកិច្ចប្រជុំប្រចាំឆ្នាំ កម្រិតតំបន់ និងសកល ។ ចំពោះចំណេះដឹងផ្នែកបច្ចេកទេស សិក្ខាកាមបានសិក្សាស៊ីជម្រៅពីវិធីសាស្ត្រចរចាក្នុងវិស័យការទូត ការវិភាគពីភូមិសាស្ត្រនយោបាយ បញ្ហាប្រឈមនានានៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ និងច្បាប់អន្តរជាតិ ជាពិសេសពួកគេចេះវិភាគអំពី គោលនយោបាយការបរទេស សភាពការណ៍ និងបញ្ហាដែលកើតឡើងវិស័យទំនាក់ទំនងអន្តរជាតិ និងភូមិសាស្ត្រនយោបាយជាដើម ។ មិនតែប៉ុណ្ណោះពួកគេក៏មានឱកាសសិក្សាផងដែរអំពីគោលការណ៍ និងនីតិវិធី នៃការងាររបស់អង្គការអន្តរសភា ក្នុងតំបន់ និងសកលលោក ។

ក្រោយពីបញ្ចប់ការបណ្តុះបណ្តាល មន្ត្រីទាំងអស់ត្រូវបានបញ្ចូលទៅក្នុងអង្គភាពស្រាវជ្រាវដែលទទួលបន្ទុកស្រាវជ្រាវកិច្ចការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានសភាកម្ពុជា រួមមាននាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិជាដើម។ មន្ត្រីទាំងនោះបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីបែបវិភាគនានា និងសុន្ទរកថាផ្សេងៗជូនគណៈប្រតិភូសភាកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំរបស់អង្គការអន្តរសភាក្នុងតំបន់ និងសកលលោក ដូចជា មហាសន្និបាតរបស់អន្តរសភាអាស៊ាន (AIPA) មហាសន្និបាតរបស់សហភាពអន្តរសភា (IPU) កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) ឬសម្រាប់ថ្នាក់ដឹកនាំក្នុងពេលមានជំនួបជាមួយឥស្សរជនជាន់ខ្ពស់អន្តរជាតិ និងសម្រាប់ការបំពេញបេសកកម្ម របស់គណៈប្រតិភូសភាទៅប្រទេសនានា។

លទ្ធផលនេះ បានធ្វើឱ្យវិទ្យាស្ថានសភាកម្ពុជា ឈានទៅជួយបណ្តុះបណ្តាលជំនាញការទូតសភា ដល់មន្ត្រីមកពីសភាដែលជាសមាជិកអាយប៉ាបានជាបន្តបន្ទាប់ ។ ចាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ដំណាច់ឆ្នាំ២០២០ កម្មវិធីបណ្តុះបណ្តាលនេះបានផ្តល់ជូនមន្ត្រីមកពីសភា កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងហ្វីលីពីន ចំនួនពីរជំនាន់ហើយ។

# VI. ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

| *រដ្ឋសភា* | *ព្រឹទ្ធសភា* |
|---|---|
| ***អំពីការរៀបចំ និងការប្រព្រឹត្តទៅ*** | |
| ***អំពីនីតិកាលរបស់រដ្ឋសភា៖***<br>- *នីតិកាលមានកំណត់ ៥ឆ្នាំ ។* | - *នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់៦ឆ្នាំ* |
| - *រដ្ឋសភា មិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុង ករណីដែលរាជរដ្ឋាភិបាលត្រូវបាន ទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ ។*<br>*(រដ្ឋធម្មនុញ្ញ មាត្រា ៧៨)* | - *មិនអាចរំលាយមុនផុតនីតិកាលបានឡើយ ។* |
| ***អំពីសមាជិករដ្ឋសភា*** *គឺរដ្ឋសភាមានសមាជិកតំណាងយ៉ាងតិច ១២០រូប*<br>*( រដ្ឋធម្មនុញ្ញ មាត្រា ៧៦ថ្មី )* | - *ចំនួន : សមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល( មាត្រា៩៩ថ្មីនៃរដ្ឋធម្មនុញ្ញ)* |
| ***អំពីការបោះឆ្នោតជ្រើសតាំង***<br>*តំណាងរាស្ត្រ ៖*<br>- *ការជ្រើសតាំង: បោះឆ្នោតជាសកល* | - *ការជ្រើសតាំង: បោះឆ្នោតជាអសកលផង ជ្រើសតាំងដោយរដ្ឋសភាផង និងចាត់តាំងដោយព្រះមហាក្សត្រផង* |
| - *បេក្ខជនតំណាងរាស្ត្រ គឺជាពលរដ្ឋខ្មែរទាំងពីរភេទដែលមាន:*<br>*១. អ្នកមានសិទ្ធិបោះឆ្នោត*<br>*២. មានអាយុយ៉ាងតិច ២៥ ឆ្នាំ*<br>*៣. មានសញ្ជាតិខ្មែរតាំងពីកំណើត*<br>*(រដ្ឋធម្មនុញ្ញ មាត្រា៣៤ថ្មី មាត្រា ៧៦ថ្មី)* | - *បេក្ខជន : អ្នកមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត* |

| | |
|---|---|
| - **អំពីអង្គបោះឆ្នោត** គឺជាប្រពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ<br>( រដ្ឋធម្មនុញ្ញ មាត្រា ៣៤ថ្មី មាត្រា៧៦ថ្មី ) | - អង្គបោះឆ្នោត : តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង |
| - មណ្ឌលបោះឆ្នោត គឺជារាជធានី ខេត្ត | - មណ្ឌលបោះឆ្នោត : ភូមិភាគទាំង៨ |
| - ប្រធានរដ្ឋសភាត្រូវបំពេញភារកិច្ចជាប្រមុខរដ្ឋស្ដីទីនៅពេលព្រះមហាក្សត្រនិងប្រធានព្រឹទ្ធសភាអវត្តមាន | - ប្រធានព្រឹទ្ធសភាត្រូវបំពេញភារកិច្ចជាប្រមុខរដ្ឋស្ដីទី នៅពេលព្រះមហាក្សត្រអវត្តមាន |
| - ប្រធានរដ្ឋសភា គឺជាអនុប្រធានទី១ នៃក្រុមប្រឹក្សារាជសម្បត្តិ ។ | - ប្រធានព្រឹទ្ធសភា គឺជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ។ |
| - ប្រធានរដ្ឋសភា ទទួលតំណែងជំនួសប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា ពេលដែលប្រធានអវត្តមាន ឬមិនអាចបំពេញមុខងារបាន ។ | - ប្រធានព្រឹទ្ធសភា គឺជាប្រធាន នៃសមាជរដ្ឋសភា និងព្រឹទ្ធសភា |
| -**អំពីការបោះឆ្នោត**ទុកចិត្ត និងការបោះឆ្នោតជ្រើសតាំង៖<br>ក. រដ្ឋសភា បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល ឬអនុម័តញត្តិបន្ទោសរាជរដ្ឋាភិបាល ។<br>(រដ្ឋធម្មនុញ្ញមាត្រា ៩០ថ្មី( ពីរ ) មាត្រា៩៨ថ្មី)<br>ខ. រដ្ឋសភា បោះឆ្នោតជ្រើសតាំងសមាជិកនៃស្ថាប័នមួយចំនួនដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់រៀបចំអង្គការ។ | - សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល |

| អំពីមុខងាររដ្ឋសភា និងព្រឹទ្ធសភា | |
|---|---|
| ក.មុខងារនីតិកម្ម | |
| - រដ្ឋសភា ពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ តាមនីតិវិធីដូចតទៅ៖<br>- ពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលគឺ បញ្ចេញមតិថា តើគួរទទួលពិចារណា ឬទេ។ | - ព្រឹទ្ធសភាពិនិត្យនិងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលរដ្ឋសភាបានអនុម័តបញ្ជូនមកដាក់ឱ្យពិនិត្យ |
| - ពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗក៏បាន ឬលើជំពូកមួយម្តងៗក៏បាន។<br>- អនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល ។<br>(រដ្ឋធម្មនុញ្ញមាត្រា ៩០ថ្មី(ពីរ) និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាប្រការ ២៩ថ្មី ) | - ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើរបាយការណ៍របស់គណៈកម្មការ ការឆ្លើយបំភ្លឺរបស់ តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង |
| - តំណាងរាស្ត្រ មានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។<br>(រដ្ឋធម្មនុញ្ញមាត្រា ៩១ថ្មី ) | |
| - ប្រធានរដ្ឋសភា មានសិទ្ធិផ្តើមគំនិតសើរើ ឬផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>(រដ្ឋធម្មនុញ្ញមាត្រា ១៥៣ថ្មី (ពីរ មាត្រា១៥១ថ្មី ) | - ព្រឹទ្ធសភា ពុំមានសិទ្ធិផ្តួចផ្តើមគំនិតសើរើ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។ |

| ខ.មុខងារត្រួតពិនិត្យការអនុវត្តច្បាប់ | |
|---|---|
| - តំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ៖<br>ក.សំណួរត្រូវសរសេរជាលាយលក្ខណ៍អក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។<br>ខ. រដ្ឋសភា កំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។ ទោះបីយ៉ាងណាក៏ដោយសម័យប្រជុំសម្រាប់ឆ្លើយសំណួរ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។<br>**(រដ្ឋធម្មនុញ្ញ មាត្រា៩៦)** | - ព្រឹទ្ធសភាមានភារកិច្ចសម្រប សម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល |
| - រដ្ឋសភា អាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល ពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកយកមកពិភាក្សាបាន ។<br>**(រដ្ឋធម្មនុញ្ញ មាត្រា៩៨ថ្មី)** | - ព្រឹទ្ធសភាអាចតាមដានត្រួតពិនិត្យការងារ និងការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល ។ |
| **គ.មុខងារតំណាង** | |
| - តំណាងរាស្ត្រក្នុងរដ្ឋសភាមានមុខងារជា តំណាងប្រជាពលរដ្ឋក្នុងមណ្ឌលបោះឆ្នោត និងជាតំណាងប្រជាជាតិខ្មែរទាំងមូល ដែលមានតួនាទីស្វែងយល់ ទទួល និងជួយដោះនូវសំណូមពរ សំណើ និងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។<br>**(រដ្ឋធម្មនុញ្ញ មាត្រា៣៩ មាត្រា៩១ថ្មី )** | - សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ ។ |

# ផ្នែកទី៣
# នីតិវិធីធ្វើច្បាប់


I. នីតិវិធីតាក់តែងសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ ....................................... ១៨៣

១. សេចក្តីព្រាងច្បាប់ ....................................... ១៨៣

២. សេចក្តីស្នើច្បាប់ ....................................... ១៨៣

II. នីតិវិធីពិនិត្យ និងអនុម័តច្បាប់ ....................................... ១៨៣

១. នីតិវិធីពិនិត្យ និងអនុម័តសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នៅរដ្ឋសភា ....................................... ១៨៤

*ក. ការពិនិត្យ និងអនុម័តសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ ....................................... ១៨៤*

*ខ. ការបញ្ជូនសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ទៅព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ ....................................... ១៨៥*

*គ. នីតិវិធីប្រកាសឱ្យប្រើ ....................................... ១៨៦*

២. នីតិវិធីពិនិត្យ និងអនុម័តច្បាប់នៅព្រឹទ្ធសភា ....................................... ១៨៧

# I. នីតិវិធីដាក់តែងសេចក្តីព្រាងនិងសេចក្តីស្នើច្បាប់

## ១. សេចក្តីព្រាងច្បាប់

*សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល គឺនាយករដ្ឋមន្ត្រីត្រូវបំពេញទម្រង់ បែបបទ ដើម្បីផ្ញើសេចក្តីព្រាងច្បាប់ជូនប្រធានរដ្ឋសភាមានជាអាទិ៍ លិខិតស្នើសុំឱ្យរដ្ឋសភាអនុម័តអត្ថបទសេចក្តីព្រាងច្បាប់ និងសេចក្តីថ្លែងហេតុដែលមានចុះហត្ថលេខា ដោយនាយករដ្ឋមន្ត្រី។*

## ២. សេចក្តីស្នើច្បាប់

*សេចក្តីស្នើច្បាប់របស់តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា គឺតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ត្រូវធ្វើទម្រង់បែបបទផ្ញើជូនប្រធានរដ្ឋសភា មានជាអាទិ៍ លិខិតស្នើសុំឱ្យរដ្ឋសភាអនុម័តអត្ថបទសេចក្តីស្នើច្បាប់ និងសេចក្តីថ្លែងហេតុដែលមានចុះហត្ថលេខា ដោយតំណាងរាស្ត្រ ឬ សមាជិកព្រឹទ្ធសភាហត្ថលេខី។*

# II. នីតិវិធីពិនិត្យ និងអនុម័តច្បាប់

***គំនូសបំព្រួញ អំពី នីតិវិធីក្នុងការពិនិត្យ និងអនុម័តរវាងរដ្ឋសភា និងព្រឹទ្ធសភា***



*កំណត់សម្គាល់៖*

*(១) ដំណើរការការងារក្នុងរដ្ឋសភា និងព្រឹទ្ធសភា ។*

*(២) ការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា ។*

## ១. នីតិវិធីពិនិត្យ និងអនុម័តសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នៅរដ្ឋសភា

### ក. ការពិនិត្យ និងអនុម័តសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់

- គណៈកម្មាធិការអចិន្ត្រៃយ៍៖ ប្រធានរដ្ឋសភា កោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យតាមនីតិវិធី ពីរដំណាក់កាល។

  ១. ដំណាក់កាលទី១ ពិនិត្យ និងសម្រេច ប្រគល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឱ្យគណៈកម្មការតាមមុខជំនាញពិនិត្យ បន្ទាប់ពីទទួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ។

  ២. ដំណាក់កាលទី២ ពិនិត្យ និងសម្រេច រៀបចំដាក់របៀបវារៈសម័យប្រជុំរដ្ឋសភា បន្ទាប់ពីគណៈកម្មការជំនាញ ពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ចប់សព្វគ្រប់ ។

- គណៈកម្មការជំនាញ៖ គណៈកម្មការជំនាញ ពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវធ្វើដូចតទៅ៖

  ១. គណៈកម្មការជំនាញ ពិនិត្យផ្ទៃក្នុង ដោយមានការចូលរួមពីអ្នកជំនាញ

  ២. គណៈកម្មការជំនាញ អាចរៀបចំសិក្ខាសាលា ឬវេទិកាពិគ្រោះយោបល់

  ៣. គណៈកម្មការជំនាញ ពិនិត្យជាមួយតំណាងរាជរដ្ឋាភិបាល ឬអ្នកធ្វើសេចក្តីស្នើច្បាប់ ដោយមានការចូលរួមពីតំណាងគណៈកម្មការជំនាញ ដើម្បីពិនិត្យ និងអនុម័ត។

បន្ទាប់ពីគណៈកម្មការជំនាញ បានពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ចប់សព្វគ្រប់ ត្រូវធ្វើលិខិតរាយការណ៍ជូនប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា អំពីលទ្ធផលនៃការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីដាក់ជូនកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងអនុម័តដាក់បញ្ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភា។

- សម័យប្រជុំរដ្ឋសភា៖ សម័យប្រជុំរដ្ឋសភាពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ត្រូវធ្វើដូចតទៅ៖
  ១. អង្គសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរទទួលពិចារណា ឬទេ ។
  ២. អង្គសភាពិភាក្សា និងអនុម័តលើមាត្រាមួយម្ដងៗក៏បាន ឬលើជំពូកមួយម្ដងៗក៏បាន ។
  ៣. អង្គសភាអនុម័តលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ទាំងមូល ។

បែបបទ និងនីតិវិធីពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នៅក្នុងសម័យប្រជុំរដ្ឋសភាខាងលើ ត្រូវមាននីតិវិធីផ្សេងៗទៀតដូចជា៖

១. អង្គសភាអនុម័តរបៀបវារៈសម័យប្រជុំរដ្ឋសភា

២. ប្រធានគណៈកម្មការជំនាញ រាយការណ៍អំពីលទ្ធផលនៃការពិនិត្យសេចក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់ របស់គណៈកម្មការជំនាញជូនអង្គសភា

៣. តំណាងរាជរដ្ឋាភិបាល ឬតំណាងក្រុមតំណាងរាស្ត្រហត្ថលេខី ឬតំណាងក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខី និងប្រធានគណៈកម្មការជំនាញសហការគ្នាការពារសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់។

បន្ទាប់មកអត្ថបទសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ត្រូវបញ្ជូនទៅព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់។

### ខ. ការបញ្ជូនសេចក្ដីព្រាង ឬសេចក្ដីស្នើច្បាប់ទៅព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់

សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយត្រូវបញ្ជូនទៅព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់។

ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមក ពិចារណាភ្លាមជាលើកទី២។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួលដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភាត្រូវធ្វើតែក្នុងរយៈពេលមួយខែ។

រយៈពេល នេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយ មកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទី២ បានមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹម ១៥ថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

### គ. នីតិវិធីប្រកាសឱ្យប្រើ

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ប្រធានរដ្ឋសភាត្រូវផ្ញើលិខិត និងឯកសារភ្ជាប់ជូននាយករដ្ឋមន្ត្រី ដើម្បីឱ្យចាត់ការតាមនីតិវិធីថ្វាយព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើ។

ចំពោះច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ត្រូវផ្ញើជូនប្រធានក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យពីធម្មនុញ្ញភាពជាមុនសិនមុននឹងប្រកាសឱ្យប្រើ។

## ២. នីតិវិធីពិនិត្យ និងអនុម័តច្បាប់នៅព្រឹទ្ធសភា

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ស្នើឡើងដោយប្រធានរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវទទួលយកមកពិនិត្យ ព្រមទាំងចាត់បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ទៅឱ្យគណៈកម្មការមួយ ឬច្រើនពិនិត្យសិក្សាទៅតាមវិស័យជាសមត្ថកិច្ច និងចម្លងចែកជូនគ្រប់សមាជិកព្រឹទ្ធសភា ដោយមានភ្ជាប់សេចក្តីថ្លែងហេតុទៅជាមួយផង ។

ក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍ ។

គណៈកម្មការត្រូវសុំយោបល់ពីសមាជិកព្រឹទ្ធសភា (យល់ព្រម កែសម្រួល បដិសេធជាអសារបង់ ភ្ជាប់ដោយការកត់សម្គាល់ និង/ឬអនុសាសន៍) ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលសមាជិកព្រឹទ្ធសភាម្នាក់ៗបានទទួល ។

សមាជិកព្រឹទ្ធសភាគ្រប់រូប មានភារកិច្ចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកពិនិត្យសិក្សាលម្អិត ដោយផ្តោតលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងក្របខ័ណ្ឌភូមិភាគរបស់ខ្លួន ហើយត្រូវជូនយោបល់ ០៣ថ្ងៃ យ៉ាងយូរ មុនគណៈកម្មការប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬបើជាការប្រញាប់ ០១ថ្ងៃ យ៉ាងយូរ មុនគណៈកម្មការប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ។

ប្រធានគណៈកម្មការ កាលបើពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយ ត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភា និងនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈក្នុងសម័យប្រជុំនីមួយៗ ។ ការកំណត់ថ្ងៃប្រជុំ ត្រូវធ្វើលិខិតផ្ញើជូនសមាជិកព្រឹទ្ធសភា ។ បើមានការកំណត់ផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះ ត្រូវធ្វើជាលិខិតផ្ញើជូនសមាជិកព្រឹទ្ធសភា ដែលមិនបានមកប្រជុំ ។ តាមធម្មតាត្រូវកំណត់ ០២ថ្ងៃ មុនពេលប្រជុំ ដោយមានភ្ជាប់ទៅជាមួយ នូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងករណីប្រញាប់ ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន

ក. កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឲ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ. កូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ៣០នាទី ក្រោយពេលកំណត់ចាប់ផ្ដើមការប្រជុំ ប្រធានព្រឹទ្ធសភាត្រូវលើកពេលប្រជុំ ។

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្ដារ ។ កំណត់ហេតុទាំងអស់ ត្រូវតម្កល់ទុកក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា ។

ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បាន តាមសំណើសុំពីប្រធានព្រឹទ្ធសភា ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីប្រធានរដ្ឋសភា ឬពីនាយករដ្ឋមន្ត្រី ។

អាសនានុក្រមរបស់សមាជិកព្រឹទ្ធសភា ត្រូវរៀបតាមក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ។ ក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងតិច១០រូប ។ សមាជិកព្រឹទ្ធសភា ១រូប អាចចូលជាសមាជិកក្រុមបានតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗត្រូវមានប្រធាន១រូប និងអនុប្រធាន១រូប ។

សមាជិកព្រឹទ្ធសភា ចាត់តាំងដោយព្រះមហាក្សត្រ ជ្រើសតាំងដោយរដ្ឋសភា និងគណបក្សនយោបាយដែលមានអាសនៈតិចជាងដប់អាចជ្រើសរើសចូលជាមួយក្រុមណាមួយតាមការពេញចិត្តរបស់ខ្លួន ។ បញ្ជីរាយនាមរបស់ក្រុមសមាជិកព្រឹទ្ធសភា ត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា ។

ក្រុមសមាជិកព្រឹទ្ធសភា បំពេញតួនាទី ដើម្បីប្រមូលផ្តុំបញ្ញាញាណនយោបាយរបស់ព្រឹទ្ធសភា សំដៅបម្រើឱ្យការបញ្ចេញយោបល់របស់តំណាងក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា ។ ពហុនិយមខាងនយោបាយ ត្រូវអនុវត្តដោយថ្លៃថ្នូរ មានគុណធម៌ និងសុជីវធម៌ ក្នុងក្របខ័ណ្ឌនៃក្រមសីលធម៌សមាជិកព្រឹទ្ធសភា គ្មានការរំលោភបំពាន និងគ្មានការរើសអើងសក្តិសមទៅនឹងលក្ខន្តិកៈទូទៅរបស់សមាជិកព្រឹទ្ធសភា ដែលជាតំណាងឱ្យភូមិភាគ និងប្រជាជាតិខ្មែរទាំងមូល ។

ក្រុមសមាជិកព្រឹទ្ធសភា មានភារកិច្ចដូចខាងក្រោម៖

- រួមគ្នាពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីរៀបចំតំណាងក្រុមថ្លែងយោបល់ក្នុងនាមក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា និងប្រកាន់ជំហររួមរបស់ក្រុមក្នុងការអនុម័ត
- រួមគ្នាផ្តួចផ្តើមគំនិតស្នើច្បាប់ ឬស្នើវិសោធនកម្មច្បាប់
- រួមគ្នាប្រជុំ ដើម្បីចែករំលែកព័ត៌មាន ពិគ្រោះគ្នាកំណត់គោលជំហររបស់ក្រុម ទៅលើបញ្ហា បច្ចុប្បន្នភាពណាមួយ ដែលក្រុមត្រូវយកចិត្តទុកដាក់ក្នុងការថ្លែង ឬប្រកាសជំហរជាសាធារណៈ ។

ជាគោលការណ៍ រយៈពេលបញ្ចេញយោបល់សម្រាប់ក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ត្រូវបានកំណត់ ។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលបានសុំចុះឈ្មោះបញ្ចេញយោបល់ អាចនិយាយបាន ២០នាទីយ៉ាងយូរ ។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលគ្រាន់តែសុំឆ្លើយតប និយាយបានត្រឹមតែ៥នាទី ប៉ុណ្ណោះ ។

បើប្រធានព្រឹទ្ធសភាយល់ថា ជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សា នោះប្រធានអាចអនុញ្ញាតបន្ថែមពេលឱ្យនិយាយបាន ១០នាទីទៀត ។ ការបន្ថែមនេះ អាចឱ្យបន្តបានពីរដងក្នុងប្រធានបទតែមួយ ។ សមាជិកក្នុងក្រុមជាមួយ មានសិទ្ធិសុំបញ្ចេញមតិបន្ថែមក្នុងប្រធានបទដដែល និងក្នុងរយៈពេលដែលនៅសល់ពីការកំណត់ខាងលើ ។

សូមបញ្ជាក់ជូនថា បទប្បញ្ញត្តិអំពីការសុំចុះឈ្មោះបញ្ចេញយោបល់ និងការកំណត់រយៈពេលបញ្ចេញយោបល់ខាងលើ ប្រើសម្រាប់តែសមាជិកព្រឹទ្ធសភាតែប៉ុណ្ណោះ មិនយកមកប្រើសម្រាប់តំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សេចក្តីស្នើច្បាប់ ឬអ្នកជំនាញការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះទេ ។

តាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូងរួចហើយ ត្រូវបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់ ។

### ១. ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីពិនិត្យនិងសម្រេចលើសំណើរបស់រដ្ឋសភា

- ពិនិត្យលើទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបញ្ជូនមក និងសម្រេចបញ្ជូនទៅគណៈកម្មការណាមួយពិនិត្យសិក្សា ទៅតាមវិស័យជាសមត្ថកិច្ច
- ក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍ ។

### ២. គណៈកម្មការទទួលបន្ទុកពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

- ដំណើរការសុំយោបល់ពីគ្រប់សមាជិកព្រឹទ្ធសភា (យោបល់យល់ព្រម កែសម្រួល បដិសេធជាអសារបង់ភ្ជាប់ដោយការកត់សម្គាល់ និង/ឬអនុសាសន៍) ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលសមាជិកព្រឹទ្ធសភាម្នាក់ៗបានទទួល
- ការផ្តល់យោបល់ពីសមាជិកព្រឹទ្ធសភាត្រូវធ្វើក្នុងរយៈពេលបីថ្ងៃយ៉ាងយូរ បើជាការប្រញាប់មកត្រឹមតែមួយថ្ងៃយ៉ាងយូរ មុនគណៈកម្មការប្រជុំ
- សមាជិកព្រឹទ្ធសភាគ្រប់រូប មានភារកិច្ចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកពិនិត្យសិក្សាលម្អិតដោយផ្តោតលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌភូមិភាគរបស់ខ្លួន

- ក្រុមសមាជិកព្រឹទ្ធសភានីមួយៗកោះប្រជុំដើម្បីកំណត់អំពីជំហររបស់ក្រុម និង ចាត់តាំងតំណាងក្រុម ដើម្បីថ្លែងពីជំហររបស់ក្រុមក្នុងសម័យប្រជុំព្រឹទ្ធសភា
- គណៈកម្មការទទួលបន្ទុក ត្រូវប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬតំណាងហត្ថលេខី ម្ចាស់សេចក្តីស្នើច្បាប់ ដោយមានការអញ្ជើញតំណាងគណៈកម្មការនានា ឬតំណាងក្រុមសមាជិកព្រឹទ្ធសភា និងអ្នកជំនាញចូលរួម ដើម្បីពិគ្រោះយោបល់ និងរៀបចំរបាយការណ៍ស្តីពី លទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា
- ប្រធានគណៈកម្មការទទួលបន្ទុក កាលបើពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយ ត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភា និងនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា ។

### ៣. ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការនានា សុំដាក់បញ្ចូល ក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភា

- ប្រធានគណៈកម្មការទទួលបន្ទុក នាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យនិងសម្រេច
- អង្គប្រជុំត្រូវសម្រេចថា យល់ព្រម ឬមិនយល់ព្រម ដើម្បីដាក់បញ្ចូលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ទៅក្នុងរបៀបវារៈនៃសម័យប្រជុំព្រឹទ្ធសភា ។

### ៤. ប្រជុំព្រឹទ្ធសភាដើម្បីពិនិត្យនិងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង

- កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។ បើកូរ៉ុមមិនគ្រប់ ក្នុងរយៈពេល៣០នាទី ក្រោយពេលកំណត់ ចាប់ផ្តើមការប្រជុំ ប្រធានអង្គប្រជុំត្រូវលើកពេលប្រជុំ

- តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬតំណាងហត្ថលេខីម្ចាស់សេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលមកការពារ ត្រូវមានវត្តមាននៅក្នុងសាលប្រជុំ តាមការអញ្ជើញរបស់ប្រធានព្រឹទ្ធសភា
- ដំណើរការប្រជុំត្រូវធ្វើតាមរបៀបវារៈ ។ មុនចាប់ផ្តើមសម័យប្រជុំព្រឹទ្ធសភាត្រូវអនុម័តរបៀបវារៈនិងសមាសភាពលេខាធិការសម័យប្រជុំនីមួយៗ
- ការពិនិត្យនិងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង នៅក្នុងអង្គប្រជុំព្រឹទ្ធសភា ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក
- អង្គប្រជុំព្រឹទ្ធសភា ពិនិត្យពិភាក្សាលើសេចក្តីសន្និដ្ឋានរួមរបស់គណៈកម្មការទទួលបន្ទុក ។ តំណាងក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ដែលប្រធានអង្គប្រជុំបានអនុញ្ញាតឱ្យមានយោបល់ ត្រូវមានយោបល់តែអំពីរឿងដែលកំពុងតែពិភាក្សាប៉ុណ្ណោះ
- តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលមកការពារត្រូវឆ្លើយបំភ្លឺចំពោះយោបល់ របស់សមាជិកព្រឹទ្ធសភាដែលបានលើកឡើង
- អង្គប្រជុំព្រឹទ្ធសភាពិនិត្យនិងឱ្យយោបល់ (យល់ព្រមដោយឥតកែប្រែ ទទួលយកយោបល់សុំកែសម្រួល ឬទទួលយកយោបល់សុំបដិសេធជាអសារបង់ )
- បន្ទាប់ពីព្រឹទ្ធសភា បានពិនិត្យនិងឱ្យយោបល់រួចហើយ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនេះ ត្រូវបញ្ជូនទៅរដ្ឋសភាវិញ ។

# ផ្នែកទី៤
# សមាជវេទរដ្ឋសភា និងព្រឹទ្ធសភា


I. រចនាសម្ព័ន្ធ........................................................................១៩៥

II. តួនាទី និងភារកិច្ច ..........................................................១៩៦

III. អគ្គលេខាធិការដ្ឋានសមាជ ...................................១៩៦

សមាជរដ្ឋសភា និងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នានៃសមាជិករដ្ឋសភា និងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជ ត្រូវកំណត់ក្នុងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃសមាជរដ្ឋសភា និងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុង នៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ។

# I. រចនាសម្ព័ន្ធ

សមាជរដ្ឋសភា និងព្រឹទ្ធសភា មានរចនាសម្ព័ន្ធដូចខាងក្រោម៖

## ក. ថ្នាក់ដឹកនាំសមាជរដ្ឋសភា និងព្រឹទ្ធសភា

- ប្រធានព្រឹទ្ធសភា ជាប្រធានសមាជ
- ករណីប្រធានសមាជអវត្តមាន ឬ មានធុរៈមិនអាចបំពេញមុខងារបាន ប្រធានរដ្ឋសភាត្រូវទទួលភារកិច្ចជំនួស ។
- តំណែងជំនួសប្រធានសមាជ ដូចមានចែងខាងលើនេះ អាចនឹងដូរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ៖

| | |
|---|---|
| • អនុប្រធានទី ១ | ព្រឹទ្ធសភា |
| • អនុប្រធានទី ១ | រដ្ឋសភា |
| • អនុប្រធានទី ២ | ព្រឹទ្ធសភា |
| • អនុប្រធានទី ២ | រដ្ឋសភា |

## ខ. សមាជរដ្ឋសភា និងព្រឹទ្ធសភា មានគណៈកម្មាធិការសមាជមួយជាអ្នករៀបចំសមាជដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ប្រធានព្រឹទ្ធសភា | ប្រធាន |
| - ប្រធានរដ្ឋសភា | អនុប្រធាន |
| - អនុប្រធានទី ១ ព្រឹទ្ធសភា | សមាជិក |
| - អនុប្រធានទី ១ រដ្ឋសភា | សមាជិក |
| - អនុប្រធានទី ២ ព្រឹទ្ធសភា | សមាជិក |
| - អនុប្រធានទី ២ រដ្ឋសភា | សមាជិក |

ប្រធានគណៈកម្មការទាំងអស់ នៃព្រឹទ្ធសភា និងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

## II. តួនាទី និងភារកិច្ច

សមាជរដ្ឋសភា និងព្រឹទ្ធសភា មានតួនាទី និងភារកិច្ច ដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់។

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិមាន៖

- ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ឬ
- ករណីប្រធានសក្តិ បណ្តាលឱ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ជាតិ និងប្រជាជន ឬ
- ករណីផ្សេងៗទៀត ដែលគណៈកម្មាធិការសមាជយល់ឃើញថា ជាបញ្ហាសំខាន់របស់ប្រទេសជាតិ។

## III. អគ្គលេខាធិការដ្ឋានសមាជ

សមាជរដ្ឋសភា និងព្រឹទ្ធសភា មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។

# ផ្នែកទី៥
# អគ្គលេខាធិការដ្ឋាន


**I. អគ្គលេខាធិការដ្ឋានរដ្ឋសភា ....................................១៩៩**

**១. រចនាសម្ព័ន្ធ ....................................................................................១៩៩**

*ក. ថ្នាក់ដឹកនាំ....................................................................................១៩៩*

*ខ. រចនាសម្ព័ន្ធគ្រប់គ្រង ....................................................................១៩៩*

**២. តួនាទី និងភារកិច្ច.........................................................................២០០**

**II. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា...............................២០០**

**១. រចនាសម្ព័ន្ធ....................................................................................២០០**

**២. តួនាទី និងភារកិច្ច.........................................................................២០១**

# I. អគ្គលេខាធិការដ្ឋានរដ្ឋសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា ជាសេនាធិការឱ្យរដ្ឋសភា ហើយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

## ១. រចនាសម្ព័ន្ធ

### ក. ថ្នាក់ដឹកនាំ

អគ្គលេខាធិការដ្ឋានរដ្ឋសភា ដឹកនាំដោយ អគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរង មួយចំនួន ដែលមិនមែនជាតំណាងរាស្ត្រ។

### ខ. រចនាសម្ព័ន្ធគ្រប់គ្រង

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ អគ្គនាយកដ្ឋាន នាយកដ្ឋាន ការិយាល័យ ផ្នែក អង្គភាព ដូចខាងក្រោម៖

- អគ្គនាយកដ្ឋានចំនួន ៤
- អគ្គាធិការដ្ឋាន ចំនួន ១



## ២. តួនាទី និងភារកិច្ច

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

ក- រៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា

ខ- ទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាល និងសេវានានាជូនរដ្ឋសភា

គ- ទំនាក់ទំនងផ្សេងៗក្រៅរដ្ឋសភា

ឃ- ទទួលរ៉ាប់រងសន្តិសុខ និងសណ្ដាប់ធ្នាប់នៅក្នុងរដ្ឋសភា

ង- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋសភាប្រគល់ឱ្យ

ច- អនុវត្តតួនាទី និងភារកិច្ចដែលមានកំណត់នៅក្នុងសេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

# II. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

## ១. រចនាសម្ព័ន្ធ

អគ្គាធិការដ្ឋាន — **អគ្គលេខាធិការដ្ឋាន** — ខុទ្ទកាល័យអគ្គលេខាធិការដ្ឋាន

| អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី | អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ | អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ | អគ្គនាយកដ្ឋានស្រាវជ្រាវ |
|---|---|---|---|---|
| - ន. រដ្ឋបាល<br>- ន. ដ្ឋានហិរញ្ញវត្ថុ<br>- ន. គ្រប់គ្រងបុគ្គលិក<br>- ន. អភិវឌ្ឍន៍ធនធានមនុស្ស<br>- ន. គ្រប់គ្រងអគារ សារពើភ័ណ្ឌ និងសំណង់<br>- ន. ផែនការ និងបូកសរុប<br>- អង្គសន្តិសុខ | - ន. នីតិវិធី<br>- ន. ភូមិភាគ និងសមូហភាពដែនដី<br>- លេ. អមគណៈកម្មការទាំង១០<br>- លេ. ក្រុមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា<br>- លេ. ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រឹទ្ធសភា<br>- ល. អមអ្នកនាំពាក្យព្រឹទ្ធសភា | - ន. ព័ត៌មាន<br>- ន. ព័ត៌មានវិទ្យា (ICT)<br>- បណ្ណាល័យ<br>- បណ្ណសារដ្ឋាន | - ន. ពិធីការ<br>- ន. ទំនាក់ទំនងអន្តរជាតិ<br>- ន. ស្រាវជ្រាវកិច្ចការអន្តរជាតិ | - ន. ស្រាវជ្រាវច្បាប់<br>- ន. ស្រាវជ្រាវទូទៅ<br>- ន. ស្រាវជ្រាវកិច្ចការសភា<br>- ន. ស្រាវជ្រាវថវិកា (PBO) |

## ២. តួនាទី និងភារកិច្ច

ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋានមួយ ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា ។ អគ្គលេខាធិការដ្ឋាននេះ ទទួលរ៉ាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំនិងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា ។

នៅរៀងរាល់ដើមនីតិកាលនីមួយៗ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំព្រឹទ្ធសភាបានហើយ ប្រធានព្រឹទ្ធសភា ដោយមានការឯកភាពពីអនុប្រធានទាំងពីររបស់ខ្លួន ស្នើសុំទៅព្រះមហាក្សត្រតែងតាំងឥស្សរជនជាន់ខ្ពស់មួយរូបជាអគ្គលេខាធិការ និង អគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដើម្បីដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ដែលមានបទពិសោធន៍ក្នុងកិច្ចការសភា ឬរដ្ឋបាលយ៉ាងតិច ១០ឆ្នាំ ហើយដែលមិនមែនជាសមាជិកព្រឹទ្ធសភា និងមិនមែនជាអ្នកដឹកនាំគណបក្សនយោបាយ ។

អគ្គលេខាធិការ មានឋានៈស្មើនឹងរដ្ឋលេខាធិការ ។

អគ្គលេខាធិការរង មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ។

បុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រធានព្រឹទ្ធសភា ស្របតាមច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

នៅក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នាយកដ្ឋានថ្មីចំនួនពីរ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០២០ ដែលជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិក្នុងការពង្រឹងសមត្ថភាពជំនាញជាមួយវិទ្យាស្ថានសភាកម្ពុជា គឺនាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិនិងនាយកដ្ឋានស្រាវជ្រាវថវិកា។

ក្នុងតួនាទីជាសេនាធិការ ដើម្បីរួមចំណែកជួយឲ្យព្រឹទ្ធសភាសម្រេចបាននូវចក្ខុវិស័យប្រែក្លាយជាសភាទំនើប និងជាដៃគូដ៏ល្អជាមួយសភានានាក្នុងតំបន់ និងពិភពលោក ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០២១-២០៣០) អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានដាក់ចេញនូវទស្សនវិស័យ និងអាទិភាពសម្រាប់រយៈពេលវែង គឺក្នុងពេល១០ឆ្នាំខាងមុខត្រូវខិតខំកសាងសមត្ថភាពឲ្យបានខ្ពស់ក្នុងការផ្តល់សេវាជូនព្រឹទ្ធសភា ឲ្យមានគុណភាព និងប្រសិទ្ធភាពមួយថ្មី ។

រយៈពេលនៃការអភិវឌ្ឍស្ថាប័ន(២០២១-២០៣០) ជាពិសេសបរិបទព្រឹទ្ធសភានីតិកាលទី៤ និងនីតិកាលទី៥ មានកត្តាគន្លឹះចំនួន៥ ដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតគឺ កត្តាសេវា មនុស្ស សមត្ថភាព ការសហការគ្នា និងកត្តាបរិស្ថាន។ ក្នុងដំណាក់កាលនេះវិទ្យាស្ថានសភាកម្ពុជា (PIC) ឬមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) គឺជាស្នូលនៃការអភិវឌ្ឍស្ថាប័ន ហើយជាចំណុចផ្តុំនៃជំនួយពហុភាគីសម្រាប់អភិវឌ្ឍអង្គការនីតិប្បញ្ញត្តិកម្ពុជា។ ក្រៅពីការផ្អែកលើវិទ្យាស្ថានសភាកម្ពុជា (PIC) ដែលនឹងប្រែក្លាយទៅជាមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ព្រឹទ្ធសភាត្រូវខិតខំផ្ទាល់ផងដែរ ក្នុងការពង្រឹងពង្រីកទំនាក់ទំនងជាមួយដៃគូនានា ទាំងក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីទទួលបាននូវការឧបត្ថម្ភគាំទ្រចាំបាច់ សម្រាប់ការអភិវឌ្ឍស្ថាប័ន ។

# ឯកសារពិគ្រោះ ឬឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពី លក្ខន្តិកៈតំណាងរាស្ត្រ
- ច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភា
- ច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ( ពីឆ្នាំ១៩៤៧ ដល់១៩៩៣)
- កំណត់ហេតុប្រជុំក្រុមប្រឹក្សាព្រះរាជអាណាចក្រកម្ពុជាលើកទី២និងលើកទី៣ ថ្ងៃទី៩និងទី២៣ ខែកុម្ភៈ ឆ្នាំ១៩៤៨
- បញ្ញត្តិលេខៈ ៤១/៧២ ប.ស.ខ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧២ ស្តីពី ការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភាទី១ នៃសាធារណរដ្ឋខ្មែរ
- ឯកសារផ្ទាល់ស្តីពី រដ្ឋសភា
- គេហទំព័ររដ្ឋសភា http://nac.org.kh
- គេហទំព័រព្រឹទ្ធសភា https://senate.gov.kh/

## ដឹកនាំការរៀបចំសៀវភៅដោយ

| | |
|---|---|
| ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា | ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា |
| ឯកឧត្តម ឡេង ប៉េងឡុង | អគ្គលេខាធិការរដ្ឋសភា |
| ឯកឧត្តម អ៊ុំ សារិទ្ធ | អគ្គលេខាធិការព្រឹទ្ធសភា |
| លោក គីម យាត ដារ៉ារិទ្ធ | នាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា |

# សមាសភាពក្រុមការងាររៀបចំ និងតាក់តែងសៀវភៅ

## ក្រុមការងារនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា

១. ឯកឧត្តម កែ កេតនិន — អគ្គនាយក នៃអគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ
ប្រធាន

២. ឯកឧត្តម ឡាយ ប៊ុនម៉េង — អគ្គនាយករងនីតិកម្ម និងស្រាវជ្រាវ
អនុប្រធាន

៣. លោក លី រតនាឌ — ប្រធានការិយាល័យជំនួយការគណៈកម្មការនានា
សមាជិក

៤. កញ្ញា ចៅ សូម៉ាណី — អនុប្រធានការិយាល័យជំនួយការគណៈកម្មការនានា
សមាជិកា

៥. លោក អ៊ុំ សុភក្តិ — អនុប្រធានការិយាល័យស្រាវជ្រាវច្បាប់
សមាជិក

## ក្រុមការងារនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

១. ឯកឧត្តម ប៊ុន វុទ្ធា — អគ្គ.នា.នៃអគ្គនាយកដ្ឋានសេវាច្បាប់និងសម្ព័ន្ធភាពដែនដី
ប្រធាន

២. ល.ជំទាវ សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
អនុប្រធាន

៣. លោក យិន យូវ៉ាន់ — អគ្គនាយករងសេវាច្បាប់ និងសម្ព័ន្ធភាពដែនដី
សមាជិក

៤. លោក តុន គន្ធូ — ប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់
សមាជិក

៥. លោក សំអឿន ម៉ារឌី — ប្រធាននាយកដ្ឋានស្រាវជ្រាវទូទៅ
សមាជិក

៦. លោក ប៉ិះ ជឿន — អនុប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់
សមាជិក

## ក្រុមការងារនៃវិទ្យាស្ថានសភាកម្ពុជា

១. លោកស្រី គង់ គន្ធា ប្រធានទំនាក់ទំនងសភា

២. លោក អែម សូរ៉ានី អ្នកជំនាញប្រាស្រ័យទាក់ទងសភា

## សម្របសម្រួល និងគាំទ្រការបោះពុម្ពដោយ

វិទ្យាស្ថានសភាកម្ពុជា តាមរយៈជំនួយហិរញ្ញប្បទានពីទីភ្នាក់ងារស៊ុយអែត ដើម្បីកិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍អន្តរជាតិ ( Sida )

## រចនា និងរៀបចំប្លង់សៀវភៅ

Graphic Roots Co., LTD.

**Tel**: +855 ( 0 ) 23 210 712

**Website**: graphicroots.net

## បោះពុម្ព

STC (JSRC) Printing House

**Tel**: +855 ( 0 ) 12 974 567

**Email:** jsrcprinting@gmail.com

រក្សាសិទ្ធិដោយ អគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពក្នុង ខែមីនា ឆ្នាំ២០២១






មុខងារនីតិកម្ម






មុខងារតំណាង






មុខងារតាមដានការអនុវត្តច្បាប់

**ផ្តួចផ្តើមរៀបចំ និងបោះពុម្ពដោយ**

គណៈកម្មការនីតិកម្ម និងយុត្តិធម៌រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**សម្របសម្រួល និងគាំទ្រការបោះពុម្ពដោយ**

វិទ្យាស្ថានសភាកម្ពុជា តាមរយៈជំនួយហិរញ្ញប្បទានពី Sida

បោះពុម្ពក្នុង ខែមីនា ឆ្នាំ២០២១

ចំនួនបោះពុម្ព ១០០០ក្បាល

វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

Sweden
Sverige